# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី៣៤ លេខ ៦ ខែ មិថុនា

ព.ស. ២៥០៤ គ.ស. ១៩៦២

- ភ្នំពេញ -

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

បេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា — បញ្ជីរឿង — ទំព័រ


– ស្តីអំពីអដ្ឋង្គិកមគ្គ អធិប្បាយ អ្នកនិពន្ធ ទា-សាន អតីតរដ្ឋមន្ត្រី រៀបរៀង . . . . ៦០៣
– ព្រះអភិធម្មបិដក (គម្ពីរព្រះយមកៈ) (ត) លោកប៊ូ-ប៉ុ ប្រែរៀបរៀង . . . . ៦១៧
– មធុរសវាហិណី(ត)សម្ដេចព្រះធម្មលិខិតល្វី-ឯម ប្រែរៀបរៀង . . . . . . ៦២៨
– មហោសថជាតក(ត) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹតព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ ៦៣៥
– ប្រវត្តិព្រះឥន្ទនិងសង្គ្រាមអសុរ (ពាក្យកាព្យ) លោក ផល-ទិត្យ និពន្ធ . . . . . ៦៥១


ផ្នែកអក្សរសាស្ត្រ


– ភាសាសាស្ត្រនិងអក្សរសាស្ត្រខ្មែរ (ត) លោក ឌឹក-ឆាម រៀបរៀង . . . . . . ៦៦៧
– ពាក្យខ្មែរប្រែពីបរទេស (ត) ដោយគណៈកម្មការជាតិនៃការសិក្សាផ្នែកអក្សរ “ក” . . ៦៨៥
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (ត) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . . . . . ៦៨៦
– រឿងសាមកុក (ត) និពន្ធ នូ-កន ប្រែ . . . . . . . . . . . . ៦៨៧
– រឿងព្រេងចិន (ត) លោក ភិយ ប៊ុក ប្រែរៀបរៀង. . . . . . . . . . ៧០៣
– រឿងព្រេង ទាក់ទងដោយភូមិសាស្ត្រខ្មែរ . . . . . . . . . . . ៧១៥


ផ្នែកកំណត់ទិនប្រវត្តិការណ៍


– ដំណឹងផ្សេង ៗ នៃក្រសួងធម្មការ . . . . . . . . . . . . . ៧១៩


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជា៖ ២៣០៛០០

34è Année — N° 6 — Juin 1962

# KAMBUJASURIYA

Revue mensuelle de culture religieuse et littéraire
publiée par l'Institut-Bouddhique de Phnom-Penh

## SOMMAIRE

### Partie religieuse

—Athangikamgga par Oknha TEA-SAN . . . . . . . . . . . . . 603
—Préah Abhidhamma pitaka «Kampir Préah Yamaka» (suite)
par M. BOU-PO . . . . . . . . . . . . . . . . . . . . . 617
—Madhurasavahini (suite) par Samdech Préah Dhammalikhita
LOUIS-EM . . . . . . . . . . . . . . . . . . . . . . 628
—Mahosotha Jataka (suite) relevé du manuscrit sur feuilles de la
tanier par M. IM-PHON, revu et corrigé par le Vén. KEM-TO . . . 635
—L'Histoire d'Indra et de la guerre des Asora (en vers)
par M. PHAL-TIT . . . . . . . . . . . . . . . . . . 651

### Partie littéraire

—Le Langage et la littérature Khmèrs (suite) par M. DIK-KEAM. . . 667
—Activité de la Commission Culturelle (suite) chapitre «Ka» . . . 685
—Dictionnaire Sanscrit-Khmer (suite) par Vén. PANG-KHAT . . . 686
—Histoire de Sam-Kok (suite) traduite par Oknha NOU-KAN . . . 687
—Contes et Légendes de la chine (suite) traduits par M. RAY-BUC 703
—Légendes relatives à l'origine géographique Khmèr . . . . . . 715

### Notes et Chroniques

—Nouvelles du Ministère des Cultes . . . . . . . . . . . . 719

Prix d'Abonnement annuel (comprenant 12 numéros) : 230 ; 00

## ផ្នែកសាសនា

ពាក្យយាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលោមក ឲ្យធ្វើល្អទៅ ។
ឲ្យជុំសភាត់ចិត្ត កុំឲ្យហ្មងសៅ
នេះឯងលោកហៅ ពុទ្ធសាសនា ។

ប.ព.

### វិចារណកថាស្ដីអំពីអដ្ឋង្គិកមគ្គ

*អ្នកនុកញ៉ា ជា-សាង អតីតរដ្ឋមន្ត្រីរៀបរៀង*

---

### ១– អដ្ឋង្គិកមគ្គ គឺអ្វី ?

*អដ្ឋង្គិកមគ្គនោះមានអង្គ ៨ គឺ:*

*១– សម្មាទិដ្ឋិ ការយល់ឃើញត្រូវ ។*

*ឯការយល់ឃើញត្រូវនេះ សំដៅការយល់ឃើញត្រូវចំពោះអរិយសច្ច ៤ ប្រការ មានទុក្ខសច្ចជាដើម និងមគ្គសច្ចជាទីបំផុត ។*

*២– សម្មាសង្កប្បោ ការត្រិះរិះត្រូវ ។*

*ឯការត្រិះរិះត្រូវនេះ គឺសំដៅកុសលវិតក្កៈ ៣ មាននេក្ខម្មវិតក្កៈ គឺការត្រិះរិះនឹងចេញចាកកាមជាដើម ។*

*៣– សម្មាកម្មន្តោ ការធ្វើត្រូវ ។*

*ឯការធ្វើត្រូវនេះ គឺសំដៅវិរតិចេតនាវៀរមិនប្រព្រឹត្តនូវកាយទុច្ចរិត ៣ ។*

៤- សម្មាវាចា ការនិយាយត្រូវ ។

ឯការនិយាយត្រូវនេះ គឺសំដៅវិរតិចេតនា វៀរមិនពោលនូវវចីទុច្ចរិត៤ ។

៥- សម្មាអាជីវោ ការចិញ្ចឹមជីវិតត្រូវ (របស់បព្វជិតពុទ្ធសា-សនិក) ។

ឯការចិញ្ចឹមជីវិតត្រូវនេះ គឺសំដៅវិរតិចេតនា វៀរមិនប្រព្រឹត្តនូវអនេសនៈ ២១ និងបាបធម៌ ៤ ។

៦- សម្មាវាយាមោ ការព្យាយាមត្រូវ ។

ឯការព្យាយាមត្រូវនេះ គឺសំដៅបធាន ៤ មានសំវរប្បធានជាដើម ។

៧- សម្មាសតិ ការតាំងស្មារតីត្រូវ ។

ឯការតាំងស្មារតីត្រូវនេះ គឺសំដៅសតិបដ្ឋាន ៤ មានកាយានុ-បស្សនាសតិបដ្ឋានជាដើម ។

៨- សម្មាសមាធិ តាំងចិត្តឲ្យស្ងប់ត្រូវ ។

ឯការតាំងចិត្តឲ្យស្ងប់ត្រូវនេះ គឺសំដៅការចំរើនឈាន មានការចំរើនរូបជ្ឈាន ៤ ជាដើម ។

២- តើត្រូវចំរើនដូចម្តេច ដើម្បីនឹងបំពេញអដ្ឋង្គិកមគ្គ គឺមគ្គប្រ-កបដោយអង្គ៨នេះ ឲ្យសម្រេចកើតមានជាក់ច្បាស់ឡើងបាន ?

ឯអដ្ឋង្គិកមគ្គ គឺមគ្គប្រកបដោយអង្គ៨នេះជាភាវេតព្វធម៌ គឺធម៌ដែលយោគាវចរ គប្បីចំរើនឲ្យសម្រេចកើតមានជាក់ច្បាស់ឡើង ។ ត្រង់នេះ

បានសេចក្តីថា យោគាវចរគប្បីចំរើនគុណធម៌ដែលជាគូនៃអង្គនីមួយៗ ដូចបានពណ៌នាខាងលើនេះ ឲ្យសម្រេចកើតមានប្រាកដឡើងដូចតទៅនេះ ៖

ដើម្បីនឹងចំរើនអង្គសម្មាទិដ្ឋិឲ្យកើតមានជាក់ច្បាស់ឡើងនោះ យោគាវចរគប្បីលើកទុក្ខ ១២ កងមានជាតិទុក្ខជាដើម មកពឹងត្រិះរិះពិចារណាស្រាវជ្រាវរកហេតុបច្ច័យឲ្យរឿយៗ រៀងកបដកប លុះគ្រាតែញាណ គឺការដឹងច្បាស់ ៤ ប្រការកើតឡើងគឺ ៖

១- ទុក្ខេញាណំ ដឹងច្បាស់នូវកងទុក្ខ គឺដឹងច្បាស់ថាទុក្ខមានព្រោះមានខន្ធ ៥ ជាទីកើត នឹងជាទីតាំងសម្រាប់ឲ្យទុក្ខនោះ អាចមានដំណើរប្រព្រឹត្តទៅបាន ព្រមទាំងដឹងច្បាស់ថា ទុក្ខនោះជាបរិញ្ញាតព្វធម៌ គឺធម៌គប្បីកំណត់ទុកក្នុងចិត្តថា ទុក្ខនេះតែងតែបៀតបៀនសត្វ ធ្វើឲ្យកើតមានសេចក្តីឈឺចាប់ សេចក្តីខ្លោចផ្សាក្តៅក្រហាយគ្រប់បែបយ៉ាង, គ្មានសត្វណាដែលស្ថិតនៅលើត្រៃភព អាចគេចខ្លួនឲ្យរួចផុតចាកទុក្ខនោះបានសោះឡើយ ។

២- ទុក្ខសមុទយេញាណំ ដឹងច្បាស់នូវហេតុនៃកងទុក្ខ គឺដឹងច្បាស់ថា តណ្ហា ៣ ប្រការ គឺកាមតណ្ហា ១ ភវតណ្ហា ១ និងវិភវតណ្ហា ១ ជាហេតុនាំឲ្យខន្ធ ៥ កើតឡើងក្នុងភពថ្មីទៀត ព្រមទាំងដឹងច្បាស់ថា តណ្ហា ៣ ប្រការនោះជាបហាតព្វធម៌ គឺធម៌គប្បីលះឲ្យដាច់ស្រឡះចេញ ។

៣– ទុក្ខនិរោធញ្ញាណំ  ដឹងច្បាស់នូវកិរិយារលត់នៃទុក្ខ ពោលគឺដឹងច្បាស់ថា  កិរិយារលត់នៃតណ្ហា ៣ ប្រការ  ជាហេតុនាំឲ្យទុក្ខរលត់ជាដាច់ ព្រមទាំងដឹងច្បាស់ថា  កិរិយារលត់នៃតណ្ហា ៣ ប្រការជាសច្ឆិកាតព្វធម៌ គឺធម៌គប្បីធ្វើឲ្យជាក់ច្បាស់ឡើង ។

៤– ទុក្ខនិរោធគាមិនីបដិបទាញ្ញាណំ  ដឹងច្បាស់នូវបដិបទា ដែលអាចញ៉ាំងទុក្ខឲ្យរលត់ទៅបាន  ពោលគឺដឹងច្បាស់ថា អដ្ឋង្គិកមគ្គ  ជាបដិបទាអាចធ្វើឲ្យជាក់ច្បាស់  នូវកិរិយារលត់នៃតណ្ហា ៣ ប្រការនោះបាន ព្រមទាំងដឹងច្បាស់ថា  អដ្ឋង្គិកមគ្គនោះជាភាវេតព្វធម៌ គឺធម៌គប្បីចំរើនឲ្យសម្រេចកើតមានប្រាកដឡើង ។

នៅខណៈដែលអង្គសម្មាទិដ្ឋិកើតមានក្នុងខន្ធសន្តាន  ដូចបានពណ៌នាខាងលើនេះបរិបូណ៌ហើយ, ទើបអង្គសម្មាទិដ្ឋិនោះ ប្រែទៅជាមគ្គុទ្ទេសក៍ដឹកនាំយោគាវចរឲ្យត្រិះរិះគិតឃើញនូវកុសលវិតក្កៈ ៣ ប្រការ គឺៈ នេក្ខម្មវិតក្កៈ  ត្រិះរិះចេញចាកកាម ១, អព្យាបាទវិតក្កៈ  ត្រិះរិះវៀរមិនព្យាបាទដល់អ្នកដទៃ ១, និងអវិហិង្សាវិតក្កៈ  ត្រិះរិះវៀរមិនបៀតបៀនអ្នកដទៃ ១ ថាជាការចាំបាច់គប្បីបំពេញឲ្យសម្រេចឡើង  ទើបជាហេតុអាចនាំឲ្យចំរើនអង្គឯទៀតគឺ អង្គសម្មាកម្មន្តោ, សម្មាវាចា, សម្មាអាជីវោ, សម្មាវាយាមោ, សម្មាសតិ និងសម្មាសមាធិ  ឲ្យសម្រេចឡើងជាគតិប្រាកដបាន ។ កាលបើយោគាវចរបានត្រិះរិះគិតឃើញត្រូវដូច្នេះហើយ

ក៏ប្តេជ្ញាចិត្តទៅសុំបព្វជ្ជាជាភិក្ខុក្នុងព្រះពុទ្ធសាសនា ខំព្យាយាមសមាទាន នូវចតុប្បារិសុទ្ធិសីល មានបាតិមោក្ខសំវរសីលជាដើម ហើយតាំង រារាំងចេតនាវៀរមិនប្រព្រឹត្តនូវកាយទុច្ចរិត ៣, នូវវចីទុច្ចរិត ៤, នូវ អនេសនៈ ២១ និងនូវបាបធម៌ ៤ ជាលំដាប់តទៅ ។

កាលបើអង្គសម្មាកម្មន្ត, សម្មាវាចា និងសម្មាអាជីវៈ បាន សម្រេចកើតមានឡើងប្រាកដហើយ យោគាវចរបុគ្គលនោះ ក៏តាំងចិត្ត ឲ្យចុះសិប់ក្នុងការចំរើនកម្មដ្ឋាន ដើម្បីព្យាយាម ៖

១– បំពេញនូវបធាន ៤ មានសំវរប្បធានជាដើម ជាប្រយោជន៍ ដើម្បីនឹងលះនូវឧបក្កិលេស ១៦ មានអភិជ្ឈាវិសមលោភៈជាដើម ដែលជា កិលេសធ្វើចិត្តឲ្យសៅហ្មង និងដើម្បីបំពេញគុណធម៌ផ្សេង ៗ មានឥទ្ធិ-បាទ ៤ និងពល ៥ ជាដើម ដែលមិនទាន់កើតមានក្នុងខ្លួនសត្តានឲ្យ សម្រេចកើតមានឡើង ប្រយោជន៍ដើម្បីជាកម្លាំងសម្រាប់ទ្រទ្រង់ក្នុងការ ចំរើនកម្មដ្ឋានផ្សេង ៗ តទៅទៀត ។

២– ចំរើនសតិប្បដ្ឋាន ៤ មានកាយានុបស្សនាសតិប្បដ្ឋានជាដើម ជា ប្រយោជន៍ដើម្បីនឹងលះនីវរណៈ ៥ មានកាមច្ឆន្ទៈជាដើម ដែលជាសត្រូវ នឹងសមាធិចិត្ត ឲ្យវិនាសសាបសូន្យអស់ពីខន្ធសន្តាន ។

៣– ចំរើនឈានមានរូបជ្ឈាន ៤ ជាដើម ជាប្រយោជន៍ដើម្បីនឹងលះ រាគៈ ទោសៈ មោហៈឲ្យអស់ពីខន្ធសន្តាន ហើយញុំាងអង្គសម្មាវាយាមោ,

សម្មាសតិនិងសម្មាសមាធិឲ្យសម្រេចកើតមានប្រាកដឡើងជាលំដាប់ ។

ដើម្បីនឹងចំរើនឈានឲ្យសម្រេចនូវប្រយោជន៍បានជាក់ច្បាស់នោះ ទើបអដ្ឋសម្មាទិដ្ឋិ ដែលជាមគ្គុទ្ទេសក៍នោះ ដឹកនាំយោគាវចរឲ្យនឹកគិតឃើញត្រូវថា គប្បីចាប់ផ្ដើមចំរើនកសិណជាបឋម ឲ្យបានសម្រេចនូវអប្បនាសមាធិជាមុនសិន ពីព្រោះអប្បនាសមាធិនេះជាមូលដ្ឋានសម្រាប់ឲ្យឈានចិត្ត ៨ មានរូបជ្ឈានចិត្ត ៤ ជាដើមអាចកើតឡើងបានហើយ ពីព្រោះឈានចិត្តនីមួយ ៗ សុទ្ធតែសម្បយុត្តដោយអង្គឯកគ្គតាគឺ អប្ប-នាសមាធិនោះឯង ។

កាលបើនឹកគិតឃើញដូច្នេះហើយ ទើបយោគាវចរតាំងចិត្តព្យាយាមចំរើនកសិណ , ចំរើនឈាន នឹងចំរើនវិបស្សនាការនោះរៀងរាបដរាប លុះត្រាតែបានសម្រេចនូវអប្បនាសមាធិ , ឈានចិត្ត ៨ នឹងវិបស្សនា-ញាណ ១០ សមតាមគោលបំណងសព្វគ្រប់ដោយប្រការដូច្នេះឯង ។

រីឯលទ្ធផលដែលយោគាវចរ បានបំពេញឲ្យសម្រេចកើតមានឡើងដូចបានរៀបរាប់ខាងលើនេះជាសក្ខីភាព បញ្ជាក់សេចក្ដីឲ្យឃើញថាលោកបានចំរើនអដ្ឋង្គិកមគ្គឲ្យសម្រេចឡើងជាក់ច្បាស់ហើយ ។

ចំណែកឯគុណធម៌ដែលយោគាវចរបានចំរើន ឲ្យសម្រេចកើតមានឡើងនោះ បណ្ឌិតលោកបែងចែកជា ៣ គំនរ ហៅថាត្រៃខន្ធគឺ លោកយកសុចរិត ១០ នឹងសម្មាអាជីវៈធ្វើជាគំនរ ១ ហៅថា សីលខន្ធ, យក

សមាធិចិត្ត និងឈានចិត្ត ៨ ធ្វើជាគំនរ ១ ហៅថា សមាធិខន្ធ, ហើយយកវិបស្សនាញាណ ១០ ធ្វើជាគំនរ ១ ទៀត ហៅថា បញ្ញាខន្ធ ។

គឺត្រៃខន្ធនេះហើយ ដែលបណ្ឌិតលោកចាត់ទុកថាជាគ្រឿងសម្រាប់កំចាត់បង់នូវវិភាគាទិក្កិលេស ឲ្យវិនាសសាបសូន្យអស់ពីខន្ធសន្តានទៅបាន ជាពិតប្រាកដនោះ ។

## ៣- តើត្រៃខន្ធនេះ អាចកំចាត់បង់នូវវិភាគាទិក្កិលេសឲ្យវិនាស សាបសូន្យអស់ពីខន្ធសន្តានទៅបានដោយប្រការដូចម្តេចទៅ ?

ចំពោះរឿងនេះ ខ្ញុំសូមបញ្ជាក់ថា ៖

១- សីលខន្ធដែលប្រកបដោយសុចរិត ១០ មានកាយសុចរិត ៣ ជាដើម និងសម្មាអាជីវៈអាចការពារយោគាវចរឲ្យរួចផុតចាកវីតិក្កមទោស គឺកិលេសយ៉ាងគ្រោតគ្រាតទាំងឡាយបាន ។

២- រីឯសមាធិខន្ធ ដែលមានបរិបូណ៌ដោយសមាធិចិត្ត និងឈានចិត្ត ៨ រមែងញុំាងខន្ធសន្តានឲ្យរួចផុតចាករាគៈ និងទោសៈ ពីព្រោះឈានចិត្តដែលសម្បយុត្តដោយអង្គឧបេក្ខា និងឯកគ្គតា រមែងតែតាំងនៅជាកណ្តាល មិនអើពើ គឺមិនសោមនស្សមិនទោមនស្សចំពោះឥដ្ឋានិដ្ឋារម្មណ៍ ហើយតតាំងប្រឆាំងមិនឲ្យរាគៈ ទោសៈ ចូលមកកើតក្នុងខន្ធសន្តានបាននោះឡើយ ។

៣- ចំណែកឯបញ្ញាខន្ធ ដែលពោរពេញទៅដោយវិបស្សនាញាណ ១០ សម្រាប់បន្ថោចនូវមោហៈ និងសក្កាយទិដ្ឋិ ពីព្រោះវិបស្សនាញាណ គឺញាណដែលដឹងច្បាស់នូវដំណើរនៃសង្ខារធម៌ទៅតាមការណ៍ពិតនោះ ក៏រមែងតែប្រឆាំងរកាំងមិនឲ្យមោហៈ និងសក្កាយទិដ្ឋិ ចូលមកកើតក្នុងខន្ធសន្តានបានសោះ ដែលជាហេតុធ្វើឲ្យខន្ធសន្តាននោះរឹងហួតស្ងួតផុតចាកមោហៈ សក្កាយទិដ្ឋិ និងវិចិកិច្ឆាអស់ទៅបាន ។

លុះណាតែយោគាវចរបានប្រកបដោយត្រៃខន្ធនេះ ទើបយោគាវចរអង្គនោះមានសមត្ថភាពអាចលះសំយោជនៈ ១០ ដាច់ស្រឡះ ដើម្បីការត្រាស់ដឹងមគ្គផលនិព្វានសមដូចសេចក្តីប្រាថ្នាទៅបាន ។

នៅទីនេះ ខ្ញុំពុំធ្វើអត្ថាធិប្បាយអំពីការត្រាស់ដឹងមគ្គផលនិព្វានទេ, ខ្ញុំគ្រាន់តែលើកយកគោលធម៌ខ្លះមកបញ្ជាក់ ដើម្បីឲ្យងាយយល់នូវលក្ខណៈនៃការត្រាស់ដឹងនោះ ដូចមានសេចក្តីតទៅនេះ ៖

សំយោជនៈទាំងឡាយណា ដែលយោគាវចរលះដាច់ស្រឡះអស់ទៅហើយ, សំយោជនៈទាំងឡាយនោះ ទុកដូចជារួចផុតស្រឡះចាកខន្ធសន្តានអស់ទៅហើយ ។ មួយវិញទៀតសំយោជនៈទាំងឡាយណា ដែលរួចផុតស្រឡះចាកខន្ធសន្តានអស់ទៅហើយ សំយោជនៈទាំងឡាយនោះទុកដូចជាបានរលត់ពីខន្ធសន្តាននោះអស់ទៅហើយ ។

បើនិយមតាមទ្រឹស្តីខាងលើនេះ គេអាចសន្និដ្ឋានបានថា កិរិយាលះ

សំយោជនៈ ១០ ដាច់ស្រឡះជាសម្ដាននៃការត្រាស់ដឹងនូវមគ្គ ៤ មានសោតាបត្តិមគ្គជាដើម, ហើយកិរិយារួចផុតស្រឡះចាកសំយោជនៈ ១០ ជាសម្ដាននៃការត្រាស់ដឹងនូវផល ៤ មានសោតាបត្តិផលជាដើម, ហើយកិរិយាលះនៃសំយោជនៈ ១០ ជាសម្ដាននៃការត្រាស់ដឹងនូវនិព្វាននោះឯង ។

បើអស់លោកជាពុទ្ធបរិស័ទណាចង់ជ្រាប តើមគ្គ ៤ ផល ៤ និងនិព្វានគឺជាអ្វីនោះ ខ្ញុំសូមអញ្ជើញអស់លោកជាពុទ្ធបរិស័ទនោះអានសៀវភៅ លោកុត្តភកិសម័យ ដែលខ្ញុំបាននិពន្ធហើយបានបោះពុម្ពចែកផ្សាយជាធម្មទាននោះទៀត អស់លោកគង់នឹងបានជ្រាបអំពីរឿងនេះពុំខានឡើយ ។

៤- បើអដ្ឋង្គិកមគ្គជាបដិបត្តិធម៌ សម្រាប់ការត្រាស់ដឹងមគ្គ ផល និព្វានទេ, តើហេតុដូចម្ដេច បានជាបណ្ឌិតលោកបាត់ទុកអដ្ឋង្គិកមគ្គនោះ ថាជាទុក្ខនិរោធគាមិនីបដិបទា គឺបដិបទាអាចញុំាងកងទុក្ខឲ្យរលត់ទៅវិញ ?

បានជាបណ្ឌិតលោកចាត់ទុកអដ្ឋង្គិកមគ្គ ថាជាទុក្ខនិរោធគាមិនីបដិបទាទៅវិញ ពីព្រោះការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វានមែនជាមូលហេតុនាំឲ្យទុក្ខ ៨ រលត់ដាច់ពុំខានឡើយ ។ នៅពេលដែលទុក្ខ ៨

ត្រូវបានរលត់ហើយ ទុក្ខ ១២ កងដែលមានខន្ធ ៥ នោះជាទីតាំងនិងជាទីកើត ក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

អាស្រ័យហេតុនេះ ទើបបណ្ឌិតលោកពោលថាអដ្ឋង្គិកមគ្គជាទុក្ខ-និរោធគាមិនីបដិបទា ដោយប្រការដូច្នេះឯង ។

## ៥– តើការត្រាស់ដឹងមគ្គ ៤ ផល ៤ និងនិព្វាន ជាហេតុអាចញុំាងខន្ធ ៥ ព្រមទាំងទុក្ខ ១២ កង ឲ្យរលត់ទៅបាន ដោយប្រការដូចម្តេចទៅ ?

ដើម្បីឲ្យងាយយល់ ខ្ញុំសូមរំឭកម្តងទៀតថា ការត្រាស់ដឹងនិព្វានដែលនឹងសម្រេចឡើងបាន ក៏ព្រោះកិរិយារលត់នៃកិលេសជាមូលហេតុ, ហើយកិរិយារលត់នៃកិលេសដែលនឹងសម្រេចកើតមានឡើងបាន ក៏ព្រោះការត្រាស់ដឹងមគ្គ ៤ ផល ៤ ជាមូលហេតុ ។

សេចក្តីបញ្ជាក់នេះ នាំឲ្យសន្និដ្ឋានបានថា កិរិយារលត់នៃកិលេសនោះហើយ ដែលជាមូលហេតុមិនត្រឹមតែនាំឲ្យការត្រាស់ដឹងនិព្វានសម្រេចឡើងបានប៉ុណ្ណោះទេ, ថែមទាំងនាំឲ្យតណ្ហា, ឧបាទាន និងកម្មរលត់អស់ជាលំដាប់ទៀត ដូចមានសេចក្តីបញ្ជាក់ហេតុផលតទៅនេះ ៖

– តណ្ហា គឺសេចក្តីប្រាថ្នានូវអារម្មណ៍ ៥ មានរូបជាដើម ដែលនឹងមានដំណើរប្រព្រឹត្តទៅជាធម្មតាបាន ក៏ព្រោះមានរាគាទិកិលេសគឺ

ភៈ ទោសៈ មោហៈ ជាមូលហេតុ ។ កាលបើកតាទិក្កិលេសជាដើមហេតុរលត់អស់ទៅហើយ រីឯតណ្ហាដែលជាផលក៏ត្រូវតែរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

– ឧបាទាន ៤ មានកាមុបាទាន គឺសេចក្ដីជំពាក់ចិត្តនឹងកាមជាដើម ដែលនឹងមានដំណើរប្រព្រឹត្តទៅជាប្រក្រតីបាន ក៏ព្រោះមានតណ្ហានោះឯងជាមូលហេតុ ។ កាលបើតណ្ហារលត់អស់ទៅហើយ, រីឯឧបាទាន ៤ ដែលជាផល ក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

– កម្ម ២ ប្រការគឺ កុសលកម្ម១ នឹងអកុសលកម្ម១ ដែលនឹងកើតមានឡើងបាន ក៏ព្រោះឧបាទាន ៤ មានកាមុបាទានជាដើមនោះឯងជាមូលហេតុ ។ កាលបើឧបាទាន ៤ ជាដើមហេតុរលត់អស់ទៅហើយ, រីឯកម្ម ២ ប្រការដែលជាផល ក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

– ខន្ធ ៥ ដែលនឹងកើតមានឡើងក្នុងភពថ្មីទៀតបាន ក៏ព្រោះមានកម្ម២ប្រការជាមូលហេតុ ។ កាលបើកម្ម ២ ប្រការរលត់អស់ហើយ, រីឯខន្ធ ៥ ដែលជាផល ក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់នោះដែរ ។

រីឯទុក្ខ ១២ កងដែលនឹងកើតមានឡើងបាន ក៏ព្រោះមានខន្ធ ៥ នោះជាទីកើត កាលបើខន្ធ ៥ រលត់អស់ទៅហើយ, ទុក្ខ ១២ កងក៏ត្រូវរលត់ព្រមជាមួយគ្នាជាលំដាប់ដែរ ។

សរុបសេចក្តីទៅឃើញថា កិរិយារលត់នៃកងកិលេស ជាមូលហេតុអាចនឹងញុំាងខន្ធ ៥ ព្រមទាំងទុក្ខ ១២ កង ឲ្យរលត់ទៅបានពិតមែន តែមិនមែនឲ្យរលត់ក្នុងពេលជាបច្ចុប្បន្ននេះទេ គឺឲ្យរលត់ទៅឯអនាគត នៅពេលដែលអាយុក្ខ័យមកដល់ឯណោះ ។

អាស្រ័យហេតុនេះ ទើបនិព្វានដែលសម្រេចកើតមានឡើងដោយកិរិយារលត់នៃកិលេសនោះ ក៏ត្រូវមាន ២ ប្រការដែរគឺ ១ឧបាទិសេសនិព្វាន ១ នឹងអនុបាទិសេសនិព្វាន ១ ។

ឯឧបាទិសេសនិព្វាន គឺនិព្វានដែលសម្រេចកើតមានឡើងដោយកិរិយារលត់នៃកិលេសទុកជានិព្វានបច្ចុប្បន្ន, រីឯអនុបាទិសេសនិព្វាន គឺនិព្វានដែលសម្រេចកើតមានឡើង ដោយកិរិយារលត់ទាំងកិលេស ទាំងបញ្ចក្ខន្ធនោះទុកជានិព្វានទៅអនាគត ។

ត្រង់នេះសេចក្តីឲ្យឃើញថា កិរិយារលត់នៃកិលេសក្នុងបច្ចុប្បន្ន ជាហេតុនាំឲ្យបញ្ចក្ខន្ធ នឹងកងទុក្ខរលត់ទៅអនាគតទៀតពុំខានឡើយ ។

៦- តើបណ្ឌិតលោកយល់ឃើញដូចម្តេច ទើបលោកខំព្យាយាមបំពេញនូវអដ្ឋង្គិកមគ្គ ដើម្បីនឹងធ្វើឲ្យខន្ធ៥រលត់លែងឲ្យកើតក្នុងភពថ្មីទៀតយ៉ាងដូច្នេះ?

បើតាមយោបល់ខ្ញុំ ប្រហែលបណ្ឌិតលោកចាត់ទុកខន្ធ ៥ នោះ ជា

សេចក្តីទុក្ខសោក, សេចក្តីឈឺចាប់ក្តៅក្រហាយខ្លោចផ្សាគ្រប់បែបយ៉ាង, គ្មានសត្វណាដែលស្ថិតនៅលើត្រៃភព អាចនឹងគេចខ្លួនឲ្យរួចផុតពីទុក្ខ១២ កងនោះបានឡើយ ។ មិនតែប៉ុណ្ណោះ ពីព្រោះខន្ធ ៥ នោះ ជាអ្នកនាំមកនូវអារម្មណ៍ ៥ មានរូបជាដើម សម្រាប់លួងលោមចិត្ត ធ្វើសត្វឲ្យស្រវឹងជ្រប់នឹងកាមគុណ ៥ វង្វេងភ្លេចភ្លាំងស្មារតី ភ្លេចខ្លួនជាប់ស្អិតនៅវិលវល់ក្នុងវដ្តសង្សារ ដែលទុក្ខវេទនារកទីបំផុតគ្មានសោះឡើយ ។

អាស្រ័យហេតុនេះហើយ បានជាបណ្ឌិតលោកស្វែងរកឧបាយដើម្បីនឹងដោះខ្លួនឲ្យរួចផុតស្រឡះចាកខន្ធ ៥ នោះដោយប្រការដូច្នេះឯង ។

លំដាប់តអំពីនេះ ខ្ញុំនឹងធ្វើអត្ថាធិប្បាយបញ្ជាក់អំពីខន្ធ ៥ នឹងទោសនៃខន្ធ ៥ នោះ ដូចមានសេចក្តីតទៅនេះ ៖

ឯខន្ធ ៥ នោះគឺ ៖

១– រូបក្ខន្ធ គឺគំនររូប.– គំនររូបនេះ មានមហាភូតរូប ៤ គឺ ដី ទឹក ភ្លើង ខ្យល់ នឹងឧបាទាយរូប ២៤ មានបសាទ ៥ អារម្មណ៍ខាងក្រៅ ៥ ជាដើម ។ល។

២– វេទនាក្ខន្ធ គឺគំនរវេទនា.– គំនរវេទនា មានវេទនា ៥ គឺ សោមនស្ស ទោមនស្ស សុខ ទុក្ខ នឹងឧបេក្ខា ។ ឯវេទនាគឺចិត្តដែលសោយអារម្មណ៍ហើយដឹងថា អារម្មណ៍នោះ ៗ ជាសោមនស្ស ឬ ជាទោមនស្ស ឬ ជាសុខជាទុក្ខ ឬ ជាឧបេក្ខា ។

៣- សញ្ញាខន្ធ គឺគំនរសញ្ញា – គំនរសញ្ញានេះ មានសញ្ញា៦ គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា និងផោដ្ឋព្វសញ្ញា ។

ឯសញ្ញាគឺចិត្ត ដែលសំគាល់នូវរូប សម្លេង ក្លិន រស (សម្ផស្សប៉ះពាល់ត្រូវដោយអណ្តាត) និងផោដ្ឋព្វៈ (សម្ផស្សដែលប៉ះពាល់ត្រូវដោយកាយ) ។

៤- សង្ខារក្ខន្ធ គឺគំនរគំនិត.– គំនរគំនិតនេះ មានចេតសិក៥២ ចែកចេញជាកុសលចេតសិក ២៥ ជាអកុសលចេតសិក ១៤ និងជាអញ្ញសមានាចេតសិក ១៣ ។ ឯសង្ខារ គឺចិត្តដែលសញ្ចេតនា គឺគិតនូវការជាកុសលឬជាអកុសល តែងគិតឃើញនូវគំនិតផ្សេង ៗ ហៅថា ចេតសិកនោះឯង ។

៥- វិញ្ញាណក្ខន្ធ គឺគំនរវិញ្ញាណ.– គំនរវិញ្ញាណមានវិញ្ញាណ ៦ គឺ ចក្ខុវិញ្ញាណ ដឹងតាមភ្នែក សោតវិញ្ញាណ ដឹងតាមត្រចៀក ឃានវិញ្ញាណ ដឹងតាមច្រមុះ ជិវ្ហាវិញ្ញាណ ដឹងតាមអណ្តាត កាយវិញ្ញាណ ដឹងតាមកាយ និងមនោវិញ្ញាណ ដឹងតាមចិត្ត ។

(នៅមានត)

# ព្រះអភិធម្មបិដក

# គម្ពីរព្រះយមកៈ

លោក ម៉ុ · ម៉ុ ប្រែរៀបរៀង

(គមក)

បុរោហិតតាប្យឆ្លើយថា មហាសេដ្ឋី បពិត្រលោកជាមហាសេដ្ឋី អជ្ជ ធារកោ ហេតុដទៃកុំនិយាយចូរលើកទុកទៅចុះ និយាយតែហេតុមួយថា ទារកដែលកើតក្នុងថ្ងៃនេះនឹងបានធ្វើជាមហាសេដ្ឋី លោកចូរកំណត់ចាំទុកចុះ ។

តទា គរុគព្ភា គ្រានោះ ភរិយារបស់សេដ្ឋីនោះមានគភ៌ចាស់ជិតនឹងប្រសូតបុត្រ មហាសេដ្ឋីប្រើអ្នកបំរើឲ្យវិលទៅផ្ទះវិញឲ្យសួរថា ភរិយាប្រសូតបុត្រហើយឬនៅឡើយទេ ។ អ្នកបំរើទៅដល់ផ្ទះសួរតាមពាក្យសេដ្ឋីផ្តាំដឹងថាភរិយាមិនទាន់ប្រសូតបុត្រ ទើបត្រឡប់មកជំរាបដល់មហាសេដ្ឋី ។ ក៏ទៅគាល់ព្រះមហាក្សត្រ រួចហើយវិលមកដល់ផ្ទះវិញ ហើយប្រើបុរសឲ្យដើររកមើលទារកដែលកើតក្នុងថ្ងៃនោះ ។ ឯឃោសកទេវបុត្រច្យុតពីស្ថានសួរចុះមកកើតក្នុងគភ៌នៃស្ត្រីពេស្យា ។ នោះចិញ្ចឹមតែកូនស្រី ទើបបង្គាប់ឲ្យខ្ញុំស្រីនាំយកទារកនោះទៅបោះចោលមិនទុកចិញ្ចឹមឡើយ ។ បុរសម្នាក់មកឃើញកើតចិត្តស្រឡាញ់រើសយកទារកនោះ

ទៅចិញ្ចឹមទុកជាកូនធម៌ ៗ បុរសរបស់សេដ្ឋីដឹងថា តារកនោះកើតក្នុងថ្ងៃនោះ ទើបត្រឡប់ទៅដំរាបសេដ្ឋី ៗ ឲ្យប្រាក់មួយពាន់កហាបណៈទៅវិញយកតារកនោះមកចិញ្ចឹមទុក ៗ សេដ្ឋីគិតថា បើកូនរបស់អញកើតមកជាស្រីនឹងផ្សំផ្គុំឲ្យជាភរិយារបស់តារកនេះ បើកូនអញជាប្រុសវិញ អញនឹងសម្លាប់តារកនេះចោលចេញ គិតហើយលាក់ទុកតែក្នុងចិត្តឥតស្រដីឲ្យអ្នកណាដឹងឮផងឡើយ ៗ

៧ កន្លងពីនោះមកមិនយូរប៉ុន្មាន ភរិយារបស់សេដ្ឋីប្រសូតកូនមកជាប្រុស សេដ្ឋីក៏តាំងចិត្តប្រទូស្តរ៉ាយតារកនោះ ប្រើនាងទាសីឲ្យយកតារកទៅបោះចោលក្នុងព្រៃខ្មោច ៗល ៗ សេដ្ឋីគិតសម្លាប់តារកនេះជាច្រើនលើកណាស់ សូម្បីកូនប្រុសរបស់ខ្លួនត្រូវស្លាប់ដោយឧបាយកលរបស់ខ្លួនហើយ ក៏នៅតែមិនឈប់សម្លាប់តារកនោះដែរ ក្នុងទីបំផុតប្រើតារកនោះឲ្យនាំសំបុត្រទៅឯស្រុកសួយ ប្រាប់ឲ្យសេដ្ឋីអ្នកនាំសួយនៅស្រុកក្រៅជួយសម្លាប់តារក ៗ ប៉ុន្តែ ផ្ទុយទៅវិញ បែរជាតារកនោះបានធីតាសេដ្ឋីក្នុងជនបទធ្វើជាភរិយា ៗ មហាសេដ្ឋីគិតសម្លាប់តារកមិនស្លាប់ កើតទុក្ខតូចចិត្តណាស់ ឈឺធ្លាក់ឈាមពីមាត់ពាល់តែស្លាប់ខ្លួនឯងទៅ ៗ ឯបុគ្គលដែលរស់នៅជាមួយសត្រូវនឹងសង្ខារមិនជាទីស្រឡាញ់តែងនាំឲ្យកើតទុក្ខធំដូចជារឿងមហាសេដ្ឋីនេះឯង ៗ

ការដែលកើតមកជាសត្វជាបុគ្គលហើយ រមែងតែមានទុក្ខគ្រប់គ្នា ៗ,

បើអ្នកមានធនធានច្រើនប៉ុន្មាន ទុក្ខក៏មានច្រើនប៉ុណ្ណោះដែរ ព្រោះទុក្ខនឹងរក្សាទ្រព្យសម្បត្តិឲ្យគង់វង្សទៅកុំឲ្យអន្តរាយ ៗ លុះខូចខាតសាបសូន្យហើយ គឺជាទុក្ខក្នុងការថែរក្សាខ្លួនមិនឲ្យខាតសាបសូន្យ ៗ លុះមានព្យាធិជម្ងឺឈឺចាប់មកគ្របសង្កត់ខ្លួនហើយ ទុក្ខក៏រឹតតែកើតមានច្រើនឡើងទៀត ៗ កាលបើសេចក្ដីស្លាប់មកដល់ហើយក៏គ្មានសុខសោះ ព្រោះខ្លាចសេចក្ដីស្លាប់ជាទីបំផុត ៗ

ការនៅជាមួយសត្វនិងសង្ខារមិនជាទីស្រឡាញ់ ក៏ជាទុក្ខរហូតដល់បែកគ្នាទៅ កុំថាអ្នកដទៃ សូម្បីតែប្ដីនិងប្រពន្ធនៅជាមួយគ្នាបានសុខនោះ ព្រោះតែចិត្តស្រឡាញ់អាណិតមេត្តាគ្នាទៅវិញទៅមក ចុះបើចិត្តបែកចេញពីគ្នា គឺមិនទុកចិត្តគ្នា មិនព្រមព្រៀងគ្នាហើយ ក៏នៅជាមួយគ្នាឥតសុខឡើយ ៗ

ការព្រាត់ប្រាសបុគ្គលជាទីស្រឡាញ់ក៏ជាទុក្ខ ៗ ចិត្តប្រាថ្នាចង់បានរបស់អ្វីហើយ មិនបានសម្រេចដូចបំណងក៏ជាទុក្ខ ប៉ុន្តែ ចង់បានរបស់ដទៃ ក្រៅពីចង់បានស្រី បើមិនបានកើតទុក្ខយ៉ាងល្មមគ្រាន់អត់ទ្រាំបាន បើចង់បានស្រីហើយមិនបានវិញនោះ កើតទុក្ខធំណាស់ ទាល់តែអត់បាយក្រហាយទឹក ដូចជាព្រះបាទបសេនទិកោសល ព្រះអង្គមហេសីក៏មានព្រះស្នំក៏មានច្រើនណាស់ កាលព្រះអង្គចង់បានស្រីម្នាក់ជាប្រពន្ធរបស់គេនៅក្បែរក្រុងព្រះនគរ ក្នុងពេលស្ដេចយាងប្រទក្សិណព្រះនគរជួនជា

ពោលព្រះនេត្រទៅចំនាងនោះ ក៏ទ្រង់កើតទុក្ខដល់តែអត់ទ្រាំមិនបាន នឹងបាច់ស្រដីថ្វីដល់អ្នកឯទៀត ។

ម្យ៉ាងទៀត បញ្ចុបាទានក្ខន្ធទុក្ខនោះ សម្តេចព្រះបរមសាស្តាទ្រង់ត្រាស់ថាជាទុក្ខពិត ។ ឧបាទានក្ខន្ធទាំងប្រាំនេះជាទុក្ខ ។ ទុក្ខមួយ ៗ នឹងពណ៌នាមិនអស់ទេ គ្រាន់តែជាតិទុក្ខមួយ បើចែកចេញទៅទៀតមានច្រើនណាស់ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ក្នុងទុក្ខក្ខន្ធសូត្រមានបួនកង មានជាតិទុក្ខជាដើម មានមរណទុក្ខជាទីបំផុត ។

ក្នុងព្រះធម្មចក្កប្បវត្តនសូត្រមានទុក្ខ ៨ កង មានជាតិទុក្ខជាដើម មានឧបាទានក្ខន្ធទុក្ខជាបរិយោសាន ។ ក្នុងគម្ពីរអដ្ឋកថាដទៃ ៗ មានគម្ពីរសម្មោហវិនោទនីជាដើម ព្រះអដ្ឋកថាចារ្យសំដែងអនុលោមតាមក្រសែព្រះពុទ្ធដីកាជាច្រើនណាស់ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា ទុក្ខទាំងឡាយមានជាតិទុក្ខជាដើម សម្តេចព្រះបរមទសពលប្រទានព្រះសទ្ធម្មទេសនាថាជាទុក្ខពិត រាប់ចូលក្នុងទុក្ខអរិយសច្ច ។

ក្នុងទុក្ខសមុទយអរិយសច្ច ព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាដោយធម៌ជាទីកើតនៃទុក្ខ ជារបស់ពិតនៃព្រះអរិយ ។ បើប្រែតាមពាក្យបាលី ស-មុទយ អក្សរបួនតួនេះចែកចេញជាពីរបទគឺ សំ មួយបទ អក្សរមួយតួ, ឧទយ មួយបទអក្សរបីតួ ។ សំ ប្រែថា ព្រម, ថាក្នុងទីមួយ, ថាល្អ, ថាក្រៃលែង, ថាប្រជុំជាដើម ។ ឧទយ ប្រែថា ជាទីកើត ។

អរិយ ប្រែថា បុគ្គលប្រសើរ ព្រោះថាតាំងនៅឆ្ងាយចាកកិលេស ។ សច្ច ប្រែថា ពិតៗ រួមចូលគ្នាទាំងអស់ជា សមុច្ចយអរិយសច្ច បាន សេចក្តីថា ធម៌ជាទីកើតឡើងព្រមនៃទុក្ខ, ជាទីកើតឡើងកងទីមួយនៃទុក្ខ, ជាទីកើតឡើងដោយល្អ, ជាទីប្រជុំ, ជាទីកើតឡើងក្រៃលែងណាស់, ជាទីប្រជុំកើតនៃទុក្ខ ជារបស់បុគ្គលអ្នកប្រសើរឆ្ងាយចាកកិលេស ។ បុគ្គលអ្នកឆ្ងាយចាកកិលេសនោះ បានដល់ព្រះអរិយជាម្ចាស់ទាំងឡាយ មានសម្តេចព្រះពុទ្ធអង្គជាប្រធាន ។

ធម៌ជាទីកើតឡើងព្រមនៃទុក្ខនោះ សម្តេចព្រះបរមលោកុត្តមាចារ្យ ទ្រង់ត្រាស់ថា បានដល់តណ្ហា ។ នោះមានបីប្រការ គឺសេចក្តីប្រាថ្នាកងកាមគតហៅ កាមតណ្ហា ១ សេចក្តីប្រាថ្នាកងរូបគតហៅ ភវ-តណ្ហា ១ សេចក្តីប្រាថ្នាកងអរូបគតហៅ វិភវតណ្ហា ១ គ្រប់ជាតណ្ហាបីប្រការ តណ្ហាបីប្រការនេះ បើចាត់ដោយប្រភេទចែកចេញទៅដល់មួយរយប្រាំបីឡើងទៀត រួមជាមួយរយប្រាំបីប្រការ (១០៨) ។

តសតីតិ តណ្ហា ដែលហៅតណ្ហានោះព្រោះអត្ថថាញុំាងចិត្តឲ្យតឹតតក់ស្លុតស្ងប់ស្ងាត់មិនបាន គឺចិត្តមិនស្ងប់ ។ តណ្ហាបីប្រការនេះ ជាពួកធំ ហើយបែកខ្ញែកចេញទៅទៀតជាមួយរយប្រាំបីប្រការ នេះឯង ជាទីកើតឡើងព្រមនៃកងទុក្ខ ជារបស់ពិតនៃព្រះអរិយៈ ព្រោះថាបើតណ្ហានៅមានដរាបណា ទុក្ខក៏នៅមានដរាបនោះ ។

កាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាមភពនោះ គឺជាប្រាថ្នាក្នុងទីកើតដ៏ប្រកបដោយកាមគុណទាំងប្រាំ គឺមនុស្សនិងសួគ៌ ។ ភវតណ្ហា សេចក្ដីប្រាថ្នាក្នុងរូបភពនោះ គឺប្រាថ្នាក្នុងរូបព្រហ្មតាំងពីព្រហ្មបារិសជ្ជ ឡើងទៅរហូតដល់ជាន់អកនិដ្ឋ ។ វិភវតណ្ហា សេចក្ដីប្រាថ្នាក្នុងអរូបភពនោះ គឺប្រាថ្នាក្នុងរូបព្រហ្មទាំងបួនជាន់ៈ មានអាកាសានញ្ចាយតនព្រហ្មជាដើម ។ សេចក្ដីប្រាថ្នាក្នុងភពទាំងបី គឺ កាមភព, រូបភព, អរូបភព នេះឯងជាទីកើតឡើងព្រមនៃកងទុក្ខ មានជាតិទុក្ខជាដើម ។

មានពាក្យអធិប្បាយថា សេចក្ដីប្រាថ្នាក្នុងកាមភពដែលជាទីនាំមកនូវទុក្ខនោះ ព្រោះថាកាមទាំងឡាយប្រកបដោយទុក្ខ គ្មានសុខសោះ សមតាមព្រះពុទ្ធភាសិតថា កាមតោ ជាយតេ សោកោ សេចក្ដីសោកនឹងកើតមានឡើង រមែងកើតព្រោះកាម, កាមតោ ជាយតេ ភយំ ភ័យនឹងកើតមានឡើង រមែងកើតព្រោះកាម, កាលសេចក្ដីសោកនិងភ័យកើតមានឡើងហើយ ទុក្ខរមែងកើតមានឡើងដែរ ។

ឯសេចក្ដីប្រាថ្នាក្នុងកាមភពជាទីកើតនៃកងទុក្ខនេះ ល្មមនឹងឲ្យពិចារណាបានឃើញខ្លះ ។ ចំណែកសេចក្ដីប្រាថ្នាក្នុងរូបភពក្ដី ក្នុងអរូបភពក្ដី សុទ្ធតែជាទីកើតនៃកងទុក្ខទាំងអស់ កម្រនឹងពិចារណាឲ្យឃើញបាន នឹងឃើញថាជាទីកើតនៃកងទុក្ខដូចម្ដេច ព្រោះឃើញថាមិនបានជាទុក្ខដោយបរិភោគអាហារជាដើម ។ អ្នកប្រាជ្ញគប្បីពិចារណាឲ្យឃើញ

ថាជាទីនាំមកនូវទុក្ខទាំងអស់ ព្រោះហេតុមិនបានផុតពីទុក្ខមានជាតិទុក្ខជាដើម ។ បើបុគ្គលធ្វើការកុសលគឺរូបាវចរកុសលបានរូបាវចរឈាន លុះរលត់បញ្ចក្ខន្ធហើយ ក៏បានទៅកើតក្នុងរូបាវចរព្រហ្ម នៅក្នុងរូបាវចរភពតាមកំណត់ក្នុងរូបាវចរភពនោះ ហើយទំលាយបញ្ចក្ខន្ធក៏រមែងមកកាន់បដិសន្ធិជាតិ លុះមកចាប់បដិសន្ធិជាតិហើយ ក៏ជាហេតុនឹងឲ្យបានទុក្ខមានគព្ភោក្កន្តិកទុក្ខជាដើម ។ ឯបុគ្គលអ្នកធ្វើការកុសល គឺអរូបាវចរកុសលនោះក្ដី កាលមានឈានមិនបានសាបសូន្យអស់ជីវិតក្ស័យហើយទៅកើតក្នុងអរូបាវចរព្រហ្ម សោយសុខតែម្យ៉ាង ឥតទុក្ខ តែជាបើច្យុតពីអរូបាវ-ចរភពកាលណា ក៏ជាហេតុជាបច្ច័យឲ្យមកកាន់ជាតិ គឺបដិសន្ធិកំណើតមាននៅភពណា ទុក្ខក៏រមែងជាប់តាមទៅភពនោះ មិនបានរួចពីទុក្ខមានជាតិទុក្ខជាដើមទេ ។ ហេតុដូច្នោះ សម្ដេចព្រះមានព្រះភាគទ្រង់ត្រាស់ថា សេចក្ដីប្រាថ្នាក្នុងភពទាំងបី គឺ កាមភព, រូបភព និងអរូបភព ជាទីប្រជុំកើតឡើងនៃកងទុក្ខមានជាតិទុក្ខជាដើម ហៅថាជាទីកើតឡើងនៃទុក្ខពិត របស់ព្រះអរិយជាម្ចាស់ជាគំរប់ពីរ ឈ្មោះថាទុក្ខសមុទយអរិយសច្ចំ ត្រាស់ទេសនាក្នុងសច្ចយមក: ក្នុងគម្ពីរយមក:នេះ ។

## ទុក្ខនិរោធអរិយសច្ច

ទុក្ខនិរោធោ ទុក្ខនិរោធអរិយសច្ចំ ទុក្ខនិរោធ-

អរិយសច្ចំ ទុក្ខនិរោធោ, ទុក្ខនិរោធោ ន ទុក្ខនិរោធអរិយសច្ចំ, ទុក្ខនិរោធអរិយសច្ចំ ន ទុក្ខនិរោធោតិ ។ អាមន្តា ទុក្ខនិរោធោ ទុក្ខនិរោធអរិយសច្ចន្តិ ។

លំដាប់នេះ នឹងពណ៌នាក្នុងទុក្ខនិរោធអរិយសច្ច ដែលមានក្នុងសច្ចយមកៈតទៅ សេចក្ដីថា កតវា សម្ដេចព្រះទ្រង់ព្រះភាគអនាវរណញ្ញាណទ្រង់ព្រះនាមថា ព្រះមានព្រះភាគ ព្រោះហេតុជាទីសេពគប់នៃទេវតានិងមនុស្សទាំងឡាយ ដោយអំណាចនាំមកនូវសម្បត្តិបីប្រការដល់បុគ្គលអ្នកសេពគប់ កាលព្រះអង្គត្រាស់ទេសនាទុក្ខសមុទយអរិយសច្ចចប់ចុះហើយ ក្នុងលំដាប់នោះ ទើបទ្រង់ត្រាស់ ទុក្ខនិរោធអរិយសច្ចតទៅ មានព្រះពុទ្ធដីកាត្រាស់បុច្ឆាជាគូ ៗ ហើយត្រាស់វិសជ្ជនាជាគូ ៗ

ព្រះអង្គទ្រង់ត្រាស់បុច្ឆាថា ទុក្ខនិរោធោ ទុក្ខនិរោធអរិយសច្ចំ ការរលត់នៃទុក្ខនោះឬ ឈ្មោះថា ទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធអរិយសច្ចនោះឬ ឈ្មោះថារលត់នៃទុក្ខ ឬថាទុក្ខនិរោធនោះម្យ៉ាង ទុក្ខនិរោធអរិយសច្ចនោះម្យ៉ាង, ទុក្ខនិរោធនោះមិនមែនជាទុក្ខនិរោធអរិយសច្ច ទុក្ខនិរោធអរិយសច្ចនោះមិនមែនជាទុក្ខនិរោធទេ ឬ មានប្រការដូចម្ដេច ?

ព្រះអង្គទ្រង់ត្រាស់វិសជ្ជនាថា អាមន្តា អើ ! ទុក្ខនិរោធនោះឯង ឈ្មោះថាទុក្ខនិរោធអរិយសច្ច, ទុក្ខនិរោធអរិយសច្ចនោះឯង ឈ្មោះថា

ទុក្ខនិរោធ, ទុក្ខនិរោធ នឹងទុក្ខនិរោធអរិយសច្ចនោះដូចគ្នាតែមួយ មិនមែនផ្សេងពីគ្នាទេ ។

មានពាក្យអធិប្បាយថា ទុក្ខនិរោធ នោះប្រែថា ធម៌ជាទីរលត់នៃទុក្ខ ។ ទុក្ខនិរោធអរិយសច្ច នោះប្រែថា ធម៌ជាទីរលត់នៃទុក្ខពិតរបស់ព្រះអរិយៈ ឈ្មោះថាជារបស់ពិតនៃព្រះអរិយៈនោះ ព្រោះព្រះអរិយៈទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម រមែងត្រាស់ដឹងធម៌ដែលព្រះអរិយៈត្រាស់ដឹង ជាធម៌រលត់ទុក្ខបានពិតនោះមិនមែនដទៃឡើយ បានទឹងព្រះនិព្វាន ។ នោះរលត់ទុក្ខបានពិតមិនវិបរិតប្រែប្រួលទេ ។

និព្វានសព្ទនេះ បើប្រែសេចក្តីតាមបាលីថា ចេញចាកតណ្ហា ជាហេតុស្រោបរួបរឹត ជាហេតុឲ្យសត្វវិលវល់នៅក្នុងវដ្តសង្សារ ។ បើពោលដោយបរិយាយមានពីរប្រការគឺ សឧបាទិសេសនិព្វាន ១ អនុបាទិសេសនិព្វាន ១ ។

សឧបាទិសេសនិព្វាននោះ បានទឹងព្រះយោគាវចរកុលបុត្រក្នុងព្រះពុទ្ធសាសនានេះ មានសេចក្តីព្យាយាមចំរើនព្រះវិបស្សនា បានសម្រេចព្រះអរហត្តផលអស់អាសវកិលេសជាសមុច្ឆេទបហាន ដល់ព្រះនិព្វានគឺចេញចាកតណ្ហារលត់បានតែកិលេសនៅមិនទាន់ចូលកាន់ព្រះនិព្វានដូច្នេះ ឈ្មោះថា សឧបាទិសេសនិព្វាន សមដូចក្រសែព្រះពុទ្ធភាសិតដែលប្រ. តានព្រះធម្មទេសនាទុកក្នុងគម្ពីរឥតិវុត្តកៈថា ឥធ ភិក្ខវេ អរហំ

ហោតិ ទីណាសវោ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាព្រះខីណាស្រពអស់អាសវៈទាំងបួន គួរដល់សក្ការបូជាវិធី បាននៅចប់ហើយនូវសាសនព្រហ្មចារ្យនិងមគ្គព្រហ្មចារ្យ មានសោឡសកិច្ចធ្វើស្រេចហើយ មានភារៈគឺកិលេសដាក់ចុះហើយ មានប្រយោជន៍នៃខ្លួនគឺព្រះអរហត្តផលបានដល់ហើយ មានសំយោជនៈជាប្រការអស់ហើយ ផុតដោយបញ្ញាវិមុត្តិនិងចេតោវិមុត្តិដ៏ល្អប្រពៃ តិដ្ឋន្តិ នៅមានឥន្ទ្រិយ៍ទាំងប្រាំតាំងនៅឡើយមិនទាន់រលត់ បច្ចុប្បន្នកាលតិ សុខទុក្ខំ នៅបានសោយនូវសុខនិងទុក្ខ ។ អ្នកប្រាជ្ញគប្បីជ្រាបថា អាការដែលអស់ទៅនៃកាមរាគនិងទោសៈមោហៈនៃព្រះខីណាស្រពនេះឯង គឺថាគតហៅថា សឧបាទិសេសនិព្វាន ។

ឯអនុបាទិសេសនិព្វាននោះ មានព្រះពុទ្ធដីកាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាព្រះខីណាស្រពគួរដល់សក្ការបូជា ផុតដោយបញ្ញាវិមុត្តិនិងចេតោវិមុត្តិដ៏ប្រពៃ រលត់ជីវិតិន្ទ្រិយ៍ចូលកាន់ព្រះនិព្វានហើយ ដូច្នេះតថាគតហៅថា អនុបាទិសេសនិព្វាន ។ ព្រះនិព្វានមានពីរប្រការដូច្នេះ ។

ព្រះអមតមហានិព្វាននោះ បុគ្គលណាមួយមិនទាន់បានដល់ព្រះអរហត្តផលញាណ ដូចជាយើងគេអស់លោកអ្នកកល់គ្នាសព្វថ្ងៃនេះ

មិនបានទៅកាន់ព្រះនិព្វានទេ មិនបានឃើញព្រះនិព្វានទេ ។ ឯព្រះនិព្វាននោះ នឹងទៅដល់បានចំពោះតែអសេខបុគ្គលគឺបុគ្គលដែលបានសម្រេចព្រះអរហត្តផលមួយពួក សមដោយក្រសែព្រះពុទ្ធដីកាថា

ន ចា ឃតេចា គន្តេយ្យ អគតំ ទិសំ យាចេចា
យថាត្តជា សុខេត្តេន ខេត្តា ខេត្តេន គច្ឆតិ ។

សេចក្តីថា បុគ្គលមានខ្លួនខ្ទាន់ល្អហើយ អ្នកខ្ទាន់ហើយ គឺបានសម្រេចព្រះអរហត្តផលហើយ រមែងទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅឡើយ គឺព្រះនិព្វាន ដោយខ្លួនខ្ទាន់ល្អហើយ ដូចម្តេច បុគ្គលគប្បីទៅកាន់ទិសដែលខ្លួនមិនធ្លាប់ទៅហើយ គឺព្រះនិព្វានដោយយានទាំងឡាយនេះដូច្នោះមិនបានទេ ។

ហេតុនោះ សម្តេចព្រះគតាគតទ្រង់ត្រាស់ថា ជារបស់លោកទុក្ខបានជារបស់ព្រះអរិយៈ ។ រមែងត្រាស់ដឹង ឈ្មោះថា ទុក្ខនិរោធអរិយសច្ចជាគំរប់បីក្នុងសច្ចយមកៈនេះ ។

(នៅមានត)

## មនុរសភាហ៊ាណី

# សម្តេចព្រះធម្មលិខិត លី-ឯម ប្រែរៀបរៀង

ព្រះញាណកោសល ញាណ-ឈឹន ពិនិត្យ

(តមក)

---

ឯមនុស្សទាំងឡាយ ដល់នូវគុណព្រះរតនត្រ័យជាទីពឹងទីរលឹកពីមុន ១. លុះធ្វើមរណកាលហើយ សឹងបានទៀងទៅកើតឯស្ថានសួគ៌លោកនាយទាំងអស់ បានសោយនូវទិព្វសម្បត្តិទាំង ១០ ប្រការ ដោយផលានិសង្សនៃព្រះត្រ័យសរណគមន៍នោះហោង ។

ព្រោះហេតុដូច្នោះ ទើបព្រះអរហន្តទាំងឡាយ កាលបើបានសម្តែងរឿងនិទាននេះចប់ហើយ លោកពោលនូវបទព្រះគាថាដូច្នេះថា :

ធុរេ្ហាបិ ហាទេន ថិតកស្ស ឃរំ
កាឡិន្ទ្រេ ចាបិ មហានុភាវេ
តិលោកនាថស្ស តថាគតស្ស
មហានុភាវេ ហិ អចិន្តិយោ ។

អធិប្បាយថា គ្រាន់តែកំណាត់ឈើគីទ្រនាប់ព្រះបាទនៃព្រះសម្ពុទ្ធ ដែលប្រតិស្ឋានក្នុងវត្ថុកចេតិយ ត្រូវមហាជនអ្នកបាននូវជំនឿស្មោះស្ម័គ្រ បួងសួង តាមហេតុគួរជឿ គង់មានអានុភាពស័ក្តិសិទ្ធិដល់ម្ល៉េះ, ចំណាន់

បើ ព្រះតថាគតជាទីពឹងនៃសត្វក្នុងត្រៃភព ( កាលទ្រង់ធរមាននៅ ) ទឹង មានអានុភាពធំមិនគប្បីគិតគណនាបាន ( យ៉ាងណាទៅ )

សម្តែងរឿងនិទានបុរសអ្នកបូជាព្រះបាទបង្គំធាតុជាគំរប់បី ក្នុងវគ្គទីបី ក៏ចប់ដោយសង្ខេបតែប៉ុណ្ណោះឯង ។

x x x

## ៤– ឧត្តរសាមណេរវត្ថុ

សម្តែងរឿងនិទាន ឧត្តរសាមណេរ តទៅទៀត ដោយពាក្យបាលីថា សោ តាវ បុរិមពុទ្ធេសុ កតាធិការោ ដូច្នេះជាដើម អធិប្បាយថា មានឧត្តរសាមណេរអ្នកមានអភិនីហារកសាងសន្សំកុសល ក្នុងសំណាក់ព្រះអតីតសម្ពុទ្ធទាំងឡាយ មកជាច្រើនជាតិណាស់ហើយ, កាលដែលអន្ទោលទៅមកក្នុងសង្សារវដ្ត ហើយបានសន្សំនូវកុសលកសិ ដែលជាឧបនិស្ស័យធម៌យ៉ាងនេះ អាចផ្តាច់បង់សង្សារវដ្តចេញជ្រះស្រ-ឡះហើយសំរេចព្រះនិព្វានបានដោយពិត ។ លុះដល់មកសាសនាព្រះមានព្រះភាគទ្រង់ព្រះនាមសុមេធៈ ក៏បានច្យុតមកកើតជាវិជ្ជាធរមួយអង្គនៅអាស្រ័យក្នុងប្រទេសហិមពាន្ត ។

កាលនោះព្រះសម្មាសម្ពុទ្ធព្រះអង្គប្រាថ្នានូវទីស្ងាត់ហើយស្តេចពុទ្ធ-ដំណើរចេញទៅកាន់ប្រទេសហិមពាន្ត លុះដល់ហើយព្រះអង្គទ្រង់ផ្គត់

ព្រះវិក្ខននៃពនព្រះបាទគង់នៅក្នុងប្រទេសជាទីរហោឋាន ឥតមានមន្ទិលអ្វីឡើយ ។

កាលនោះវិជ្ជាធរនោះបានហោះចេញមកតាមអាកាសវេហាស៍ បានឃើញព្រះសម្មាសម្ពុទ្ធទ្រង់មានរស្មីទាំង ៦ ពណ៌ ដ៏រុងរឿងព្រាលអន្ទាលផ្គិនផ្ទៅគួរជាទីអស្ចារ្យពន់ពេក ហើយមានចិត្តត្រេកអរជ្រះថ្លាបានបូជាព្រះអង្គដោយផ្កាកណិការទាំងឡាយបីទងក្នុងកាលនោះឯង ។

ដោយតេជះនៃពុទ្ធានុភាព ផ្កានោះបានស្ថិតនៅពីខាងលើព្រះសិរនៃព្រះសាស្តាមានអាការដូចជាឆត្របើកបាំងថ្វាយជាអស្ចារ្យដោយកុសលចេតនាដ៏សម្បយុត្តដោយចិត្តសទ្ធារបស់វិជ្ជាធរនោះឯង ។

ឯវិជ្ជាធរនោះសោត លុះដល់កំណត់កាលអស់អាយុក្ស័យជីវិតទៅហើយ ក៏បានឡើងទៅកើតក្នុងស្ថានតាវតឹង្សទេវលោកនាយ សោយទិព្វសម្បត្តិជាសុខក្សេមក្សាន្ត អស់កាលជាយូរក្នុងស្ថានសួគ៌នោះឯង ។ គ្រាន់តែអន្ទោលទៅវិញទៅមកក្នុងស្ថានសួគ៌ទេវលោក នឹងស្ថានមនុស្សលោកទាំងឡាយជាច្រើនជាតិ, លុះដល់មកកាលពុទ្ធុប្បាទព្រះពុទ្ធជាម្ចាស់នៃយើងទាំងឡាយនេះ, ទើបវិជ្ជាធរនោះបានមកកើតជាបុត្រនៃត្រកូលព្រាហ្មណ៍មហាសាលមួយ ក្នុងនគររាជគ្រឹះ មានឈ្មោះប្រាកដជា ឆត្តកុមារ ។

ឯឆត្តកុមារនោះ ទ្រទ្រង់នូវរូបឆោមលោមពណ៌ដ៏ឧត្តមសមសួនគួរ

ជាវិស័យគន់មើលដល់ប្រជុំជន, លុះបានដល់នូវភាពជាកុមារដឹងក្តីហើយ, ក៏បានសិក្សារៀនសូត្រចំណេះវិជ្ជា ប៉ែកខាងព្រាហ្មណ៍បានសំរេចចេះចាំស្ទាត់ហើយក៏កើតជាបុគ្គល គឺមនុស្សលោកគប្បីសរសើរសំដៅសីលនឹងមារយាទល្អដោយអំណាចចំណេះវិជ្ជា ដែលចេះដឹងដ៏សមគួរដល់ជាតិដោយពិត ។

កាលនោះ វស្សការព្រាហ្មណ៍ជាមហាមាត្យក្នុងនគររាជគ្រឹះ បានឃើញនូវបញ្ញាសម្បត្តិនិងរូបសម្បត្តិរបស់ទត្តកុមារហើយ មានសេចក្តីប្រាថ្នាចង់ឲ្យធីតារបស់ខ្លួនធ្វើជាភរិយានៃទត្តកុមារនោះ ទាំងបានចាត់មនុស្សទៅឲ្យដំណឹងដល់ព្រាហ្មណ៍ ជាមាតាបិតារបស់ទត្តកុមារនោះផង ដោយសមគួរតាមសេចក្តីប្រាថ្នារបស់ខ្លួន ។

ឯទត្តកុមារក៏បានឃាត់នូវដំណឹងនោះ ព្រោះខ្លួនមានអធ្យាស្រ័យចង់រលាស់ចេញចាកគេហ កុមារតែងចូលទៅអង្គុយក្នុងសំណាក់នៃព្រះសារីបុត្តត្ថេរ ដើម្បីស្តាប់ធម៌ទេសនាអស់កាលទាំងពួង, លុះបានស្តាប់ធម៌ទេសនាហើយ ក៏មានសទ្ធាកើតឡើងចំពោះខ្លួន ទើបលាមាតាបិតាចេញទៅបួសក្នុងសំណាក់ព្រះសារីបុត្តត្ថេរនោះឯង ។

លុះទត្តកុមារបានបព្វជ្ជាជាសាមណេរហើយ សឹងបរិបូណ៌ដោយវត្តប្រតិបត្តិល្អ ជាបុគ្គលប្រដៅងាយ តែងបម្រើព្រះថេរៈដោយសេចក្តីគោរព ។

សម័យមួយ ព្រះមហាសារីបុត្តត្ថេរមានអាពាធឈឺចាប់ចុកសៀត

កើតឡើងជាទម្ងន់ ។ ឯឧត្តរសាមណេរនោះកាលបើដល់វេលាព្រឹកហើយ ក៏កាន់យកបាត្រចីវរចេញពីវត្តទៅ ដើម្បីនឹងបិណ្ឌបាតភេសជ្ជៈប្រគេនព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍របស់ខ្លួន, ស្រាប់តែដល់ពាក់កណ្ដាលផ្លូវ ក៏ដំកល់បាត្រចុះទៀបឆ្នេរស្រះមួយ ហើយចុះទៅក្បង់ទឹកមកលុបលាងមុខ។

កាលនោះ មានចោរម្នាក់វាជីកទំលាយនូវឧម្មង្គលួចយកបន្ទិចកែវទាំង ៧ ប្រការក្នុងសំណាក់ស្ដេចហើយរត់ទៅ ។ ពួកមនុស្សអ្នករក្សា គេបានដឹងហើយក៏នាំគ្នាដេញតាមជាប់ប្រកិតនូវចោរនោះ ឯចោរក៏វាគេចចេញអំពីចំណោមទៅតាមទ្វារដែលចំហដោយរហ័ស ។ លុះបានដល់ស្រះនោះហើយ វាយកបន្ទិចកែវទាំង ៧ ដាក់ចុះក្នុងបាត្ររបស់ឧត្តរសាមណេរ ហើយរត់បាត់ទៅ ។

ចំណែកឯសាមណេរ កាលបើបានលុបមុខរួចហើយ ក៏ត្រឡប់ឡើងពីស្រះមកវិញដើរចូលទៅរកបាត្ររបស់ខ្លួនក្នុងវេលានោះឯង ។ ស្រាប់តែរាជបុរសអ្នកដេញតាមចោរក៏ទៅដល់ទីនោះដែរ ហើយបានឃើញបន្ទិចកែវទាំង ៧ ប្រការនៅក្នុងបាត្ររបស់ឧត្តរសាមណេរក៏គិតថា សាមណេរនេះប្រាកដជាចោរពិត អំពើចោរកម្មគឺសាមណេរនេះធ្វើហើយដោយខ្លួនឯងមែន ។ លុះរាជបុរសទាំងឡាយគិតយ៉ាងនេះហើយ ក៏ប្រូតគ្នាចាប់សាមណេរនោះចងសេក គឺចងឲ្យមានដៃមកខាងក្រោយ ហើយនាំយកទៅប្ដឹងចំពោះវស្សការព្រាហ្មណ៍ក្នុងកាលនោះឯង ។

កាលនោះ វស្សការព្រាហ្មណ៍មានឋានៈជាអ្នកវិនិច្ឆ័យ អាចបង្គាប់បញ្ជាឲ្យកាត់ដៃកាត់ជើងពុះបំបែកក្បាល ឬទំលាយអវៈយវតូចធំតាមទោសានុទោសបានឥតមានទើសទាល់ឡើយ ។

កាលបើវស្សការព្រាហ្មណ៍បានឃើញទុគ្គតសាមណេរនោះហើយ ក៏ស្គាល់ជាក់ថា ទុគ្គតសាមណេរនេះ កាលនៅជាកុមារនៅឡើយ ពុំបានអើពើទទួលស្ដាប់តាមពាក្យរបស់អាត្មា ហើយចេញទៅបួសក្នុងព្រះពុទ្ធសាសនា ការបួសដោយសទ្ធាដូច្នេះ ទុកដូចជាជាប់អន្ទាក់នឹងដកឃ្លាពុំរួចឡើយ ។ ដែលវស្សការព្រាហ្មណ៍គិតយ៉ាងនេះ ព្រោះតែសេចក្ដីគំនុំគំគួនចងអាឃាដរបស់ខ្លួនពីមុនយ៉ាងនោះឯង គាត់ពុំបានពិចារណានូវអំពើទោសានុទោសនោះឡើយ, ស្រាប់តែបង្គាប់រាជបុរសទាំងឡាយថា: អ្នកទាំងឡាយត្រូវយកសាមណេរនេះទាំងរស់ទៅធ្វើទោសឲ្យដេកផ្ការលើដែកស្រួច "គឺឈើអណ្ដាត" ឲ្យក្សីណក្ស័យជីវិតទៅហោង ។ រាជបុរសទាំងឡាយបានស្ដាប់ហើយ ក៏ចងបណ្ដើរទុគ្គតសាមណេរនោះនាំយកទៅឲ្យដេកផ្ការលើឈើអណ្ដាតតាមបង្គាប់មហាមាត្យនោះឯង ។

ចំណែកឯទុគ្គតសាមណេរបានអង្គុយលើឈើអណ្ដាតនោះហើយ ក៏ពុំបានគិតអំពីសេចក្ដីទុក្ខរបស់ខ្លួនឡើយ គិតនឹកតែព្រះសារីបុត្តត្ថេរជាព្រះឧបជ្ឈាយ៍ថា: អ្នកណាហ្ន៎! អាចនឹងនាំយកភេសជ្ជៈមកប្រគេនព្រះឧបជ្ឈាយ៍របស់អាត្មាអញបាន ។

លំដាប់នោះព្រះមហាសារីបុត្តថេរ បានជ្រាបហេតុនោះហើយក៏នាំយកសេចក្តីនុះទៅក្រាបបង្គំទូលចំពោះព្រះសម្មាសម្ពុទ្ធជាម្ចាស់ សូមទ្រង់ជ្រាបក្នុងកាលនោះ ៗ លុះព្រះមានព្រះភាគបានជ្រាបហើយ ក៏នាំយកសាវកទាំងឡាយជាច្រើន តាមហែព្រះអង្គក៏បានរំពឹងមើលប្រាជ្ញាចាស់ក្នុងដោយជុំវិញរបស់ទុគ្គតសាមណេរនោះ បានជ្រាបសព្វគ្រប់ហើយទ្រង់ស្រូតរូតព្រះដំណើរយាងទៅដល់ទីនោះឯង ៗ

កាលនោះ អ្នកនគរទាំងអស់បានដឹងថា ព្រះមានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃជាសាវកនិមន្តចេញទៅហើយ ក៏បបួលគ្នាចូលទៅប្រជុំព្រមក្នុងកាលនោះឯង ៗ

ឯព្រះមានព្រះភាគ ទ្រង់យកព្រះហស្តខាងស្តាំដែលមានព្រះអង្គុលីដ៏ទន់ល្វន់ល្មោស មានបណ្តាញរស្មីផ្សាយចេញអំពីផ្ទៃព្រះហស្ត ទាំងមានពន្លឺហូរចេញមកតែនពន់ដូចជាវង់កន្ទុយក្អែក ពុំនោះសោតមានពណ៌ដូចទឹកជាតិហិង្គុល នឹងទឹកមាស មកដាក់លើសិរសានៃទុគ្គតសាមណេរ ព្រះអង្គស្ទាបអង្អែលសិរសារួចហើយទ្រង់ត្រាស់ថា ម្នាលទុគ្គតសាមណេរ ផលនៃសេចក្តីទុក្ខដែលកើតឡើងដល់អ្នកនាបច្ចុប្បន្ននេះជាផលនៃបាបកម្ម ដែលអ្នកបានធ្វើពីបុព្វជាតិមកហើយនោះ ត្រូវតែអ្នកខំទ្រាំអត់សេចក្តីទុក្ខវេទនាដោយកំឡាំងបច្ចវេក្ខណញ្ញាណ គឺប្រាជ្ញដែលពិចារណាឃើញជាក់ច្បាស់ក្នុងអំពើបាបកម្មនោះឯង ៗ

(នៅមានត)

# មហោសថជាតក

លោក អ៊ឹម-គង ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះគ្រូវង្ស គឹម-ទូរ ពិនិត្យ

(តមក)

ពោធិសត្វប្រើទៅថា ត្នងទាំងឡាយ ឲ្យតែងនូវសភាពអាការ នាយេីងហើយត្នងមកហោង ៗ រីយោធាទាំងអម្បាលនោះ ទទួលយកនូវពាក្យទៅមហោសថអ្នកប្រាជ្ញហើយថា ពីកេះ ៗ ពេក, យោធាទាំងនោះសំពះហើយ ក្រាបលាព្រះមហាសត្វ នាំយកនូវពត៌មាន កាលណា យកទៅនូវគ្រឿងសាស្ត្រាវុធគេចចេញទៅហោង, កាលនោះ យោធាទាំងឡាយទៅនាឋាននោះ នាំគ្នាចូលទៅក្នុងឧទ្យាន ដ៏អ្នកប្រដាប់ដូចនន្ទឧទ្យាន យល់ឥស្សូរសម្បត្តិលោកប្រដាប់សំរាប់ទុកនូវរាជអាសនាស្តេចមួយរយទីងមួយនោះ មានរាជអាសនាស្តេចចុលនីជាដើម ដ៏ប៉ាំងត្រសាក់ទៅនូវស្វេតច្ឆ័ត្ររ័តន៍មាលា ឲ្យយោធាអម្បាលនោះធ្វើអស់ប្រការទាំងពួង ដូចនិយាយពីព្រះមហាសត្វនោះហោង , យោធាទាំងនោះ កញ្ជ្រោកបង្កជាដំណោះប្រកែកដៃគ្នា នឹងមហាជនផងទាំងឡាយ ហើយរត់ឆ្ពោះមកកាន់មិថិលានគរវិញ ៗ ចំណែកអាមាត្យស្តេចចុលនី ក៏រត់ទៅទូលពត៌មានស្តេចទាំងឡាយនោះ ៗ

ចុលនីព្រហ្មទត្តោ ឯវំរូបស្ស ញាម មេ វិសយោ តស្ស អត្ថកាយោ កាតោតិ កុជ្ឈិ ។ រីព្រះបាទចុលនីព្រហ្មទត្តរាជ ស្តេចខ្ញាល់ថា ចៅមហោសថនេះ វាធ្វើឲ្យអន្តរាយនូវស្រាផល់ប្រាំពិសនៃអញនេះ នាថ៎ហៅមានសភាពបង្គួរដូច្នេះហោង ៗ ឯស្តេចទាំងឡាយដទៃខ្ញាល់ថា រឺមហោសថ វាមិនឲ្យអស់អញផឹកស្រាជ័យនេះបានឡើយ ៗ រីអស់ពពួកពលយោធាសេនាផងទាំងឡាយសឹងខឹងថា ឱ ! យើងអើយ ! មិនបានផឹកស្រាជ័យ មានដំឡៃប្រសើរនេះឡើយ ៗ ម្នោះហើយព្រះបាទចុលនីព្រហ្មទត្តរាជ ស្តេចស្រដីនឹងស្តេចផងទាំងឡាយថា ភោ ម្នាលអ្នកទាំងឡាយអើយ ! ចូរគ្នាយើងទាំងឡាយទៅម៉ិថិលានគរនាយ យើងនឹងកាត់កយកក្បាលស្តេចវិទេហរាជនឹងព្រះខាន់ យើងនឹងពែនជើងទំនេងនឹងអង្គុយលើ ហើយផឹកស្រាជ័យបាន, តុម្ហេ រីអ្នកចូររណ្តាប់ឆាប់ ៗ នូវសេនាយោធាផង យើងនឹងទៅហោង, រីស្តេចចុលនីលីលាទៅឋានស្នាក់ គាប់ចិត្តគិតសំដែងប្រាប់នូវកាថប្រស្នាការគំនិតនោះ នឹងអាចារ្យកេវដ្តព្រាហ្មណ៍ដូច្នេះថា មហោសថ គាត់ធ្វើឲ្យអន្តរាយនៃគំនិតយើង មានសភាពបង្គួរដូច្នេះនេះ យើងនឹងទៅចាប់វាជាសត្រូវនោះមកហោង, ស្តេចបន្ទូលថា ហៃអាចារ្យអើយ ! ចូរមកយើងនឹងទៅមួយអន្លើដោយស្តេចមួយរយនឹងមួយ នូវពពួកពលសកលយោធាផងទាំងឡាយ ១៨ អក្ខោភិនីជាបរិវារ ៗ រីអាចារ្យ

កេវដ្ដព្រាហ្មណ៍រំពឹងគិតសភាពនាអាត្មាឯងជាអ្នកប្រាជ្ញ ក៏នឹងអាចដើម្បី
ទៅនឹងឈ្នះចៅមហោសថអ្នកប្រាជ្ញនោះគ្មានៈឡើយ ហើយយើងនឹង
ក្រឡាប់វិលមកកាន់នគរយើងនេះ គួរគប្បីខ្លាចស្ដេចទាំងឡាយនោះ
គាត់ហោង ៗ លំដាប់នោះ, អាចារ្យកេវដ្ដព្រាហ្មណ៍ទូលស្ដេចនូវ
ពាក្យដូច្នេះថា មហារាជ បពិត្រមហារាជអើយ! រីស្ដេចវិទេហរាជ គេ
មានកំឡាំងនឹងស្ដេចទាំងឡាយច្រើន, មហោសថនេះគាត់ចេះតាក់តែង
គ្រប់ប្រការ ឯចម្បាំងនោះមហិមាក្រៃគតប៉ុះឡើយ ហើយគាត់មានអា-
នុភាពនោះច្រើន នាព្រះមហោសថគាត់តែងរក្សាក្រុងមិថិលានគរ ដូច
រាជសីហ៍ចាំរក្សាគូហា យើងពុំអាចដើម្បីនឹងយកដោយនូវប្រការម្ដេចនឹង
បាន; រីអាចារ្យកេវដ្ដព្រាហ្មណ៍ទូលថា រីយើងខ្ញុំខ្លាចស្ដេចទាំង
ឡាយ, រីដំណើរអ្នកនឹងទៅនាមិថិលានគរនោះមិនគួរគាត់ហោង, រីអា-
ចារ្យកេវដ្ដព្រាហ្មណ៍ថាដូច្នេះ ៗ មួយនិសោត រីស្ដេចមានចិត្តរឹងត្អឹង
ដោយជាក្សត្រាធិរាជ ហើយប្រហែលពឹងតែឥស្សរសម្បត្តិគាត់, អញ
នឹងធ្វើម្ដេច អញនឹងធ្វើស្ដេចនេះឲ្យក្រឡាប់វិលមកបានដោយនូវប្រការ
ដូចម្ដេច ? ឯស្ដេចចេញទៅនូវស្ដេចមួយរយនឹងមួយជាបរិពារ មួយ
អន្ទើនឹងពពួកសេនាយោធាទាំងឡាយ ១៨ អក្ខោភិនី ៗ សូម្បីអាចារ្យ
កេវដ្ដព្រាហ្មណ៍ដឹងថាស្ដេចនោះ ពុំអាចដើម្បីនឹងយកពាក្យអាត្មាបាន
ឡើយ, អាចារ្យវដ្ដព្រាហ្មណ៍ថា នាប៉ះហៅនឹងទាស់ស្ដេចនោះមិនគួរ

ឡើយ, អាចារ្យកេវដ្តព្រាហ្មណ៍គិតដូច្នោះហើយ ក៏ចេញទៅមួយអន្លើនឹងស្ដេចហោង ។ រីយោធាព្រះមហាសត្វទាំងអម្បាលនោះ មកតែមួយពាក្រើដល់មិថិលានគរ ក៏សំដែងប្រាប់ទៅមហោសថនូវកិច្ចដែលអាត្មាបានធ្វើនោះហើយ ។ ឯបុរស ៤ បនិក្ខត្តពោធិសត្វនោះប្រើពតិមានមកប្រាប់មុនដូច្នេះថា រីស្ដេចចុលនីព្រហ្មទត្តរាជ នឹងមកចាប់ព្រះបាទវិទេហរាជ, ព្រះបាទចុលនីព្រហ្មទត្តរាជមកនោះ មានស្ដេចមួយរយនឹងមួយជាបរិវារមានប្រការដូច្នេះ បណ្ឌិតអើយ ! សូមអម្ចាស់កុំថីប្រហែសឡើយ ឥឡូវនេះ លោកមកដល់ឋានមានឈ្មោះដូច្នេះ ៗ លោកនឹងមកដល់ឥឡូវនេះហើយ រីបុរសជា ៤ បនិក្ខត្តពោធិសត្វនោះប្រើពតិមានមកពុំដែលដាច់ឡើយ ។

តំ សុត្វា មហាសត្តោ អប្បមត្តកោ អហោសិ ៗ ព្រះមហាសត្វអ្នកឮពតិមាននោះហើយ អ្នកឲ្យរណ្ដាប់សំរាប់មិនប្រហែសឡើយ ។ រីស្ដេចវិទេហរាជ ឮស្ដេចចុលនីព្រហ្មទត្តរាជ មកនឹងចាប់យកនគរយើងនេះក្ដី ឮស័ព្ទនោះដំណារៀងទៅដល់ស្ដេចចុលនីព្រហ្មទត្តរាជ ។ លំដាប់នោះ, ស្ដេចចុលនីព្រហ្មទត្តរាជ ជាអ្នកប្រមូស្ដក្រៃស្ដេចលើកទ័ពគត់សំរុកមកដល់ទាំងយប់ ស្ដេចឲ្យកាន់នូវភ្លើងគប់ចន្លុះទាំងឡាយមួយសែន ជាបរិវារហោមរោមជុំអស់ទាំងនគរនោះ ឥតចន្លោះដំលវ៉ែ្ងកដល់តិចឡើយ ។ លំដាប់នោះ, ស្ដេចចុលនីមកហោមស្ដេច ឲ្យ-

រៀបដំរីជាបន្ទាយ, រៀបសេះជាបន្ទាយ, រៀបរទេះជាបន្ទាយ ដាក់ទុកពលជាជំពូកច្បាំងហាននោះហើយ ។ រីមនុស្សដែលស្រែកកងឡើង អ្នកខ្លះទះដៃហៅ ខ្លះស្រែកគំរាមហើយប៉ះទៅ ។ រីពន្លឺព្រះអាទិត្យ ក្លើងគប់នោះប្រដាប់នោះក្តីអស់ទាំងកំឡុងមិថិលានគរ ៧ យោជន៍ ក្តីជាពន្លឺមួយទើទៅហោង ។ រីសត្វទាំងឡាយដំរីគេប គឺសត្វដំរី សត្វសេះ សត្វរទេះ សត្វក្បូរត្រីកីលាន់ពួកដែរពងកក្រើកទាំងផ្ទៃក្រោម ។ ចត្តារោ បណ្ឌិតា ឧល្លោលសទ្ទំ សុត្វា អជានន្តា វេញោ សទ្ទិ-តាំ តត្វា មហារាជ មហាគ្គោ ឧល្លោលសគ្គោ ឯ ទោ បឯ ជានាម តាត្ថាមេតំ វីមិសិតុំ វត្តិ មហារាជាតិ អាហំសុ ។ រីអ្នកប្រាជ្ញទាំង ៤ ព្ធទូវសត្វរចល់រលំឡើង មិនដឹងជាសត្វអ្វី ក៏ទៅកាន់សំណាក់ស្តេចទូលថា មហារាជ បពិត្រមហារាជអើយ ! បឯ មួយទីសោត ឯ ទោ ដូចអញខ្ញុំគិតនេះ, រីសត្វរចល់រលំឡើងនោះ យើងខ្ញុំមិនដឹងហៅអ្វីមកលងយើង ។ ស្តេចស្តាប់នូវពាក្យអាចារ្យទាំង ៤ ហើយ មានបន្ទូលដូច្នេះថា ឯ ទោ ដូចអញគិតហើយ, រីស្តេចចុលនីសមភាតមកហើយហោង, ស្តេចបន្ទូលអម្បាលនោះហើយ ស្តេចបើកសីហបញ្ជរកែវបវរប្រសើរ ទតមើលមើលដឹងជាស្តេចចុលនីមកដល់ហើយ មានព្រះទ័យភិតភ្លាចបន្ទូលថា ឱ ! ជីវិតយើងនឹងគ្មានហើយ, ហើយបន្ទូលទៀតថា ឥឡូវនេះ អស់យើងទាំងអម្បាលនេះក៏នឹង

លុះក្ស័យជីវិតនោះ នាំស្អកឯងហោង, ស្តេចបន្ទូលមួយអន្ទើខឹងអ្នកចាំង ៤ នោះហើយ ស្តេចគង់នៅហោង ៗ បង្ក មួយនីសោក ព្រះមហា- សត្វ អ្នកដឹងនូវស្តេចចូលទីព្រហ្មទត្តកដគាត់មកដល់ហើយ ពោធិសត្វ អ្នកឥតភ័ក្កខ្លាចនូវអំណាចព្រះបាទចុលនីនោះដល់តិចឡើយ, សីហោ- រិយ នរនាថគគាតដូចរាជសីហ៍ចេញពីគុហា អ្នកចាំរក្សាព្យាបាលអស់ ចាំងនគរនោះ, ហើយពោធិសត្វអ្នករំពឹងគិតថា អញខឹងទៅលួងលោម ស្តេច, ហើយអញឡើងទៅលើកដមម្ងរ សំពះស្តេច ហើយបិតនៅ ឮដំហានមួយហោង ៗ រីស្តេចវិទេហរាជយល់ព្រះពោធិសត្វហើយ មាន ដង្ហើមចេញចូលសប្បាយពេកពយមានបន្ទូលថា រីអញនេះ បើវៀរចង់ ខឹងព្រះមហោសថជាកូននៃអញហើយ គេនឹងមានអ្នកឯណាដទៃ នាបី ហៅអាចដោះអញបានអំពីទុក្ខដ៏ពន្ទឹកនេះ, ឧត្តិ គ្មានឡើយ, ហើយ ស្តេចបន្ទូលខឹងពោធិសត្វនូវគាថាជាបឋម, ក្នុងមស្មិ មហាឧម្មគ្គ- ជាតកោ មានក្នុងមហាឧម្មគ្គជាតកថា ៖

បញ្ចាលោ សព្វសេនាយ ព្រហ្មទត្តោ សមាគតោ
សាយ បញ្ចាលិយា សេនា អប្បមេយ្យា មហោសធ ៗ
វិទ្ធិមតី បត្តិមតី សព្វសង្គាមកោវិទា
ឱហារិនី សទ្ទវតី ភេរិសង្ខប្បពោធនា ៗ
លោហវិជ្ជា អលង្ការា ធជិនី វាមរោហិនី

សព្វេយេវ សុសម្បន្នា សុវេវា សុបតិដ្ឋិតា ។
ឧសភេ បណ្ឌិតា អាហុ គរុបញ្ញា វេហាគតា
មាតា បិតាឧសី វេញ្ញា បញ្ចាលិយេ បសាសតិ ។
អដ្ឋេក្កេកសតំ ១ញ្ញា អនុយន្តា យសស្សិនោ
អច្ឆិន្នរដ្ឋា ព្យថិតា បញ្ចាលីនំ វសំ គតា ។
យំ វទា តក្ករ វេញ្ញោ អកាម បិយភាណិនោ
បញ្ចាលមនុយាយន្តិ អកាមា វសិនោ គតា
តាយ សេនាយ មិថិលា តិសន្ធិ បរិវារិតា
ភជធានី វិទេហានំ សមន្តា បរិខញ្ញតិ ។
ឧទ្ធំ តារកជាតាវ សមន្តា បរិវារិតា
មហោសធ វិជានាហិ កថំ មោក្ខោ ភវិស្សតិតិ ។

ថៃហៅមហោសថអ្នកប្រាជ្ញអើយ ! ឥឡូវនេះ ព្រះបាទចុលនីព្រហ្ម-
ទត្តរាជ ជាអម្ចាស់នៃអ្នកបញ្ចាលរាស្ត្រ លើកពលពាលទាំងក្រឡា-
មហាប្រថពី សឹងតែហាក់ទក្សា សេនាយោធាពលហានទាំង ១៨ អក្ខោភិនី
សឹងមានកំឡាំងមហិមាក្រៃពេក, រីសេនាយោធានោះសោត គិតជាអ្នក
ប្រដាប់ខ្លួនទៅនូវគ្រឿងសាស្ត្រាវុធមុតថ្លា គឺជាធន់ផងរណ្តាប់ដោយនូវប្រាជ្ញា
ទាំង ១, រីសេនាថ្មើរជើងនោះសោត សឹងឈ្មោះនូវការសង្គ្រាមទាំងពួង
មានកំឡាំងនៀបនាចដូចខ្យល់ នោះទឹងស្វះទៅចាំង ទីងកំងកប្រក់

ចាប់បានអាវុធរត់ចូលទៅកណ្ដាលសត្រូវ  កាត់កយកក្បាលសត្រូវនាំ
ចេញមក ក៏ពុំឲ្យសត្រូវនោះដឹងខ្លួន, ពោះនឹងចេញចាំងក្ដី ចូលច្បាំងក្ដី
សឹងដ៏ប្រៀនស្ទាត់ប្រយ័ត្ន សឹងស្ដាប់ស័ព្ទ នូវសូរគេពុំព្រួយស្រដី ស្ដាប់
តែស័ព្ទនោះ ជាសំគាល់អស់សេនាទាំងអម្បាលនោះហោង, ហៃហៅ
មហោសថអើយ ! រីគ្រឿងប្រដាប់សេនាផង គឺជាងដែកប្រដាប់ក្រោះ
ក្រាយ នូវមួកជាត់ជាយសេលោផង សឹងតែរចនាដោយនូវរតន៍ទាំង ៧
រុងរឿងល្អប្រពៃ, ហើយប្រដាប់នីទៅនូវទង់ជ័យមាស ទង់ជ័យប្រាក់
គិតជ៏អ្នកឡើងចងលើចន្ទោលកដរថ, រីសេនាសេះសោត សឹងតែរបៀន
ខ្វែនស្ទាត់ប្រយ័ត្ននូវចម្បាំង, ពោះយោបីនឹងស្ទុះឡើងលើខ្នងសេះសោត
សឹងលោតឡើងខានស្ដាំ.ឆ្វេង ពុំជាន់ឈ្នាន់ក៏សឹងបាន ហើយមានប្រាជ្ញ
ចេះសិល្ប៍ទាំង ១៨ ប្រការ គឺ: សិល្ប៍ដំរី សិល្ប៍សេះជាដើម សឹង
ចេះមន្ដមាយាទាំងពួងសព្វគ្រប់ហោង, ហៃហៅមហោសថអើយ ! រីស្ដេច
មួយរយដ៏មួយ សឹងមាននូវសេនាយោធាផងច្រើន តែងក្រវែចប់រើ
ហៃនៃស្ដេចចុលនីព្រហ្មទត្ត បើគាត់នឹងប្រើធ្វើការអ្វី ១ ក្ដី អស់ស្ដេច
ទាំងនោះបើទុកជាពុំមានចំណង់ក្ដី ក៏លុះនូវអំណាចគាត់ហោង, មួយ
នីសោតស្ដេចចុលនីព្រហ្មទត្តកដ គាត់មានបុត្រព្រះបាទរមអានុភាពមហិមា
ប្រកបនូវប្រាជ្ញាឈ្លាសវៃដឹងអស់ហានចម្បាំង ប្រកបនូវកំឡាំងមហិមា
ប្រដាប់អាត្មាពាក់នូវចណ្ដាញក្រោះដែកញញាន់ប្រពៃ, ប្រដាប់នូវទង់ជ័យ

ស្តេចបុត្រប្រកិតឆ្វេង-ស្តាំ លលាំចូលមកពោមពេមមិថិលា ៣ជាន់ ប្រកិត
នូវគ្រឿងអាវុធគ្រប់ដៃ កងចំណោមដំរី ចំណោមសេះ ចំណោមរទេះផង
ស័ព្ទរំពងដូចជានឹងក្លក់ប្រថពីស្រុកមិថិលាបុរីនេះយើងឡើអប្បកជ័យ នឹងមិន
គង់ជីវិតរស់រួចអំពីភ័យម្តងនេះទេ, ហៃលោកមហោសថអើយ ! រសេនាយោ-
ធាផងគេចោមជុំវិញ សឹងតែមានដៃកាន់នូវគប់ភ្លើងភ្លឺប្រុសត្វគ្នាក្រៃលែង
សែនសល់ យល់ភ្លឺរោះព្រោងព្រាយដូចផ្កាយនាកណ្តាលអាកាសពាស
ពាំងប្រថពី; ហៃលោកមហោសថបុត្រសំឡាញ់ពេញចិត្តអាពុកអើយ ! អ្នក
គិតដូចម្តេចក៏នឹងឲ្យបានរួចអំពីភ័យសត្រូវនេះបាន; ហៃលោកមហោសថ
បុត្រសំឡាញ់អាពុកអើយ ! រស្តេចចុលនីនោះ, តាកិរ ដូចយើងបានឮមក
ថា ធស បណ្ឌិតា មានអ្នកប្រាជ្ញ ១០ នាក់ ក្ឫរបញ្ញា មាន
ប្រាជ្ញាដូចផែនដី, រីមាតានៃស្តេចបញ្ចាលមានប្រាជ្ញា តែងប្រដៅស្តេច
នោះ, ឯកាទសី ជា ១១ នាក់, រីអ្នកប្រាជ្ញទាំងអម្បាលនោះ គោះ
យោបល់អង្គុយនាបានស្ទាត់ គិតតែ២ថ្ងៃ ៣ថ្ងៃ, គោះនឹងប្រែប្រថពីនោះ
ក៏សឹងបានហោង, ហៃលោកមហោសថអើយ ! នឹងមានអ្នកដទៃឯណា
មួយមានប្រាជ្ញាយល់ស្មើបា ឯក្រោមដកបដល់អវិចិនរក ឯលើដកបដល់
អកនិដ្ឋព្រហ្ម នាបហៅជាអ្នកប្រាជ្ញនឹងឈ្លាសនូវកលឧបាយនោះស្មើ
បាបាន, ឯក្តិ គ្មានឡើយ, បណ្ឌិតភាគោ ជាម នាបហៅ
ជាអ្នកប្រាជ្ញ យល់ប្រាកដនូវប្រាជ្ញាមានសភាពដូច្នេះ ៗ ស្តេច

បន្ទូលថា ហេតុនោះហោង យើងនឹងធ្វើឲ្យរួចបានដោយប្រការម្តេច? ។

ពោធិសត្វអ្នកស្តាប់ព្រះបន្ទូលព្រះមហាក្សត្រដូច្នេះហើយ អ្នកគិតថា ស្តេចនេះភិតខ្លាចភ័យនឹងស្លាប់នោះក្រៃពេក បង មួយនិសោក ងទោ គឺដោយនូវពិត, ពេទ្យផងទាំងឡាយ តែងជាពំនាក់នៃអ្នកដ៏មានជម្ងឺព្យាធិ សូម្បីភោជនាហារក្រកាលពិសា តែងជាពំនាក់នៃអ្នកឃ្លាន, រីទឹកសោត ជាពំនាក់នៃអ្នកផង, ធម្មស្សាបិ រញ្ញោ មំ ឋបេត្វា អញ្ញោ បដិសរណំ រីស្តេចវិទេហរាជនេះ បើវៀរលែងអញហើយនឹងមានអ្នកឯណាមួយតែងជាពំនាក់, នត្ថិ គ្មានឡើយ, ពោធិសត្វថា បើដូច្នោះ អញនឹងលោមស្តេចហោង ។ លំដាប់នោះ, ព្រះមហាសត្វពុំក្រាក់ភីតខ្លាច ទូលព្រះមហាក្សត្រនូវពាក្យនរនាថដូចរាជសីហ៍នៅលើថ្មនោសិលាថា មហារាជ បពិត្រមហារាជអើយ! កុំបីអម្ចាស់ខ្លាចឡើយ, ចូរអម្ចាស់សោយរាជសម្បត្តិឲ្យស្រណុកហោង ហើយអញខ្ញុំនឹងបណ្តេញអស់សេនាយោធាទាំង ១៨ អក្ខោភិនីនេះ អញខ្ញុំនឹងធ្វើឲ្យព្រាត់នឹងអម្ចាស់ឲ្យរួចទៅតែពោះទទេ គង់តែសំពត់មួយចង្កេះនេះ ។ ឧបមាដូចបុរសកាន់កំណាត់ឈើប្រកួតដីដុំធ្លោះស្ទាក់, ឬដូចបុរសមួយកាន់យកស្នាធបង្ហិញក្អែក, អាហា ទើបអ្នកសូត្រ ឥមំ គាថំ នូវគាថា ជាគំរប់ ៩ ដូច្នេះ

ចាតេ តេវ បសាវេហិ   កុញ្ជ កាមេ រមស្សុ ច
ហិត្វា បញ្ចាលិយំ សេនំ   ព្រហ្មទត្តោ បលាយតិ ។

ទេវ បពិត្រមហារាជអើយ ! សូមព្រះអង្គលាសណ្ដូកនូវព្រះបាទ ហើយសោយនូវកាមគុណដោយនូវចំណង់ឲ្យសុខសប្បាយហោង, អញខ្ញុំនឹងបណ្ដេញនូវស្ដេចចុលនីព្រហ្មទត្តរាជ ហើយឲ្យលះបង់ចោលនូវសេនាយោធាបញ្ចាលនគរទាំងឡាយហោង ។

រីចៅមហោសថ អ្នកលោមស្ដេចហើយ អ្នកចេញទៅឲ្យខ្ទង់ស្គរភេរី ឲ្យមនុស្សទាំងឡាយលេងល្បែងមហោស្រព ហើយពោធិសត្វអ្នកស្រដីនឹងមនុស្សទាំងឡាយថា អម្ភោ ម្នាលអ្នកទាំងឡាយអើយ ! កុំបីអ្នកបារម្ភឡើយ, ចូរអ្នកទាំងឡាយប្រដាប់បាយទឹក នូវភោជនាហារនឹងគ្រឿងគន្ធពិដោរ រណ្ដាប់ដំកល់ទុក ហើយថ្វេងលេងមហោស្រពឲ្យបាន ៧ ថ្ងៃ ។ រីមនុស្សផងនៅឋាននោះ ស៊ីផឹកស្រាច្រើនដោយធ្វើលេងគន្ធព, រីល្បែងកំប្លែងផងទាំងឡាយនោះ ខ្លះច្រៀង ខ្លះរាំ ខ្លះស្រែកហោ ខ្លះទះដៃ; សូម្បីល្បែងទាំងឡាយ ក៏នឹងបានជ្រាបអំពីចំណោះនៃអញហោង, ពោធិសត្វលោមអ្នកនគរទាំងឡាយថា កុម្ហោ ចូរព្រះស្ដេងម៉េលមើលអានុភាពនៃអញ, អហំ រីអញឈ្មោះចៅមហោសថអ្នកប្រាជ្ញ ទេះតែម្នាក់ បិតនៅក្បូ ពួនូវស័ត្រូវទាំងឡាយ មានស័ត្រូវប៉ាំច្រៀងកំដាដើមនៅក្នុងនគរ ។ រីមនុស្សទាំងឡាយដាក់ទុកដោយឲ្យមើលកលស្ត្រូវនេះឥតឯកណាបានឡើយ, ហេតុនោះហោង រីស្ត្រូវនឹងសម្លាប់នាំទៅក៏ឥតបីសម្លាប់បានឡើយ; ចូរទៅតាមទ្វារបន្ទិច ចូល

នៅក្នុងនគរនោះហើយ យល់អ្នកផងទាំងឡាយសឹងអង្គុយលេងមហោ-
ស្រព ៗ សូម្បីពួកសត្វជាកោលាហលក្នុងព្រះនគរនោះហើយក្តី ព្រះ
បាទចុលនីបទូលទៅនឹងអាមាត្យ នូវពាក្យដូច្នេះថា អម្ភោ អមច្ចេ
ហៃហៅអាមាត្យអើយ ! វីសេនាយោធាទាំង ១៨ អក្ខោភិនី យើងហោម
នគរបិតនៅហោង, វីអ្នកក្នុងនគរនោះ នឹងគិតភ័យក្តី នឹងត្រេកអរក្តី,
ឯតិ្ត គ្មានឡើយ; មនុស្សផងទាំងឡាយមានចិត្តត្រេកអរ ខ្លះទះដៃ ខ្លះ
រាំស្រែកហៅ ខ្លះរាំសើច ខ្លះរាំច្រៀង ខ្លះរាំរាំ; វីមហោសពរាំឡេធ្វើហៅ
អំពើអ្វីដូច្នេះ ៗ

លំដាប់នោះ, វីបុរសជាឧបនិក្ខិតនៃពោធិសត្វ ក៏ស្រដីពាក្យក្រាប
ទូលស្តេចចុលនីព្រហ្មទត្តរាជ នូវពាក្យដូច្នេះ ទេវ បពិត្រមហារាជអើយ!
យើងខ្ញុំចូលទៅកាន់នគរតាមទ្វារ បន្តិចមើលយល់អំពើមួយ មហាជន
ទាំងឡាយអង្គុយលេងមហោស្រព យើងដណ្តឹងដូច្នេះថា អម្ភោ ម្នាល
អ្នកទាំងឡាយអើយ ! អស់ស្តេចទាំងសកលជម្ពូទ្វីប មកហោមរោមជាបរិ-
វារនគរអ្នកទាំងឡាយបិតនៅហើយ ក៏អ្នកទាំងឡាយកុំប្រហែសពេកហ៎ះ
ហៅអំពើដូច្នេះអ្វី ? វីមនុស្សផងទាំងឡាយនោះ ក៏យើងស្រដីផងថា
វីស្តេចនៃយើង កាលនៅក្មេងឡើយ ទំនុកទុកចិត្តនូវក្តីប្រាថ្នាមួយ មាន
ប្រាកដ គេថាដូច្នេះ អស់ស្តេចទាំងសកលជម្ពូទ្វីប មកហោមរោមជាបរិវារ
នានគរយើងនេះ រណ្តាប់លេងល្បែងមហោស្រព បទហេតុនោះហោង,

អជ្ជ ថ្ងៃនេះ, រីខ្ញុំគិតប្រាថ្នានៃស្ដេចយើងនេះ នឹងលុះស្រេចបរិបូណ៌, ព្រោះហេតុនោះហោង ពោធិសត្វឲ្យគូងស្គរភេរី ឲ្យអ្នកផងលេងមហោស្រព, រីខ្លួនពោធិសត្វឯងសោត តែងដំទុំផឹកស្រាច្រើនគ្នាលើគ្រឡាគំនាលធំ ៗ ស្ដេចចុលនីព្រហ្មទត្ត ស្ដេចស្ដាប់ពាក្យអាមាត្យនោះហើយ ក៏ទ្រង់ខ្ញាល់បង្គាប់ប្រើសេនាយោធាទាំងឡាយថា ភោន្តោ ម្នាលគ្នាយើងទាំងឡាយអើយ! អ្នកចូរទៅឆាប់ប្រញាប់ចូលទៅតាមកេមនគរនោះឯអាយឯនាយ ទំលាយនូវគូបន្ទាយ បើកទំលាយក្លោងទ្វារ តាស់ចូលទៅឲ្យបាននគរនោះ កាត់កយកក្បាលស្ដេចវិទេហរាជ អញខ្លាសណាស់ហ៎ះ ព្រះស្ដេចនាំយកក្បាលមហាជនផងទាំងឡាយ ដឹកនឹងរទេះចូលមកឲ្យបានមួយរយ ដូចគេដឹកឆ្នាំងបាយ ៗ រីយោធាទាហានទាំងឡាយ ស្ដាប់ពាក្យស្ដេចបន្ទូលដូច្នោះហើយ ដ៏មានដៃកាន់ទីទៅនូវគ្រឿងអាវុធមានពណ៌ផ្សេង ៗ ហើយទៅទៀបក្លោងទ្វារ, រីបុរសសេនាចៅមហោសថអ្នកប្រាជ្ញ រណ្ដាប់នូវគ្រឿងអាវុធទាំងពួង នូវសាវទំនើបគឺដុំថ្ម ថ្មដា ថ្មអាន អំបែងចេះ អំបែងចាន គ្រួសរពន នឹងបោះទឹងចោលផតក្រែងឡើយ, រីសេនាយោធាស្ដេចចុលនីឯងថា យើងចុះទៅក្នុងគូនោះ ហើយឡើងអំពីគូនោះ យើងនឹងទំលាយនូវបន្ទាយចៅមហោសថហោង, រីឯសេនាយោធាចៅមហោសថអ្នកប្រាជ្ញនោះវិញ សឹងបិតនៅនាលផ្ទៃក្លោងទ្វារបន្ទាយនោះ ក៏សឹងចាក់នូវស្នូលដែងដាវសាវកន្ទើរផង

ប៉ុនប៉ងនឹងឲ្យវិនាសផងច្រើន ៗ រីឯយោធាទៅមហោសថអ្នកប្រាជ្ញ អ្នកខ្លះកន្ទ្រញ ដៃអ្នកខ្លះបង្ហាញជុំដៃទៅកាន់យោធាស្តេចចុលនី ស្រែកជេរថា តុម្ហេ ហៃព្រះស្តេចអើយ ! អ្នកមកអំពីលំបាកព្រួយ មិនបានបាយហូបដល់តិច ហើយចូរព្រះស្តេចមកធីត្រីសាច់ ចូរមកផឹកស្រា អ្នកខ្លះប្រាប់បាននូវប្រទ្រូចត្រីលើកជំរង់បង្ហាញទៅនោះ, រីអស់អ្នកតាំងអម្បាលនោះ ផឹកធីយ៉ាងរអឹក ហើយដើរទៅដើរមក បំអើតលើភាគបន្ទាយ ៗ រីសេនាយោធាស្តេចចុលនីពុំអាចដើម្បីនឹងធ្វើអ្វីគេដល់តិច ក៏ស្រែកដើរទៅកាន់សំណាក់ស្តេចចុលនីថា ទេវ បពិត្រមហារាជអើយ ! បើវៀរប៉ុន្តែរិទ្ធអានុភាពអម្ចាស់ហើយ គេនឹងមានស្តេចដទៃឯណាមួយក៏អាចនឹងទោមចាប់បាន ៗ រីស្តេចតាំងនៅអស់ ៤-៥ ថ្ងៃ មិនយល់ឡើយ ក៏គួរគប្បីនឹងចាប់ឲ្យបានទៅក្លូវ, ស្តេចដណ្តឹងអាចារ្យកេវដ្ដ-ព្រាហ្មណ៍ថា អាចរិយ ហៃអាចារ្យអើយ ! ធ្វើដូចម្តេច ? រីយើងនេះ ពុំអាចនឹងចាប់ស្តេចវិទេហរាជនោះបាន, សូម្បីនឹងមានអ្នកពូកែណាមួយនឹងអាចដើម្បីចូលទៅចាប់បាននោះក៏គ្មានឡើយ ៗ អាចារ្យកេវដ្ដព្រាហ្មណ៍ទូលស្តេចចុលនីថា បពិត្រមហារាជក្សត្រថ្ងៃប្រសើរអើយ ! ព្រះយោបល់បើដូច្នោះ រីអាចិ១បាយកលមួយណានាបនគរនេះ មានទឹកតែឯស្រៅនោះឯងអេះ, ចំណោះនេះ យើងនឹងចាប់ឲ្យបានតែនឹងបង្អត់ទឹកនេះហោង, មនុស្សផងតាំងឡាយនៅក្នុងនគរនោះ ក៏នឹងលំបាកដៀតឥតទឹកផឹកហើយបើកទ្វារ

ចេញមក ចាំមើលយើងចាប់បានវាយក្តាត់ ទើងគិតអ៊ីទៀយ ៗ ម្លោះហើយ ស្តេចទទួលយកពាក្យអាចារ្យកេវដ្ដព្រាហ្មណ៍ថា ទុបាយកលនេះជាទុបាយ ល្អប្រពៃហោង ៗ ចាប់ដើមអំពីថ្ងៃនេះទៅ យើងនឹងបង្ហូរទឹកចូលមកឯង, យើងឯណេះចំណេះយើងនេះយល់ល្អក្រអេះ ៗ ម្លោះហើយបុរសជាទុប-ទិក្កិតចៅមហោសថសរសេរសំបុត្រប្រើពតិមាននោះឲ្យទៅចងនាគ្រចៀក កាំបញ្ជូនទៅផ្តាំដូច្នេះថា បើនរអ្នកឯណាយល់សំបុត្រនាគ្រចៀកកាំនេះ ឲ្យរើសយកទៅបង្ហាញចៅមហោសថជាដើម ៗ អដេតោ បុរិសោ តំ ទិស្វា គហេត្វា បណ្ឌិតស្ស ទស្សេតិ ៗ លំដាប់នោះ, មានបុរសម្នាក់យល់សំបុត្រនោះហើយ នាំទៅបង្ហាញចៅមហោសថអ្នក-ប្រាជ្ញ ៗ រំពោធិសត្វអ្នកដឹងពតិមាននោះជាក់ហើយថា រីអាចារ្យកេវដ្ដ-ព្រាហ្មណ៍នោះ មិនដឹងនូវសភាពអញជាមហោសថអ្នកប្រាជ្ញនេះទេហ៎ះ, ជាដូច្នោះហើយ គំពោធិសត្វអ្នកឲ្យយកទៅនូវឫស្សីប្រវែងហុកសិបហត្ថ ហើយអ្នកឲ្យពុះជា ២ អ្នកឲ្យដំរះថ្នាំងបរិសុទ្ធល្អហើយ អ្នកឲ្យផ្គាប់ចូល គ្នាដដែលវិញ ឲ្យចងតាក់ស្បែកលាបកក់ឯលើ, រីពួជគុម្ពទដែលមហា-ឫស៊ីមានឫទ្ធីអានុភាព ឲ្យនាំមកអំពីព្រៃព្រះហិមពាន្តមានទៅស្រះនោះ ឲ្យ ដាំទុកនាគក់ផ្ទៃស្រះបោក្ខរណី ឲ្យទុកចុះក្នុងឫស្សីនោះហើយ ឲ្យចាក់ ទឹកបំពេញពាល់មាត់ឯលើហោង ៗ រីគុម្ពទនោះ លូតឡើងតែមួយក្រី

ផ្កាផុសឡើងអំពីមាត់បំពង់នោះ មាត្រាហាក់ដូចជារតនវត្ថុហើយក៏បិត ទៅ ៗ លំដាប់នោះ, ពោធិសត្វអ្នកឲ្យយកផ្កាកុមុទនោះ ឲ្យទៅបុរសអាមាត្យនៃអាត្មាផ្តាំដូច្នេះថា តុម្ហេ ម្នាលអាមាត្យអើយ ! ចូរឲ្យផ្កានោះទៅស្ដេចចុលនីព្រហ្មទត្តកជនោះហោង ៗ រីបុរសនោះ ធ្វើជាក្លាយខ្ទង. ផ្កាកុមុទនោះហើយហោះទៅនិយាយថា អម្ភោ ម្នាលព្រះស្ដែងអាមាត្យតែងបំរើដិតស្និទ្ធនឹងស្ដេចចុលនី ចូរព្រះស្ដែងយកផ្កាកុមុទឧប្បលនេះទៅឲ្យស្ដេចសៀតត្រចៀកលេង ជាប់ស្ដេចឃ្មានឲ្យធំខ្ទងផ្កាកុមុទនោះចុះបំពេញពោះកុំឲ្យស្លាប់ ៗ មានបុរសមួយតែងបំរើនៃបុរសជាឧបនិក្ខិត្តទៅមហោសថនោះ រើសយកផ្កានោះទៅថ្វាយស្ដេចទូលថា ទេវ បពិត្រអើយ! អញ្ជើញអម្ចាស់អ្នកឡើងទៅមើល ផ្កានេះមានខ្ទងវែងសភាពបង្គួរដូច្នោះនោះ យើងពុំដែលយល់អំពីមុនមក, រីបុរសនោះ ក៏ទូលស្ដេចនូវពាក្យល្បើកប្រការអម្បាលនោះហើយគូរ, បុរសជាឧបនិក្ខិត្តទៅមហោសថធ្វើខ្ទងផ្កាកុមុទប្រវែងហុកសិបហត្ថនោះ បន្ទៀនចេញបានទៅជាប៉ែតសិបហត្ថវិញហោង ៗ

(នៅមានត)

# ប្រវត្តិព្រះឥន្ទ្រ នឹង សង្គ្រាមអសុរ

លោក ជល-ឌិន នៅក្នុងសាសនបណ្ឌិត្យ

និពន្ធជាពាក្យកាព្យតាមសេចក្តីក្នុងគម្ពីរសោរត្ថទីបនី

## វិនយដីកា សមន្តប្បាសាទិកាវណ្ណនា

ប្រវត្តិព្រះឥន្ទ្រ ទេវរាជ
ដែលវាតអំណាច នៅសួគ៌ា
នឹងអសុរយុទ្ធ ដោយយោធា
គូរមិត្រវាល់គ្នា កំណត់ដឹង

### រឿងនេះមានចែងថ្លែងក្នុងអត្ថ

គម្ពីរសោរត្ថ បទដីកា ជារឿងពីរោះជាប់ចិន្តា
ដូចជាតម្រាយុទ្ធសាស្ត្រ ៗ តាមរឿងដំណាលពីព្រេងព្រឹទ្ធ
អតីតកន្លងយូរលង់ណាស់ ជារឿងនិពន្ធជំនាន់ចាស់
និទានជាក់ច្បាស់និយាយថា ៖

ក៏កាលដំណាលពីដើមកប្ប មានចៅមាណពម្នាក់សោភា
គេហៅ មឃៈ ពល់ ១ គ្នា នៅនាស្រុកឈ្មោះអចលគ្រាម ៗ

គាត់មានភរិយាគ្នាបួននាក់ នឹងមានមិត្រភក្តិមិនជាក់នាម
ដែលស្មោះស្មើខ្លួនចំនួនសាម- សិបពីរនាក់តាមគម្ពីរថ្លែង ៗ

គាត់ដើបចូនជនបទ[1] ដែលស្ដេចកំណត់ប្រទានថែង
ចែកឲ្យជាសួយមួយកន្លែង ដើម្បីតាត់ថែងរាស្ត្រប្រជា ។
មិត្រគាត់ទាំងសាមសិបពីរប្រាណ ក៏បានចំណែកគ្រប់អាត្មា
គឺធំស្រុកនោះទាំងអស់គ្នា មូលមិត្រចិត្តាឥតរង្គ ។
ឯលោក មឃៈ ជាប្រធាន នាំមិត្រគ្រប់ប្រាណមកនៅជុំ
បង្កើតបានជាសមាគម ១បត្តមកសាងប្រយោជន៍ជាតិ ។
បំណាយកម្លាំងទាំងធនធាន ជីកនាំសន្តានឲ្យខ្មីឃ្មាត
សាងសាលារៀនយ៉ាងល្អស្អាត សង្វាតសាងផ្លូវទៅពេញស្រុក ។
សាងស្រះជាសហាន់ដែលគ្មានទឹក នាំជីកដីកព្រៃកចែកច្រើនមុខ
សាងពេងសំណាក់ត្រជាក់សុខ សាងស្ពានក្នុងស្រុកទុកកស្រួចផង ។
នាំគ្នាប្រព្រឹត្តយ៉ាងម៉ត់ចត់ នូវ វត្តបទ[2] ប្រាំពីរផង
ធ្វើបុណ្យសុទ្ធនូវទានពុំមានហ្មង កន្ទុំយូរយារគាប់ព្រួយ ។
លុះដល់កំណត់ផុតជន្មា អ្នកទាំងអស់គ្នាវេលាក្សយ
ក៏បានកើតក្នុងសួគ៌ាល័យ អាស្រ័យបុណ្យទានជាយានទៅ ។
គឺបុណ្យគុណកើតពីការសាង ប្រយោជន៍គ្រប់យ៉ាងឥតហ្មងសៅ
ជួយជនទាំងសាមសិបបីទៅ ឲ្យកើតនិត្យនៅផ្លូវសុខា ។

---

១ ត្រូវគ្រាស្រុកចុងកាត់មាត់ញកបែបដូចជាស្ដេចប្រាប់ ។ ២ វត្តបទប្រាំពីរប្រការ មានក្នុងគម្ពីរធម្មបទដ្ឋកថាត្រង់សក្កវគ្គ ភាគ ២ ។

កាលនោះព្រះបាទវេបចិត្តិ ស្ដេចបិតជាម្ចាស់ឋានសួគ៌ា
លុះឃើញទេវបុត្រទាំងអស់គ្នា កើតនាវិមានឋានព្រះអង្គ ។
ស្ដេចមានព្រះទ័យថ្លៃស្មោះសរ អបអរពេកទាក់ស្ម័គ្រស្មោះត្រង់
ចាត់ចែងទទួលស្រួលអស់អង្គ ដោយចង់ជាមិត្រស្និទ្ធមេត្រី ។
ចែងចែកសម្បត្តិក្នុងទេវលោក ព្រោះយោគយល់ចិត្តមិត្រកើតថ្មី
ដែលមកជុំទាំងសាមសិបបី ចក្រីរៀបចំសមឥតខ្ចោះ ។
ប្រមូលអស់បែបទេពធីតា ដ៏មានកាយាថ្លាឥតមោះ
ទ្រូងតើងឡើងពេញចេញផងពោះ គូដោះក្បិតក្បំដូចគេវេច ។
ដួងភ្នែកផ្លេកភ្លឺពន្លឺចាំង ពាក់ក្បាំងទាំងក្បាលរន្ទាលលេច
ខ្សែមាសពាសដាំអង្កាំពេជ្រ កម្ទេចស្មើរង្សីថ្លា ។
ព្រះភ័ក្ត្រស្រស់ស្រើបលើបស្រិល រអិលព្រិលព្រួចក្លួចចិន្តា
សម្ផស្សសោភណទន់សោភា កេសាឥតសៅខ្មៅយ៉ាងស្រស់ ។
ល្អអើយល្អណាស់ល្អគ្រប់គ្នា ច្រើនឥតគណនាកប់មិនអស់
ព័ទ្ធហោមពេមពេញជាកិត្តិយស ផ្សាយរសពិដោរគួរបេតី ។
បញ្ចេញធ្មេញសើចសំណើចស្រួល ទទួលពេញចិត្តមិត្រកើតថ្មី ។
ស្រាយស្រស់ផ្ដោះផ្ដងសងសំដី សំដែងមេត្រីស្រីនោមនាយ ។
ពាសពេញវៀណរង្គពន់រំពើក លាតលើកដៃជើងឡើងពង្រាយ
ក៏បែរបេះបិទម៉ិតពត់កាយ មិត្រថ្មីទាំងឡាយសប្បាយលន់ ។

នាងនាដកិត្តិ(១)ស្រីអប្សរ លើកករតាក់ក្បាច់គាប់ទន់អន្ទ
កៀកកាយលាយតាមតាមទម្រង់ ជន្ទង់ពន់ពើងឡើងល្អាសល្អន់ ។
ជាពួកជាក្រុមជុំអធិក ភ្លូកភ្លឹកគឹកកងគួរគយគន់
ទេពតាកើតថ្មីព្រះទ័យទន់ សប្បាយពេកពន់ក្តីអាត្មា ។
សូរសព្ទសំឡេងបទភ្លេងពិណ រូបរឹបដួងចិត្តមិត្រទេវតា
ពីរោះអើយពីរោះហួសឧបមា គួរព្រឺរណ្ដាថ្លាហឫទ័យ ។
នៅក្នុងប្រាសាទស្អាតប្រសើរ ខ្ពស់ទើរលើកពនភាល័យ
ក្បូរក្បាច់រចនាវាសនាថ្ងៃ ល្អហួសវិស័យនៃមនុស្សឋាន ។
សុទ្ធសឹងតែមាសពាសដោយពេជ្រ រំលេចពៃទូរ្យសូរ្យកាន្ត
មណីរត្នពិទ្ធជុំវិញគ្រប់ឋាន ប្រមាណសន្ធឹងធំល្វឹងល្វើយ ។
ទេពតាកប់ច្រើនម៉ឺនចូលចេញ នៅតែមិនពេញប្រាសាទឡើយ
អាកាសត្រជាក់ខ្យល់រំភើយ រហើយស្រួលប្រាណក្សាន្តពន់ពេក ។
ទេវបុត្រតូចធំសមតាមថ្នាក់ យសសក្តិរាប់ម៉ឺនច្រើនអនេក
ខ្លះក្រោកឡើងរាំខ្លះទំស្រែក សម្រែកចម្រៀងច្រៀងសប្បាយ ។
ឯស្តេចទេពតាបក្កាន់ លើកផ្កាចទុមពិត្រពណ្ណរាយ
នាំអស់បរិវារផងតាំងឡាយ ចូលថ្វាយចំពោះទេពតាថ្មី ។
ដែលមាននាមាថា សញ្ញា: ឲ្យគ្រងភារៈអធិបតី

---

១ ស្ត្រីរបាំ ។

សោយកដសម្បត្តិទិព្វសួស្តី កាន់កាប់ផែនដីភាគកណ្តាល ។
រួចស្រេចស្តេចទ្រង់ឲ្យតាក់តែង តាក់តែងស្រាជ័យថ្ងៃត្រកាល
ឲ្យអស់ទេពតាទាំងចក្រវាឡ ត្រអាលជីកះគ្រប់បែបកំសាន្ត ។
ជាសាធុការថ្វាប្រពៃ ប្រសិទ្ធិះជាគជ័យថ្ងៃចំណាន
ដល់មិត្រចំណូលសាមប៉ប្រាណ ឲ្យបានមង្គលសុខះថេរបិត ។
ឯពួក សញ្ញា: អ្នកកើតថ្មី ទាំងសាមសិបប៉មិនពេញចិត្ត
ព្រោះឃើញសម្បត្តិសម្បើមពិត ក្លួចចិត្តចង់បានរាជ្យទាំងអស់ ។
ក៏ឲ្យសញ្ញាអាចកំបាំង ប្រុងប្រៀបប្រចាំងដណ្តើមយស
ផ្ញើកល១បាយយកទាំងអស់ ប្រាថ្នាធំខ្ពស់ទាំងសាកល ។
ឯពួកទេពតាជាម្ចាស់រាជ្យ ប្រសេចប្រសាចដើរចល់
ចាក់ស្រាឲ្យផឹកឥតទឹកខ្វល់ ច្របល់ជ្រួលជ្រើមសម្បើមក្រៃ ។
ខ្លះលើកប៉េកឆ្កែលចុកដប រៀបរបចាក់ឆ្កែងកែវចរណៃ
ខ្លះក្រេបបែបផ្ទួនទន់ដើងដៃ ខ្លះលែបផ្អកច្រកមិត្រភក្តិ ។
ខ្លះជ្រួសហួសពេកដេកសន្ទឹង នេត្រស្មឹងរឹងសូកម្ខុះខ្មៅឃ្លាក់
ខ្លះក្រោកងោកដាក់អស់នាងអ្នក បញ្ចោញសង្វាក់កំកំសាន្ត ។
ខ្លះទៀតប្រមឹកផឹកឥតក្រែង ជួលដេកចំខែងលែងដឹងប្រាណ
ងោករង្គុលជ្រុលប្រមាណ ដេរដាសពាសឋានគ្មានសេសសល់ ។
ឯពួកស្រីស្រស់ទេពអប្សរ កំផឹករឹករេច្រួលច្របល់

កៀកកៃស្នេហ៍ស្និទ្ធចិត្តវិលវល់ អស់កល់កេរខ្មាសផ្ដេសផ្ដាសអង្គ ៗ
ប្រឡូកបូកប់ប្រឡំបល់ គ្រប់កាយខ្វាយខ្វល់តាមចំណាន់
ប្រឹងប្រឹតគិតតែកែខម្រន់ កៀកអង្គគន់អែបនែបតូគាប់ ៗ
ពួកក្មេងលេងខ្ញុំញ័រពិកព គ្មានឈប់សម្រាកផ្អាកសូរស័ព្ទ
ក្សេមអើយក្សេមក្សាន្តគ្មានទឹកស្លាប់ ទឹកច្បាប់ក្រមក្រឹត្យគួរគិតក្រែង ៗ
ឯពួក សត្តា: អ្នកកើតថ្មី តាំងសាមសិបបីក៏សំផែន
អាការដូចជាប្រឹងផឹកលេង ស្រវឹងវង្វេងគ្រប់ ៗ គ្នា ៗ
លុះឃើញទេវតាដែលនៅមុន ផឹកស៊ីនខន់ខ្ទួនផ្ទួនតែស្រា
ដួលជាសពាសទីឋាននានា លែងដឹងកាយាក្វារស្មារតី ៗ
ទ្រេតទ្រោតដួលចុះខុសទំនង ដេកគងគាក់គ្នាលែងដឹងអ្វី
លេចមុខខុកក្រោយមិនគប្បី ស្រីស្រីក៏គ្មានប្រាណអៀនខ្មាស ៗ
ដេកផ្កាប់ដេកផ្ងារហាមុខក្រោយ ខ្លះដួលបណ្ដោយដេកបញ្ច្រាស
ខ្លះដេកយកដៃលៃខ្ទប់ថ្ងាស ខ្លះប្រាសជើងគងរំលងក្បាល ៗ
ខ្លះនៅលើតុសំកុកជ្ជឹង ឱបស្រីព្រលឹងប្រឹងត្រអាល
ទោរទន់សញ្ញាះដោយក្ដីពាល ឱនក្បាលជ្រុលជ្រប់ផ្ទប់មុខគ្នា ៗ
សត្តា: ឃើញចោះអស់បារម្ភ បង្គំមិត្រភ្លាមតាមសញ្ញា
ទៀចូលចំបាប់ចាប់ទេវតា ដែលមានឧបុត្ថានុភាពធំ ៗ
ដឹងពួកបក្សាជាច្រើននាក់ មានថ្នាក់ស័ក្តិខ្ពស់យសឧត្តម

មិត្រថ្មីសាមប័ក្មានបារម្ភ    ស្ទុះចំទំចូលទ្រូលដើងដៃ ។
កន្ទ្រាក់ចាប់ដើងពួកប្រមឹក    ដែលផឹកស្រវឹងហួសវិស័យ
គ្រវីគ្រវ៉ាត់ក្តាត់អស់ដៃ    ពីសុរាល័យយ៉ាងកំណាច ។
គ្រវែងចោលក្នុងអន្ទង់ធំ    ធ្លាក់ទៅបាតភ្នំសិនេរុរាជ[1]
សក្កៈខ្លួនឯងឥតក្រែងខ្លាច    អំណាចតេជះព្រះចេស្តា ។
ស្ទុះចូលច្រូលក្តួបរួបដើងមិត្រ    នាម វេបចិត្តិ មហាពជា
គ្រវ៉ាត់យ៉ាងខ្លាំងកម្លាំងក្លា    ខ្ទាតចាកឋានាធ្លាក់ចុះវឹង ។
ទេពធិតរជាច្រើនកើនម៉ឺនលាន    ខ្ទាត់ចាកវិមានគ្មានដំណឹង
ជ្រុះទៅបាតភ្នំដុំស្លុកស្លឹង    ពាល់តែស្មាត់ឈឹងពីសួគ៌ា ។
នៅសល់ទេពតាណាស្មោះត្រង់    ព្រមអង្គផ្ចង់កាយថ្វាយវន្ទា
ស្ម័គ្រចូលមូលមិត្រចិត្តរួមគ្នា    ទើបរួចអាត្មាពីគ្រោះថ្នាក់ ។
ឯពួកស្រវឹងស៊ីងងោកងុយ    ជ្រុះចុះរប៉ើយដូចក្អៀងធ្លាក់
ទៅគរលើគ្នាជាច្រើននាក់    ឥតក្បាក់កាយាផ្កាប់ផ្ងារប្រាណ ។
ដោយកត្តាភាគផលកុសលបុណ្យ    ពួកទេពតាមុនទាំងប៉ុន្មាន
គ្រាន់តែបែរជ្រុះចុះដល់ឋាន    វិមានបាតភ្នំផ្សំគ្នាក្លាយ ។
កើតទៅជាភពផែនប្រឹថពី    ជាទីរុងរឿងថ្កើងសប្បាយ
មានជ្រុងកំពែងវែងកន្ទ្រាយ    ចម្ងាយមួយម៉ឺនកើនយោជន៍យល់ ។

---

[1] ភ្នំព្រះសុមេរុ ។

ផុសប្រាក្ដស្អាងស្អាតប្រាសាទច្រើន ដាំត្បូងរូងក្បាច់បុប្ផាផល
មានស្ត្រីអប្សរល្អខិមិល មៀងយល់ដូចជាសួគ៌ាល័យ ។
មានដើមប្រទៀង(១)ជៀងជាក់ទិព្វ សស្រិបដុះឡើងច្រើនពេកក្រៃ
មណីរ័ត្នពន្លឺភ្លឺដូចថ្ងៃ វិស័យសួគ៌ឋានគ្មានប្លែកឡើយ ។
លុះពួកទេពតាភ្ញាក់ប្រាណ មៀងមើលវិមានឋាននោះហើយ
ឃើញអស់ពួកមិត្រដិតបង្កើយ ស្មានតែហឹងហើយឋានប្រក្រតី ។
គិតតែកែក្បាច់បង្អាច់កាយ លោកកំសប្បាយគ្មានគិតអ្វី
ឥតទុក្ខសុខក្សេមដ៏ប្រិមប្រិយ សួស្តីឥតខន្តពន់ពេកក្លូវ ។
នេះគឺដោយផលពីអតីត វិចិត្រកើតឡើងដោយរដូវ
មានកម្មចាំជួយស្នួយតម្រូវ នឹងផ្លូវបច្ច័យលៃសានឲ្យ ។
ឯពួកសត្តៈអ្នកប្រយុទ្ធ ជាទេវបុត្រកើតជាន់ក្រោយ
វាយប្តូរស្វិប្រាណបានរាជ្យសោយ គឺដោយតេជៈបុណ្យបារមី ។
ពួកទេពតាចាស់ផ្លាស់ឋានៈ ព្រោះតែសត្តៈអ្នកកើតថ្មី
ធ្វើកល១បាយយកផែនដី មានជោគសួស្តីស្ថិតស្ថេរ ។
លុះចាប់មិត្រខ្លួនផ្ទួនចោលក្នុង អន្ទង់បាតភ្នំព្រះសុមេរុ
អស់ស្រេចទើបស្ដេចនាំគ្នាបែរ រៀបគ្នាពង្រីកអាណាចក្រ ។
បរពលយោធាជាអធិក គគ្រឹកគគ្រឹកផ្ទោះបោះប្រចាក់
ប្រទើសលើសគេទគ្រើនអនេក្ស ជាបក្សព្រះឥន្ទ្រពិនចក្រវាល ។

---
១ ដើមចិត្របាលិ ។

ចិត្តដូចអគ្គីបុទ្ធីកា គណនាដ៏ច្រើនកើនចំនួន ។
គឺឲ្យជាអ្នកត្រូវតាំងចាត់ នៅចាំសង្កាត់ផ្លូវទាំបួន
បើបញ្ជាមិត្រចិត្តមាំមួន ចូលដល់ផ្លាល់ខ្លួនផ្ទួនកម្លាំង ។
ត្រូវបក្សយក្សយន់ពង្សក្លាហាន ប្រុងប្រាណប្រយុទ្ធឈុតប្រឆាំង
រៀបចំក្រុមទ័ពចូលទប់ច្បាំង បន្ទយកម្លាំងក្នុងរឿណរង្គ ។
បន្ទាប់ពីពួកយក្សមកទៀត ផុតទ័ពឆ្មៀតជ្រៀតផ្លូវត្រង់
ចាត់តាំងមហាពលទាំងបួនអង្គ ឲ្យរង់គង់ឃ្លាំប្រចាំការ ។
និត្យនៅផ្លូវដើរឡើងទៅចំ លើភ្នំសិនេរុបរិវារ(១)
មានកងក្លាហានប្រចាំការ អធិកឧឡារពន់ពេកក្រៃ ។
កងទ័ពមហាពលអង់អាចណាស់ សុទ្ធសឹងជើងចាស់តបះគេជដៃ
មួយពួកមួយពួកមានទង់ជ័យ ដងខ្ពស់លៃជាសញ្ញា ។
លុះតាំងបាំងចាត់សង្កាត់សឹក ផ្លូវគោក ផ្លូវទឹក - អាកាសា
ស្រេចហើយសញ្ញា:បុទ្ធីកា និងពួកទេវតាជាមិត្រភក្តិ ។
នាំគ្នាចូលក្នុងវាំងប្រាសាទ រាតអាទ្យដ៏ឡើងថ្កើងបុណ្យស័ក្តិ
មូលមតិចាត់ការពារពិភក្តិ ចាំងសាមបីនាក់តាមថ្នាក់ជាន់ ។
ពេលនោះប្រាសាទស្អាតត្រសុស ប្រជ្រៀតគ្នាផុសច្រើនហ៊ឹនពាន់
ខ្ទះទាបពាបពោលខ្ទះច្រើនជាន់ ចេញរាប់មិនទាន់ហួសគណនា ។

---

១ ភ្នំនិលៈនៅជុំវិញភ្នំព្រះសុមេរុ មានភ្នំឈ្មោះយុគន្ធរៈជាដើម ។

ទេវពិភពលុបឈ្មោះចាស់ នាមផ្លាស់ថាត្រៃត្រឹង្សសួតា
ឬហៅពិភពតាវត្តឹសា ដោយនាមទេវតាសាមបីប្រាណ ៗ
តាំងនៅលើថ្ងៃនៃមហាភ្នំ ទំហំធំខ្ពស់ហួសប្រមាណ
គឺភ្នំសិនេរុរាជឋាន(១) វិមានកុះកុំដុំច្រើនក្រៃ ៗ
ជាទេពនគរល្អត្រកាល ធំពលដាលឆ្ងាយដាច់អាល័យ
មានទ្វារមួយពាន់កំពែងកល់ថ្ល វិស័យកំពែងវែងចាំមួន ៗ
គឺកំពែងក្រុងជ្រុងមួយ ៗ ចាំឥតរញ្ជួយព្រួយរត់ពួន
ប្រវែងមួយម៉ឺនយោជន៍តាំងបួន ចំនួនដប់កោដិយោជន៍ក្រឡា ៗ
ខាងក្នុងនគរល្អត្រចះ មានស្រះបោក្ខរណីដក់ថ្លា
សួនច្បារផ្កាដុះផុសត្រៀបត្រា បុប្ផាជម្រុះរីកស្គុសស្គាយ ៗ
មានរុក្ខជាតិមានធំខ្ពស់ សន្ទឹកខៀវស្រស់ដុះពង្រាយ
ជាជួរជាក្រុមសមឆើតឆាយ គួរឲ្យសប្បាយដើរកំសាន្ត ៗ
នៅមជ្ឈមណ្ឌលយល់ត្រកាល ជាទីកណ្ដាលបូរីហ៊ាន
ប្រាសាទមួយធំសមប្រមាណ សម្រាប់ក្សត្រក្សាន្តព្រះទ្រង់យស ៗ
ឈ្មោះថាប្រាសាទវេជយន្ត ប្រកបថ្នាក់ជាន់ពច់មិនអស់
ដហ្វាប្រសព្វគ្រប់ទិសទស ឆើតឆាយសម្រស់ស្រស់ញញឹម ៗ
កំពូលកម្ពស់ខ្ពស់ត្រដោច ប្រាំពីររយយោជន៍យល់សន្ទឹម
ក្បូរក្បាច់រចនាថ្វាបំប្រិម រគុំបូទំមផ្ទឹមពុំបាន ៗ

១ ភ្នំព្រះសុមេរុ ។

សុទ្ធសឹងដោយមាសនាគាសផ្ទេក ស្មើតាំងក្អែកគ្រប់ទីឋាន
ត្បូងពេជ្រពៃទូរ្យស្បូរក្រាន្ត ដំមានពន្លឺភ្លឺដូចថ្ងៃ ។
ខាងលើប្រាសាទស្អាតគ្រប់ផង់ មានដោតដងទង់ខ្ពស់លលៃ
សុទ្ធសឹងមាសពេជ្រល្អពេកក្រៃ វិស័យមនុស្សលោកយោគមិនយល់ ។
មានរាជរថមួយឈ្មោះវេជយន្ត ទឹមសេះពីរពាន់មហាពល(១)
ក្បូរក្បាច់រចនាថ្នាទិមិល ជាផលថ្កល់ថ្កើងរុងរឿងឫទ្ធិ ។
រថនេះជាយានថ្កានប្រសើរ ហោះហើរដើរបានគ្រប់ឋានបិត
សម្រាប់សក្កៈអ្នកមានឫទ្ធិ ឆ្ពាយដិតស្តេចគង់ថ្កានយាត្រា ។
មានដំរីមួយសមសោភ័ណ ឈ្មោះឰរាវ័ណសមសោភា
ជាទេពនិម្មិត(២)បិតស្មួគាំ សម្រាប់កជាព្រះទ្រង់យស ។
មានកេងប្រជុំក្រុមទេវតា ឈ្មោះសុធម្មាទូលាយខ្ពស់
មានច្បារផ្កាភ្ញីគន្ធរស យ៉ាងស្រស់ឈ្មោះចិត្តលតាវ័ន ។
មានស្រះបទុមផុំបុប្ផា ឈ្មោះសុនន្ទាជាតំបន់
ទឹកថ្លាត្រជាក់ស្រួលពេកពន់ គួរគន់ចុះមុជកែកសាន្ត ។
ទីក្រុងតាំងមូលពោលដោយខ្លី ស្មើពន្លឺភ្លឺសព្វឋាន
ទុគ្គិរុងរឿងល្អថ្កើងថ្កាន ទេវតាប៉ុន្មានក្បែរមកក្សាន្តសុខ ។

---

១ មានកម្លាំងច្រើន ។ ២ ដែលទេវបុត្រមួយអង្គនិម្មិតខ្លួនជាដំរីសម្រាប់ស្តេចគង់ក៏សាន្ត ។

ឯមិត្រទាំងសាមសិបបីនាក់ ស្មោះស្ម័គ្រគ្រប់ប្រាណបានដាក់ទុក
លើកអង្គសញ្ញាៈជាប្រមុខ គ្រប់គ្រងភូមិស្រុកក្នុងសួគ៌ា ។
សញ្ញាៈពេលនោះឈ្មោះវិចិត្រ ជានាមនិមិត្តច្រើនមហិមា
គឺនាមដែលពួកមនុស្សទេពតា នាំគ្នាហៅជា ព្រះបុន្ទរ(១) ។
ហៅ តិទិវាធិភូ, បុរន្ទទ ទេវិន្ទ, បាកសាសនោ
ទេវកុញ្ជរៈ, វាសវោ សុរនាថោ, ជម្ពារី ។
វជិរហត្ថ, អមរិន្ទោ គន្ធព្វរាជា, សុជម្បតី
អសុរាភិភូ, ព្រះកោសិយ ភូតបតី, សុរាធិបៈ ។
វជិរវុធ, មឃវា ទេវរាជា, សហស្សក្ខៈ
សុរិន្ទ, អសុរសាសនៈ ទសសតលោចនោ ។
វត្រភូ, ទេវានមិន្ទ ឥន្ទ្រៈ, មហិន្ទ, សហស្សនេត្ត
សក្កៈ, តិសម្បមុខោ បជាធិបោ(២) ដូច្នេះក៏មាន ។
សោយសុខសម្បត្តិសម្បើមបុណ្យ សម្បូណ៌ដោយគុណកបកល្យាណ
ពួកស្រីអប្សរថេវប្រាណ ពេញហ៊ានវក់វីរើរដេរដាស ។
ទាំងពួកទេវបុត្របៀតកើត យោនយកកំណើតទេវកាស
កើតកើនច្រើនទៀបិតដេរដាស ពេញពាសកកកុញក្នុងសួគ៌ា ។
គឺដោយសារគុណនៃសក្កៈ បានឡើងឋានៈទេវរាជា

---

១ បុរសជាអធិបតី។ ២ តាំងពី តិទិវាធិភូ ដល់ បជាធិបោ ៈនេះ ជាឈ្មោះរបស់សក្កៈទាំងអស់។

មានបុណ្យអស្ចារ្យហួសពណ៌នា  ធំលើសទេវតាផងឯទៀត ។
ថ្ងៃងពាទេពតាដែលជាម្ចាស់  កាលផ្លាស់ឋានៈដោយចាក់ស្មៀត
គិតតែកែខ្លួនផ្ទុនស្រាទៀត  ប្រឹងធ្មៀតជ្រៀតជ្រែងលេងសប្បាយ ។
ឥតគួរឥតគិតពិនិត្យឋាន  ពឹតតែកំសាន្តគ្មានក្រហាយ
ស្មានថាខ្លួនជាទេពនិកាយ  នៅសួគ៌ានាយឥតខ្វាយខ្វាត ។
មានអាយុវែងសម្បូរស្រស់  មានឥស្សរិយយសខ្ពស់ពេកក្កាត់
សម្បូណ៌សម្បើមឆ្ពើមសម្បត្តិ  វិស័យបុណ្យពាត់ដូចសួគ៌ា ។
គឺក្នុងទេវលោកយោគសុខសាន្ត  ឥតទុស្ថានថែបយ៉ាងណា
ឯអសុរភពគ្រប់ទិព  ក៏សែនសុខាដូច្នោះឯង ។
ហេតុនេះទើបពួកគេគ្រប់ប្រាណ  មិនបានដឹងខ្លួនផ្លូវវង្វេង
ប្រឹងតែស្មានថាទីនោះឯង  ជាទីកន្លែងសួគ៌ាល័យ ។
លុះដល់វេវត្រូវចាត់ជៀង  ពេលដើមប្រទៀងទិព្វត្រៃឈ
បញ្ចេញបុប្ផាជាវិស័យ  រីកស្រស់ប៉ៃប្រល្អធេតឆាយ ។

---

ស្រាប់តែពួកគេវេតំនិត  វេគិតពិនិត្យដោយក្បាក់កាយ
ថាដើ ! យើងពឹតតែសប្បាយ  គ្មានក្តៅក្រហាយគិតអើពើ ។
ពួកយើងមិនមែនជាទេពតា  នៅឋានសួគ៌ាលោកទេតើ
អាដែងគ្នាយើងពិតជាក្ញើ  ឲ្យសក្កៈធ្វើកលបញ្ឆោត ។

គិតតែពីផឹកទឹកស្រវឹង មួយដបហើយច្រើនថែមមួយប៉ោត
មួយប៉ុន់កាន់ដើររលើងរោជ សក្កៈបញ្ចោតលោតធ្លាក់ទឹក ។
ពួកឯងឃើញទេដើមប្រនៀង ជុះផ្លៀងរៀនផ្កាផ្កាសន្ទឹក
ឯណាដើមបារិច្ឆត្តកព្រឹក្ស[១] វាវឹកហើយយើងគ្មានជើងកាយ ។
ឋានសួគ៌មានដើមបារិច្ឆត្ត ជាទេពសម្បត្តិស្រស់ឆើតឆាយ
ជាទីញុំាងទេវតាទាំងឡាយ ឲ្យក្សាន្តសប្បាយកាយសួស្តី ។
ឥឡូវនេះមានឯប្រនៀង គ្មានសូរសំនៀងសៀងសព្វអ្វី
ឃើ ! ពួកសក្កៈអន្សត្តីយ អប្រិយក្រៃក្រៃព្រលេមើលឆាយធំ ។
ធ្វើយើងឲ្យបង់លង់កាយា លះការពារទេវតាសក្តុទ្ធម
កើតជាអសុរក្សលបាតត្ថ ទុក្ខធំនេះរកប្រៀបពុំបាន ។
ពីដើមគេហៅយើងសុរា ប្រែជាទេវតាក្នុងសួគ៌ឋាន
ឥឡូវបង់ប្រាជ្ញាជាចប្ផាក់ប្រាណ មកបានឋានថៃវប្រែនាមា ។
ទៅជាអសុររុលបពិត ព្រោះតែការក្សត់ពួកទេវតា
ដែលយើងសប្បុរសស្មោះចិន្តា ចាំងលើកសីមាពាក់កណ្ដាល ។

---

១ បារិច្ឆត្តកព្រឹក្ស គឺឈើមទ្វាបុស្បជុះនៅឋានសួគ៌ ។

(នៅមានត)

ផ្នែកអក្សរសាស្ត្រ

# ភាសាសាស្ត្រ និង អក្សរសាស្ត្រខ្មែរ

រៀបរៀងដោយ ឌ. គាម

(តមក)

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នួន
ឲ្យបានខ្ជាប់ខ្លួន គង់វង់គត់មត់ ។
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ ។

ប.ព

## ជំពូកទី ១

មនុស្សសំដែងកាយវិការមិនសូវខុសគ្នាប៉ុន្មានទេ ខ្ញុំសូមលើកយកឧទាហរណ៍ ជនជាតិក្រិក ។ ជនក្រិក ងក់ក្បាលសំដែងន័យថា "បាទ! យល់ព្រម!" ជល់ងើបក្បាលថា "ទេ!" ។ ខេមរជនគ្រវីក្បាលបានន័យថា "ទេ!" ។ នៅក្នុងភាពយន្ត បើគេចង់សម្លាប់មនុស្សដោយមិនចាំទទួលនូវសេចក្តីអង្វរ មេបញ្ជាត្រូវឲ្យសញ្ញាទៅកូនក្រុមដោយលើកមេដៃបង្អុលចុះក្រោម ដោយបញ្ជាក់ន័យថា "សម្លាប់ទៅ!" ។ ទាំងនេះចាត់ថាជា កាយវិការភាសា អក្សរសាស្ត្រគ្មានព្យញ្ជនៈ ។

មនុស្សក្នុងសាកលលោកនេះ ប្រើកាយវិការជាច្រើនជំនួសភាសា ។ មានកាយវិការខ្លះទៀត គេចាត់ថាជាកាយវិការអន្តរជាតិ ដូចជាកាយវិការរបស់កាយឫទ្ធិ ឬអ្នកបើកបរយានជំនិះ ។ កាយវិការភាសានេះ អាចបញ្ជាក់នូវឧត្តមគតិនិងចិត្តគំនិតរបស់មនុស្សបាន ។ ដូចយ៉ាង សំឡេង យំ·សើច·ថ្ងូរ·ត្អូញ . . . . . នេះជាកាយវិការភាសាប្រកបដោយសំឡេង ដែលចាត់ថាជាភាសាគមនាគមន៍អន្តរជាតិស្ដាប់យល់បានថា នេះសើច-យំ-កើតទុក្ខ ។

កាយវិការមួយទៀត គួរយកមកបញ្ជាក់ "មនុស្សម្នាក់យកដៃបក់លិច ៗ មុខសុនខ ដែលមិនធ្លាប់ស្គាល់ ឬក៏ស្គាល់ដែរ រួចយកដៃទះដីនៅក្បែរខ្លួនមនុស្សទៀត "ប្រែជាសេចក្ដីថា មនុស្សនេះ បក់ដៃហៅឆ្កែឲ្យមកណេះ ហើយឲ្យអង្គុយក្បែរខ្លួន" ។ រួចសុនខដើរមកអង្គុយជិតមនុស្ស តើឆ្កែបេះកានសៀវភៅឬទេចុះម្ដេចបានតែវាមកអង្គុយក្បែរមនុស្ស ថាមកពីឆ្កែយល់កាយវិការរបស់មនុស្ស ។

៣– ភាសាសត្វ (Speech of Animal) មិនត្រឹមតែមនុស្សទេ មានកាយវិការជំនួសភាសា សូម្បីតែសត្វក៏មានកាយវិការជំនួសភាសាដែរ សូមសង្កេតមើលមាន់ ។ មាន់ឈ្មោលតែសប្បាយរីករាយចិត្ត វាងារ មាន់ញីឈឺពង វាអក តែក្រោយពងហើយវាក្ដត កាលណាវាបក់ស្លាបវាសំ-ដែងប្រាប់ថា វាគោះពោះកោតខ្លាច ។ ក្របីតែវាខ្លាចគ្នាវាឬមនុស្ស វាតែង

តែបក់កន្ទុយល្វិចៗ ហើយរត់ទៅលិញ្ញាក់ ដើម្បីសំដែងថាគោរពៗ ទាំងនេះចាត់ថាជាភាសាសំរាប់សត្វៗ

សូមសង្កេតពិចារណានូវប្រយោគខ្លះនេះ នៅក្នុងសៀវភៅ (The Gift of Language) ថា បុរសគឺជាមនុស្ស ផ្សេងដោយឡែកពីសត្វលោក ដ្បិចេះត្រូវចេះនិយាយតាំងពីកំណើតដោយខ្លួនឯងៗ ឯស្រ្តីវិញ គឺចេះនិយាយឡើងដោយសារតែអាដាម នៅថ្ងៃដែលអាដាម បានចាត់កំណត់ឲ្យឈ្មោះពួកសត្វលោក....ៗ

ភាសាសត្វដែលគេអាចឲ្យយល់ទៅបាន ក៏ដោយសារតែ " ចលនា » ដែលទាក់ទងទៅនឹងធម្មជាតិមានជីវិតៗ យើងមិនអាចបានដឹងថា តើភាសាដែលកើតឡើងមុនគេនៅកន្លែងណាទេ ព្រោះយើងមិនមានឯកសារ កត់ត្រាចំណាំពីបុព្វសម័យៗ មានវិញ្ញូជនជាច្រើនបានយកខ្សែសំលេង (banque magnetique) ទៅថតសំលេងសត្វស្វាធំៗ (Chimpanzés) ហើយយកមកធ្វើនូវនិរុត្តិសាស្រ្ត (Etymologie) ចំពោះសំលេងនឹងអត្ថភាសាៗ មានវិញ្ញូជនខ្លះទៀត យកម៉ាស៊ីនថតសំលេង ទៅថតសំលេងសត្វផ្សេងៗ សត្វខ្លះមានសំលេងថា កាក! គូក! វូប! ជាដើមៗ

តែយើងអាចកត់សំគាល់បានថា ភាសាសត្វស្វាធំ ( Ape ) មាន

សំឡេងសំនៀងកាន់តែចូលជិតមកសំនៀងសំឡេងភាសាសាស្ត្រ របស់មនុស្ស ។ លោក រ៉ូប៊ែរ ម. យេក្ស (Robert M. Yerks) បានសរសេរសៀវភៅជា (The Great Apes) « ជាសត្វអាចយកទៅបង្ហាត់បង្រៀនឲ្យទៅធ្វើកាយវិការភាសាបាន ដូចជាមនុស្សគថ្លង់ (The Great Apes that these animals might, however be trained to a gesture language much as deaf mutes employ. »

៤– សញ្ញាភាសា (Signals for Words) ឥឡូវយើងត្រឡប់មកភាសាមនុស្សម្ដង ។ គេយើងអាចដឹងថា សញ្ញាភាសាមានចំនួនដែលយើងអាចយល់បានសព្វថ្ងៃនេះ ដែលកើតមកពីភាសានិយាយ ។ មានសំឡេងខ្លះអាចបញ្ជាក់ឲ្យដឹងថា ភ័យ . . . . ប៉ុនប៉ង . . . . ដូចយ៉ាងសញ្ញា "ស្ងាប" មនុស្សច្រើនជាតិដឹងថា "ងងុយគេង" ។

អ្នកនៅទីក្រុង ច្រើនតែចេះសញ្ញាភាសា ដែលមិនមានពាក្យជាគ្រឿងសំគាល់ ។ សញ្ញាភ្លើង ក្រហម–ខៀវ–លឿង ប៉ូលីសលើកដៃជើង ។ល។ សញ្ញាទាំងនេះអាចនាំអ្នកចរាចរឲ្យរួចផុតសេចក្ដីអន្តរាយ ។ នៅសាលារៀន តែគេឮស្គរជួង–ស្គរ គេអាចដឹងថា កូនសិស្សសំរាក ឈប់ចេញរៀន ឬចូលរៀន ។

សញ្ញាគូសតាមផ្លូវ សំរាប់ឲ្យរថយន្តបើកបរ គូសកាត់ផ្លូវ សំរាប់ឲ្យអ្នកដើរកាត់ ។ បើបានឃើញសញ្ញាមួយគួរឲ្យចាប់អារម្មណ៍ គឺសញ្ញា

នៅក្នុងឧមុង្គបថ (Subway ឬ Métro) នៅទីក្រុងនូវយ៉ក (New York) នៅមហាវិថីទី ៤២ នៅខាងលើពិតានឧមុង្គបថនេះ មានគូសពណ៌ប្រផេះ ៗ គំនូសនេះ មានន័យថា "បើអ្នកចង់ទៅជិះរថភ្លើងទៅទិសខាងកើត សូមមកតាមខ្ញុំ" គេគ្មានសរសេរជាអក្សរទេ គេគ្រាន់តែគូសប្រាប់ ៗ

សូមពិនិត្យមើលរថយន្តដឹកទំនិញធ្ងន់ ៗ ដូចដឹកឈើ ឬ ដែកជាដើម នៅខាងក្រោយរថយន្ត គេចងកំណាត់សំពត់ក្រហម ៗ សំពត់ក្រហមនេះ បានន័យថា "ប្រយ័ត្នគ្រោះថ្នាក់! ទៅឲ្យឆ្ងាយ!"

នាគរិក (អ្នកនៅទីក្រុង) ដល់ឃើញសញ្ញាច្រើនដូច្នោះ ស្ទើរតែដូចអនារ្យជន (Primitive) ពួកព្រានគួយជាដើម ៗ ពួកព្រានគួយច្រើនតែគូច-ចង-លាក់ឈើជាចំណាំ សុនខច្រើនយល់ចិត្តមនុស្សដោយម្រាមដៃ, មនុស្សគ ថ្លង់ ច្រើនប្រើដៃ ៗ

៥– ភាសាត្រាប់ (Imitative Words) ភាសាដែលយើងនិយាយអាចយល់បានដោយងាយ ព្រោះជាសញ្ញាភាសា រូបីក្ត អរូបីក្ត ៗ ពាក្យដែលគេគ្រាប់សំឡេងដូច្នោះហៅថា នាមការកភាសា (Onomatopoetic) ៗ តាមការត្រិះរិះមើលទៅតាម ភាសាត្រាប់ នេះទៅ ឃើញថា ប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់ មិនសូវមានភាសាដែលយកលំនាំតាមសំឡេងធម្មជាតិទេ ៗ យើងអាចសង្កេតបានទៅតាមសេចក្ដីនេះបានថា ពួកខ្មែរដូចព្រានគួយជាដើម ច្រើនយកភាសាតាមធម្មជាតិ ៗ

ភាសាខ្មែរយើង ក៏មានពាក្យដែលគ្រាប់យកលំនាំ ឬហេតុដែរ ដូចពាក្យថា " បែកអំពិលអំពែក " ។ ម៉េចបានជាគេនិយាយថាដូច្នេះ ព្រោះថា កាលណាគេចង្កិចក្បាលយ៉ាងខ្លាំងទៅវត្ថុមួយ មានរស្មីព្រិច ៗ ខ្ចាតខ្ចាត់ចេញមក ដូចពន្លឺសត្វអំពិលអំពែក ដូច្នេះគេសន្មតថា " បែកអំពិលអំពែក " ។

## ៦- សង្គមភាសា ឬក្រុមភាសា (Community Words)

បើសិនជាយើងសួរខ្មែរគ្នាឯងថា " អ្នកនិយាយភាសាអ្វី ? " ចម្លើយមុខជាមកដូវនេះថា " ខ្ញុំនិយាយភាសាខ្មែរ " ។ ចុះម៉េចបានជានិយាយភាសាដូចគ្នា ស្តាប់គ្នាមិនបានខ្លះ? មកពីនៅគ្រប់តែប្រទេស មានភាសាសំរាប់សង្គមឬជនបទ ។ ខ្ញុំសូមលើកយកឧទាហរណ៍មួយមកបង្ហាញ " ក្មេងដែលគេចរេះមិនទៅសាលារៀន តាមជនបទខ្លះហៅថា " កាន់កាតឈ្លុស, គ្រក, ខ្មាយ. . . " ។ មិនមែនតែភាសាយើងទេ ដែលនិយមនិយាយ មិនដូចគ្នា សូម្បីតែប្រទេសឯទៀត ក៏និយាយមិនដូចគ្នាដែរ ដូចសហរដ្ឋអាមេរិក " ក្មេងដែលគេចរេះពីសាលារៀនគេនិយាយតាមជនបទខ្លះថា Skip bag day out of school, play hooky ឬ hooks Jack. . . ។

សូមសង្កេតមើលក្មេងមួយក្រុមតាមចំនៀមអ្នកស្រុកខ្លះ ឬខ្ញុំទៅ ខ្ញុំមិនបានយល់ច្បាស់ ។ តែនៅស្រុកយុំខ្ញុំសព្វថ្ងៃនេះ "ក្មេងអង្គុយអាំងភ្លើង

ទៅផ្ទះវិញ ។ ក្មេងតែងទាក់ទងក្មេងក្នុងពេលជាមួយគ្នា ម្នាក់ត្រូវស្ទុះទឹកមាត់ឡើងលើ ម្នាក់ស្ទុះទឹកមាត់ចុះក្រោម មានន័យថាមិនឲ្យដំបៅមាត់ៗ នេះជាភាសាសំពប់សង្គមក្មេងដែរ ។

បើក្មេងលេងល្បែង ដូចលេងល្បែងជិះសេះ គ្រប់អូសរទេះ ឬដល់គ្រប់ជាដើម តែឈប់លេង ក្មេងថា « ណងទិត ក្រោយ ។ លេងទៀត» រួចទើបក្មេងយកដៃធ្វើជាបោសគូថ ។ ការប្រព្រឹត្តិរបស់ក្មេងដូច្នេះ ព្រោះក៏យល់ថា បើមិនធ្វើដូច្នេះទេ ខ្លាចដុះកន្ទុយ ។

បើយើងសង្កេតមើលពួកអ្នកសៀមពប និយាយជាមួយខ្មែរក្រោម ស្ទើរតែស្តាប់គ្នាមិនបានប្រហែលពាក់កណ្តាល ។ ខ្ញុំបានជួបខ្មែរសៀម-ពបម្នាក់ឈ្មោះ ឈរ-គីលិន និយាយជាមួយខ្មែរក្រោមម្នាក់ឈ្មោះប៊ុល នៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក :

គីលិន– ប៊ុល ! ប៊ុល ! រៀនអង់គ្លេសចេះដល់ម៉ាឡាហើយ?

ប៊ុល ធ្វើភ្នែកឡេងឡង់ ព្រោះស្តាប់ពាក្យម៉ាឡាមិនយល់ សូម្បីតែខ្ញុំអ្នកនិពន្ធអត្ថបទនេះក៏ស្តាប់មិនយល់ដែរ ទាល់តែខ្ញុំបញ្ជាប់ខ្មែរសៀមពបជាពាក្យកំផ្លែងថា :

មើល ! ប៊ុល ! យល់ពាក្យថាម៉ាឡាឬទេ ?

ប៊ុល – អត់យល់ទេ

មិត្តខ្ញុំសៀមរាបថា "ខ្ញុំស្មានថាគេស្តាប់បាន" ហើយខ្មែរសៀមរាបពន្យល់ថា ម៉ាំឡា "ដល់ណាហើយ ឬបានច្រើនហើយ" ។

លោក ជន.ប. ការុល (Jonh B. Carroll) និយាយថា "ភាសារបស់សង្គមនីមួយ ៗ មិនងាយឲ្យមានឯកភាពត្រឹមត្រូវបានទេ បើសិនណាជាសង្គមមនុស្ស រីកធំឡើង ភាសាកាន់តែប្រែទៅរកការឃ្លៀងឃ្លាតបន្តិចដែរ ។ ដូច្នេះនៅក្នុងសង្គមនីមួយ ៗ មុខតែមានសំដីលំនាំផ្សេង ៗ ពីគ្នា" ។

សង្គមភាសា បើនិយាយឲ្យច្បាស់ទៅទៀត គេអាចចែកភាសាខ្មែរទៅតាមជនបទ ដូច្នេះយើងត្រូវធ្វើតារាងជាផែនទីគូសចំណាំប្រាប់ថា ជនបទ ឃុំ-ស្រុក-ខេត្តនេះនិយាយរបៀបដូច្នេះ មនុស្សនៅក្នុងខេត្តនោះនិយាយរបៀបដូច្នោះជាដើម ទើបងាយឲ្យអ្នករៀនអាចយល់បានស្រួល ។

ខ្ញុំសូមអធិប្បាយភាសាតាមសង្គម ឬជនបទខ្លះ ដែលខ្ញុំបានជួបប្រទះ តែខ្ញុំសូមអភ័យទោស បើសិនជាខ្វះខុសខាតដូចម្តេច សូមលោកមេត្តាផ្ញើសេចក្តីត្រូវទៅខ្ញុំ ( សូមអរគុណ )

ពិតមែនតែខ្មែរយើងមានភាសាតែមួយសំរាប់ជាតិ តែលំនាំភាសានិយាយតាក់ទៅតាមសង្គមឬជនបទ ដូចអ្នកខេត្តកំពតប្រើពាក្យថា "គុម្ព" តាមន័យក្នុងវចនានុក្រម ឬតាមជនបទសង្គមបានន័យថា "ក្រឡគួច ៗ សំរាប់ដាក់កំបោរ" តែអ្នកខេត្តកំពតសំដៅយក "ពានធំ" ។

សូមពិនិត្យសង្គមភាសាខ្លះដូចតទៅនេះ៖

## ក)- សំដីពាយនាយ

លោកអ្នកធ្លាប់បានធ្វើដំណើរតាមរថយន្ត ទៅតាមព្រែកក្តាម ទៅស្ទឹងកំពង់ចាម មុខជាឮឈ្មួញពាយនាយថា

លក់ហ៎ះ! ក្រូចហ៎ះ! ឈូកហ៎ះ!

ឥឡូវលោកអ្នកជិះរថយន្តទៅតាមផ្លូវកំពង់ព្រែកអ្នកលឿង មុខជាឮឈ្មួញពាយនាយថា: មកហើយលក់!

បើយើងមកកំពង់ ឬ តាមជនបទឯទៀត ៗ យើងមុខតែឮពាក្យពាយនាយដូច្នេះទៅវិញ

លក់ហ៊ើ! លក់! ពោតស្ងោរហ៊ើ! ពោតស្ងោរ!

## ១- សំដីតាមស្រុក ឬ ជនបទ

១- សំដីនិយាយអ្នកខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម ៗ គេច្រើនតែនិយាយបន្តុះបន្ដាប់ពាក្យខ្មែរនេះថា ឡា-លូ-ឡាប់-លៀក (ស្វា-ម្ទូ-ស្វាប់-ស្មៀក) គេនិយាយច្រើនកាត់យកតួអក្សរ ស ចេញ ៗ សូមពិនិត្យមើលភាសាជនបទនៅឃុំស្អាង ស្រុកត្បូងឃ្មុំ កំពង់ចាម ពាក្យថា "លំប៉ាក" មានន័យថា "ចង្រៃ" សំនៀងភាសានេះដូចជាភាសាពួន ៗ

២- ខេត្តតាកែវ សំដីពួកនេះប្លែកពីពួកអ្នកខេត្តក្រចេះ តែស្រដៀងគ្នានៅខេត្តព្រៃវែង-ស្វាយរៀងដែរ ៗ

ពួកខេត្តនេះនិយាយស្រដៀងយួន ព្រោះនៅទល់ដែនយួន ដូចពាក្យដែលមានអក្សរ (ឆ-ស) (ចំពោះអក្សរឆ-ស មាននិយាយនៅក្នុងពួកព្យញ្ជនភាសា)

សូមលើកយកពាក្យខ្លះរបស់អ្នកខេត្តតាកែវ (ឆ.ស.)

ស្គែ - ឆ្ករ – – ឆ្នែង

មើលទៅខ្មែរលើបែបច្រឡំពាក្យនេះហើយ សូមប្រាប់ចុះថា ស្គែ>ឆ្កែ , ឆ្ករ>ស្ករ, ឆ្នែង>ស្នែង

ម្យ៉ាងទៀតសូមពិនិត្យតារាងខាងក្រោមនេះ ដែលមិនសូវស្របគ្នា

| ខ្មែរខេត្តក្រចេះ - ស្ទឹងត្រែង | ខ្មែរខេត្តតាកែវ |
|---|---|
| រវល់តែ . . . . . | អាល័យតែ . . . . |
| ខ. មើចបានជាយូរម្ល៉េះ ? | ខ. មើចបានជាយូរម្ល៉េះ ? |
| ឆ្លើយ : ខ្ញុំរវល់តែចាំមិត្តខ្ញុំ . . . . | ឆ្លើយ : ខ្ញុំអាល័យតែចាំមិត្តខ្ញុំ |
| . . . . . . . . . . . | . . . . . . . . . |

តែចំពោះអ្នកខេត្តក្រចេះ នឹងខេត្តឯទៀតខ្លះ ច្រើនតែនិយាយទាំងពីរ គឺរវល់តែ . . . នឹងអាល័យតែ . . . ។ តែអ្នកខេត្តតាកែវច្រើនតែនិយាយថា អាល័យតែ . . . . ។

៣- ចុះខ្មែរសៀមរាប, កំពង់ធំ, កំពង់ឆ្នាំង, ពោធិសាត់, បាត់-ដំបង និយាយប្លែកពីអ្នកខេត្តខាងលើដូចម្ដេច ? ច្រើនណាស់គ្រាន់តែតួ

អ្នកសៀមរាបមកពី ប៉ាំងាក ឬ អ្នកកំពង់ឆ្នាំង ខ្មែរភ្នំពេញរួចស៊ីកត្រចៀកតែរកវចនានុក្រមឲ្យជួយ ។

## សំដីអ្នកសៀមរាប

លោកអ្នកនានដែលឮពាក្យនេះឬទេ អ្នកសៀមរាបនិយាយដូចថា:

“គោរ៉ាចាប្រាវចូលដុប អេងថាភយអ៊ើយភយ កុំតែបានលោកភិក្ខុមួយអង្គជួយកាក់ ម៉េះលំបាកយ៉ាង„ ថាពួកអ្នកសៀមរាបនិយាយសៀមទៅមិនមែនទេ ថានិយាយបាលីទៅមិនមែនដែរ ចុះម៉េចបានជាគេស្តាប់ពាក្យខ្លះមិនបាន ថាមកពីសង្គមភាសា ឬគ្រាមភាសារបស់ពួកនេះដើមសេចក្តីខាងលើនេះ ប្រែថា „គោរ៉ាផ្ញើលចូលព្រៃគុម្ពោត ឯងថាភ័យអ៊ើយភ័យកុំតែបានលោកភិក្ខុមួយអង្គជួយចញ្ជប់ម៉្មេះលំបាកណាស់„

សង្គមមនុស្សខ្លះ មានសញ្ញាភាសាប្លែកពីគ្នា (សញ្ញាភាសាខ្ញុំអធិប្បាយរួចពីទំព័រខាងដើមហើយ) ។ មានអ្នកស្រុកខ្លះជឿដោយប្រើកាយវិការផ្សេងៗ ដើម្បីកំណត់ឲ្យដឹងនូវគោលបំណង គំនិតរបស់ពួកជននោះ ដូចយ៉ាង “យកដៃដាក់លើក្បាល, យកដៃដាក់លើពោត (ដែលគេយកធ្វើទទេ) „ ដែលឲ្យន័យថា “សូមកុំឲ្យលោះព្រលឹង” ថា “កុំឲ្យពោតសាច” ជាដើម ។ ខ្ញុំសូមជូនឧទាហរណ៍មួយ ដើម្បីប្រៀបគ្នា ជនអាមេរិកកាំង បើគេចង់មានលាភ ជ័យសួស្តី ក្នុងពេលធ្វើដំណើរ គេត្រូវខោកឬគោះឈើដោយក្រញាំម្រាមដៃ អង់គ្លេសថា (Knock on wood)

ឥឡូវយើងបែរមករកមើលវប្បធម៌របស់មនុស្សចំពូកខ្លះ ដូចពាក្យ ឬប្រយោគដែលគេនិយាយលាយតាមពណ៌ ( ស-ខៀវ )

១. ពាក្យ. តស្ងូវ · ណស្ងូវ · យ៉ស៊ុំ . . . .

ប្រែថា ទៅស · នៅស · យស ( ទៅ · នៅ · យ៉ំ. )

ភាសារបៀបនេះ គប្បីចាត់ទុកថាជាភាសាសម្ងាត់ គឺគេមិនចង់ឲ្យអ្នកដទៃទៀតស្តាប់បាន ។

ម្យ៉ាងទៀត សូមពិនិត្យភាសាមួយចំពូកទៀត ដែលគេហៅថាភាសាឫសីប៉ុងសារ ។ ភាសានេះទុកដូចជាកំប៉ាំងមួយដែរ ។ ភាសានេះមានន័យនឹងរបៀបដូច្នេះ ៖

ត្រូវសរសេរឲ្យច្បាស់លាស់ តាមភាសាធម្មតាជាមុនសិន តែត្រូវធ្វើយ៉ាងឲ្យខ្លី ឲ្យល្មមកប់ពាក្យបានងាយ រួចហើយត្រូវកប់អក្សរ បណ្តោយពីដើមទៅចុង ហើយត្រូវដកមួយតួម្តងៗ យកមកសរសេរទៅតាមបន្ទាត់ៗ របៀបកប់អក្សរដូច្នេះ ស្រៈ ប៉ាំងឈើ, អក្សរ, លេខ កប់មួយតួដែរ តែវិសជ្ជនីយគេមិនកប់ថាជាមួយតួទេ ។ ពេលផ្ញើសំបុត្រទៅគេ ដើម្បីឲ្យស្រួលដល់អ្នកទទួលផង បានងាយនោះ ត្រូវប្រាប់យ៉ាងខ្លីថា ២.៣-៤.ឬ ៦ តាមដែលយើងកប់ថា "ដក" ដល់ពេលដែលគេកប់អក្សរយកជាពាក្យវិញថា "ស្រង់" ។ ដកស្រង់នេះ មានចំនួនខុសគ្នាក៏មាន ត្រូវគ្នាក៏មាន ។ បើចង់ប្រើរបៀបដកថាស្រង់ ស្រង់ថាដក បានឥតពាស់ ។

គ្រាមភាសា ឬសង្គមភាសា នៅមានច្រើនទៅទៀត តែជាពាក្យនេះច្រើនតែដូចគ្នា ឬក៏ច្រើនតែជាវប្បធម៌ប្រែប្រួលដូចតទៅនេះ៖

១– របៀបដក ៣ ស្រង់ ៣: (តាមវចនានុក្រមខ្មែរភាគ ២)

ល្អក្រចិមិយូត្តនរ > ចិត្តល្អមិនក្រយូរ

របៀបកប់ដូច្នេះ: ពាក្យ "ចិត្តល្អមិនក្រយូរ" មាន ៨ ពាក្យ ។ គេកប់ពាក្យដើម :

ចិ ត្ត ល្អ មិ ន ក្រ យូ រ

១ ២ ៣ ៤ ៥ ៦ ៧ ៨

ដក: ល្អ ក្រ ចិ មិ យូ ត្ត ន រ

៣ ៦ ១ ៤ ២ ១ ៥ ៨

ផលដកមកបានដូច្នេះ ល្អក្រចិមិយូត្តនរ ត្រូវផ្សូវត្រង់ស្រង់យកជាសេចក្តីដើមវិញ

ស្រង់: ចិ ត្ត ល្អ មិ ន ក្រ យូ រ

១ ២ ៣ ៤ ៥ ៦ ៧ ៨

២– របៀបដក ២ ស្រង់ ៤ ឬដក ៤ ស្រង់ ២ :

ចះនចមេិឈ្នះង់ > ចេះមិនឈ្នះចង់

មាន ៧ ពាក្យ ។ (នៅមានរបៀបច្រើនទៀត)

ក) ពាក្យបង្វែងជាន យើងធ្លាប់ឮខ្លះមកហើយដូចជាព្រះ-សង្ឃ ត្រូវការឆាន់ «មួស» លោកប្រើកូនសិស្សទៅរកមួស លោកមានពុទ្ធដីកាថា «សត្វហើរ» ។ រឿងនេះជាហេតុនាំឲ្យក្មេងដែលមិនយល់ន័យពាក្យនេះ ស្មានថាលោកបញ្ជាឲ្យទៅដេញចាប់សត្វមានជីវិត ម្ល៉ោះហើយទៅដេញវាយសត្វកន្ធាយមួយបានទៅប្រគេនលោក ។ ឧបា-សក-សិកា ឃើញត្រីរស់ នឹកចង់ស៊ីដែរ តែមិនហ៊ានប្រាប់ឲ្យគេសម្លាប់ ក៏ថាឲ្យយកទៅលែង តែបើយើងមិនយល់ន័យនេះមុខតែយកទៅលែងនៅបាតបឹងផ្លូក ។ ពាក្យពិតវិញនោះមិនមែន «សត្វកន្ធាយ» មិនមែន «យកទៅបោះចោលទេ» គឺ «សត្វហើរ ជាមួស» «លែងថាឲ្យទៅសម្លាប់» ។ ពាក្យទាំងនេះជាពាក្យបង្វែងជាន ពាក្យរបៀបនេះ នៅមានច្រើនទៀត ។

## ១)- ពាក្យអាស្រ្គាម ឬពាក្យបំអេសបំអាស

ពាក្យអាស្រ្គាម ខ្ញុំមិនបាច់អធិប្បាយទេ ព្រោះថាលោកអ្នកធ្លាប់ឮមកជាញឹកញយហើយ ។

សង្គមភាសាមានថ្នាក់ៗគ្នា គេមានភាសាពិសេសច្រើនទៀត ទុកប្រចាំកិច្ចការរបស់គេ ដូចជាភាសាអ្នកបរបាញ់-ភាសាចំបាំង-ឬភាសាសំ-រាប់អ្នកលែងល្បែង ។ល។ តែលុះកន្លងក្រោយៗ មកជាច្រើនកំណាព្យដ

ឬច្រើនសតវត្សរ៍មក  កាលដែលខ្មែរមិនទាន់មានអក្សរសាស្ត្រនៅឡើយ ភាសាប្រចាំក្រុមមុខការងារនោះ ក៏បាត់បោលខ្លះដែរ ។ ម៉េចបានជាភាសាខ្លះបាត់ទៅ មកតែពីភាសានោះ មិនសូវមានសារប្រយោជន៍ បើមិនប្រើក៏បានដែរ ហើយមួយទៀតយូរៗធ្វើម្ដង ហើយទំនងជាគ្មានអ្នកកត់ចំណាំ ម៉្លោះហើយក៏សាបសូន្យទៅ តែចំណែកភាសាដូចជាភាសារបស់ពួកអ្នកចំបាំង-ពួកអារក្ស-របៀបការកូន  ដែលជាភាសាសំពប់សាងជីវិត គេនៅរក្សាទុករហូតមកដល់សព្វថ្ងៃ ។

ភាសាបរបាញ់ តាមមតិរបស់លោក (Edward D. Myers) និយាយអំពីកំណើតរបស់ភាសា (The Origin of Language) ថា ពីដើមភាសាបរបាញ់មានគ្រប់សង្គម តែគេរៀបទៅបាញ់ គេលើកគ្នាទៅ ឬគេទៅបាញ់សត្វនៅតាមផ្លូវដែលគេត្រូវចេញទៅបាញ់ តែក្រោយមកអ្នកខ្លះលួចទៅម្នាក់ឯង ហើយមិនហ៊ានបញ្ចេញសំឡេង-សំរែកអ្វីទេ ខ្លាចគេដឹងឮ ។ បើតាមខ្ញុំពិនិត្យមើលទៅតាមមតិលោកខាងលើនេះ ឃើញថាប្រហែលជា ២០ ឆ្នាំមុននេះ នៅស្រុកខ្លះ គេលើកគ្នាទៅបាញ់សត្វមែន ។

ភាសាបរបាញ់ គេត្រូវនិយាយ ឬ ប្រើពាក្យសំដីទៅតាមសំរែករបស់សត្វ ឬលំនាំរបស់សត្វ ដូចការបរបាញ់ប្រើសក្ដាន់ អ្នកប្រមាញ់ខ្លះយកស្លឹកឈើមកផ្លុំធ្វើជាសំឡេងសត្វ ។ អ្នកទាក់លលក ធ្វើត្រាប់សំ-

ទៀនលលក គុកត្រូ! គុកត្រូ! ដើម្បីឲ្យលលកព្រមករកលលកញាក់ ។ ចំណែកអ្នកទាក់ក្រួចវិញ គេក៏ធ្វើសំឡេងដូចក្រួច ដើម្បីឲ្យក្រួចមកចូលលប់ ។

ភាសាទាក់ដំរី យើងពិនិត្យមើលស្រុកខ្មែរទៀត មិនថាសម័យមុនទេ សម័យយើងនេះ អ្នកទៅទាក់ដំរី គេច្រើនតែប្រើស្នែង ផ្លុំស្នែងជាបទ ដើម្បីដាក់ស្នេហ៍ឲ្យដំរីទន់ចិត្ត ។

ខាងអ្នកស្ទូចត្រី គេមានភាសាប្លែកទៅទៀតសំរាប់ក្រុមគេដែរ ។ បើលោកអ្នកធ្លាប់ជាអ្នកស្ទូចនៅតាមស្រុកស្រែ លោកអ្នកមុខតែឃើញអ្នកស្ទូច "គោះទឹក" ដែលមានន័យថា "ហៅត្រី" ឬផ្ទាត់ទឹកនឹងម្រាមដៃហើយពោលថា "មកវើយស៊ីចំណី" អាការៈបែបនេះបង្ហាញឲ្យឃើញថា នេះជាភាសារបស់ក្រុមគេនេះដែរ ។

## ភាសាខាងល្បែង

កីឡាអុំទូកង : ពួកអ្នកកីឡាអុំទូកង គេតែងមានពាក្យគេសំរាប់បន្ទរ ឬស្រែកឲ្យមានកំលាំង អ្នកក្បាលស្រែកថា "មួយយើ!" ហើយអ្នកអុំទាំងអស់គ្នាស្រែកព្រមគ្នាថា "មួយ!" រួចបន្ទាប់ទៀត គេស្រែកព្រមគ្នាថា "អែយ៉ូវសាប់ អៃយោមួយ!"

កីឡាអន្ទញ់ : នៅក្នុងកីឡានេះ គេប្រើពាក្យថា "មាយ" គឺគេនិយាយចំពោះអន្ទញ់ណាដែលបោះត្រូវម្តងហើយ តែបោះត្រូវម្តងទៀត

គេថា " ម៉ាយ " ។ ដក, ណាប់, ប្រែត, ចាក់កន្ទក, ស៊ុទ្ធតែជាពាក្យសំរាប់អ្នកលេងអង្គុញ ។

កីឡាឯទៀត ៗ ដូចកីឡាទាត់កូនគោល គេស្រែកថា " បាក់ " ដើម្បីឱ្យអ្នកម្ខាងប្រុងប្រយ័ត្ន ក្រែងគេទាត់ត្រូវជើង ។

ល្បែងចាប់កូនខ្លែង អ្នកលេងឈរទុបចង្កេះ ឬ កាន់ចង្កេះបន្តគ្នា អ្នកនៅមុខគេធ្វើជាមេមាន់ អ្នកនៅក្រោយជាកូនមាន់ រួចមានម្នាក់ទៀតធ្វើជាមេខ្លែងចាំចាប់កូនមាន់ ។ អ្នកលេងស្រែកថា " ចាប់កូនខ្លែងប្រខ្លែង កូនមាន់យកមេទៅ ទាន់យកមាន់ទៅលាក់ លាក់ឯណា . . . " ។

ល្បែងលាក់កន្សែង អ្នកលេងអង្គុយជុំគ្នាជុំវិញ មានម្នាក់កាន់ក្រមា ឬ កន្សែងមូរឲ្យណែនរត់ក្រឡឹងជុំវិញថាលាក់កន្សែង ឆ្មាខាំកែង អួសលោងៗ . . . ហើយគេដាក់មូរកន្សែងនៅក្រោយខ្នងអ្នកអង្គុយម្នាក់ ដល់អ្នកនោះដើរមកកន្លែងដែលគេទុកកន្សែងនោះវិញ អ្នកអង្គុយមិនដឹងខ្លួនគេត្រូវវាយមួយកន្សែង ។ បើសិនជាអ្នកអង្គុយឃើញកន្សែងនៅក្រោយខ្នងត្រូវយកកន្សែងហើយដើរជុំវិញខាងក្រោយអ្នកអង្គុយ ហើយស្រែកថា លាក់កន្សែង . . . . " ។

ឯល្បែងអុក គេថា " អុក " បានន័យថាគេប្រុងស៊ីស្តេចហើយ ។

យើងឃើញហើយថា សង្គមមួយ ៗ មានភាសាប្រចាំក្រុម ៗ ឥឡូវមើលកូនក្មេងលេងល្បែងម្ដង ក្មេង ៗ ច្រើនតែជ្រើសរើសគ្នាថា " ប៉ាវយ៉ីស៊ុង " បើអ្នកណាចាញ់គេត្រូវចាំទី បើឈ្នះគេត្រូវធ្វើ ឬ ផ្ដើមលេងមុនគេ ដូចជាបោះឡូជាដើម ។ បើមិនថារបៀបនេះទេ គឺគេថា " ក្រាយក្រក ក្រាយៈក្រង់ប៉ាក់កាអេងណាំងៀកប៉ាក់កាងៀក ដូយ៉ាំដីកាដាហិច " ៗ របៀបនេះ បើអ្នកណានៅសល់ក្រោយគេត្រូវចាំទីៗ

## ៣- ភាសាសំរាប់អារក្ស ឬ អាគមភាសា (Magic Words)

ក)- ភាសាប្រើក្នុងអារក្ស បើហៅថា ព្រហ្មញ្ញភាសាក៏សឹងតែបាន ៗ ភាសាអារក្សស្ទើរតែមានមនុស្សតិចណាស់ ដែលចេះភាសា ៗ បញ្ជាជនដែលមិនសូវជឿអារក្សអ្នកតា ស្ទើរតែមិនដឹងន័យភាសានេះអស់ទៅហើយ ៗ

( នៅមានត )

# ពាក្យខ្មែរប្រែពីបរទេស

## ដោយគណៈកម្មការជាតិនៃការសិក្សា ផ្នែកអក្សរ " ក "

( តមក )

Paragraphe (n.f.) — កថាខណ្ឌ ( ព.ប្ប ) : ចំណែកនៃផ្នែក ។

Partie (n.f.) — ភាគ ( ព.ប្ប. )

Peine (n.f.) — ទោស ( ព.ប្ប. )

Prescription de l'action — អាជ្ញាយុកាលនៃបណ្ដឹង ( ព.ប្ប. )

Prescription de l'acquisition — អាជ្ញាយុកាលនៃលទ្ធកម្ម ( ព.ប្ប. )

Prescription de la peine — អាជ្ញាយុកាលនៃទោស ( ព.ប្ប. ) : គឺការផុតរលត់សិទ្ធិធ្វើទោស ដោយហេតុថា កាលបរិច្ឆេទនៃការដាក់ទោស ឃ្លាតឆ្ងាយអំពីកាលបរិច្ឆេទនៃការទទួលទោស យូរអង្វែងពេក ។ ឧ. អាជ្ញាយុកាលនៃទោសឧក្រិដ្ឋមានកំណត់ ២០ ឆ្នាំ ។

Prononcer la peine — ធ្វើទោស

Purger la peine — រងទោស

Régnicole (n. & adj.) — រដ្ឋវាសី

Réprimer une infraction — និគ្រោះបទល្មើសមួយ ។

Répression (n.f.) — និគ្រោះ

Répressif (adj.) — និគ្រោះ

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

*ព្រះមហា ចាំង. ទាត់ រៀបរៀង*

(តមក)

---

អតិវ្ឫទ្ធ គុ. ដែលចំរើនក្រៃលែង, ធំ, ប្រសើរ ។

អតិវ្ឫទ្ធិ ស្ត្រី. សេចក្តីចំរើនក្រៃលែង ។

អតិវ្ឫឞ្ដ ធាតុ. ភ្លៀងក្រៃលែង ។

អតិវ្ឫឞ្ដិ ស្ត្រី. កិរិយាភ្លៀងក្រៃលែង ។

អតិវេគវត៑ គុ. ដែលមានសន្ទុះក្រៃលែង, ដែលមានល្បឿន ។

អតិវេទនា ស្ត្រី. វេទនាក្រៃលែង

អតិវេបថុមត៑ គុ. ដែលញាប់ញ័រក្រៃលែង ។

អតិវៃចក្សណ្យ នបុំ. ភាពនៃការពិចារណាឃើញច្បាស់ក្រៃលែង,ការពិសោធន៍ ។

អតិវៃឝស គុ. ដែលគួរស្លាប់ក្រៃលែង,ដែលដល់ស្លាប់ក្រៃលែង ។

អតិវៃឞម្យ នបុំ. ភាពនៃ (ផែនដី) មានភាគស្មើគ្នាទៅប្រាសហើយក្រៃលែង, ភាពមិនស្មើគ្នា ។

អតិវ្យថិត គុ. ដែលឈឺចាប់ក្រៃលែង ។

(នៅមានត)

# រឿងសាមកុក

## កណ្ឌទី ២៨

ទកញ្ញាវិបុលភជសេនា ឆ្វ-ការ ង ប្រែរៀបរៀង

( តមក )

---

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាសបើបានអាន
នឹងបេះទយាយកលចំណាន
ទាំងមានសន្តានស្នេហាជាតិ

យូរ - អ៊ុន

ឡៅពីថា ស្រុកកេងជីវនេះ ក៏ស្ងប់កបតាបហើយ បើនឹងយកអ្នកឲ្យនៅផងក៏មិនសមគួរ ឃើញនៅទំនេរតែស្រុកឡូយគៀងខាងទិសបូព៌ា គៀងទត្តបម្លាយផ្លូវពីនេះទៅប្រហែល ១.៣០០ សិន (៨២ គ.ម.) មិនទាន់មានចៅហ្វាយស្រុកថ្មី អញ្ជើញអ្នកទៅស្រដីកជការធ្វើជាចៅហ្វាយស្រុក ខែត្រនោះសិនចុះ, បើថ្ងៃក្រោយមានទីដខែត្រក្រៅពីនោះគួរសមសឹមខ្ញុំឲ្យផ្លាស់ចេញពីទីនោះ ។ ប៉ាំងថងក៏គិតក្នុងចិត្តថាឡៅពីនេះមើលងាយហើយមិនកប់អានអញសោះបើអញនៅសន្ទានាឲ្យឃើញសតិបញ្ញាសោតខ្ញុំងបេងក៏មិននៅទៀត ត្រូវតែប្រថុយខ្លួលទៅចុះ គិតដូច្នោះហើយក៏លាឡៅពីទៅ ។

លុះទៅដល់ស្រុកឡុយអៀងកាលណា ប៉ាំងថង់ក៏ចេះតែផឹកស្រាស៊ីដេក ក្រោកពីដំណេកផឹកស្រាមិននិយាយការរាជការសោះ, បណ្ដារាស្ត្រក្នុងស្រុកនោះពាស់អព្យាស្រ័យ ក៏ចូលមកស្រដីថ្លឹងថ្លល់ដល់ឡៅពីថា ប៉ាំងថង់ចេះតែផឹកស្រាស្រវឹង គ្មានប្រឹងនិយាយការដោះសុខទុក្ខបណ្ដារាស្ត្រ តាមសណ្ដាប់ធ្នាប់អ្នកធំសោះ ។ ឡៅពីឮដូច្នោះខឹងណាស់ក៏និយាយថា ប៉ាំងថង់នោះជាមនុស្សមិនល្អនាំឲ្យយើងខូចការ ក៏ចាត់ប្រើទៀវហ៊ុយជាអាជ្ញាកណ្ដាល ទៅមើលប៉ាំងថង់ឯស្រុកឡុយអៀង បើឃើញមិនយកចិត្តទុកដាក់នឹងធ្វើរាជការពិតប្រាកដ ដូចពាក្យរាស្ត្រមកប្ដឹងមែន ត្រូវឲ្យបញ្ជូនខ្លួនមក គិតហើយក៏ត្រឡប់មានស្មារតីថា ទៀវហ៊ុយធ្វើការអ៊ូរមែងប្រឡើសបើសណាស់ ក៏ឲ្យស៊ុនខៀនទៅអមជាមួយផង ដើម្បីនឹងបានជួយមើលការខុសត្រូវ ។

ទៀវហ៊ុយ, ស៊ុនខៀន នឹងពាហានក៏នាំគ្នាទៅដល់ស្រុកឡុយអៀង ឃើញតែពួកពាហាននឹងរាស្ត្រនាំគ្នាចេញមកទទួលក្រៅស្រុក មិនបានឃើញប៉ាំងថង់ចៅហ្វាយស្រុកចេញមកគួរសមតាមធម្មតា ទៀវហ៊ុយសួរថា ចៅហ្វាយស្រុកទៅណា បានជាមិនចេញមកទទួលយើង ។ រាស្ត្រទាំងអស់ឆ្លើយថា លោកចៅហ្វាយស្រុកផឹកស្រាស្រវឹងដេកលក់ទៅហើយ ។ ទៀវហ៊ុយឮដូច្នោះក៏ខឹងណាស់ បង្គាប់ពាហានឲ្យទៅចាប់ខ្លួនប៉ាំងថង់នាំមក ។ ស៊ុនខៀនក៏ហាមឃាត់ទៀវហ៊ុយថា កុំអាលខឹងប្រឡោតមើល-

នាយគេ ត្រូវយើងចូលទៅក្នុងស្រុក យកខ្លួនមកសាកសួរឲ្យដឹងការណ៍ខុសត្រូវសិន បើពិតប្រាកដដូចពាក្យរាស្ត្រទៅប្ដឹងសារទុក្ខមែន សុំមេធ្វើតាមទោស ។ ទៀតហ៊ុយឮដូច្នោះក៏យល់ឃើញត្រូវ ទើបនាំគ្នាចូលទៅសាលាកណ្ដាល ហើយឲ្យបំរើចូលទៅហៅខ្លួនប៉ាំងថង់ចេញមក ។ បំរើចូលទៅឃើញប៉ាំងថង់កំពុងស្រវឹងស្រា ក៏ត្រាចេញមកអង្គុយ ។ ទៀតហ៊ុយឃើញប៉ាំងថង់ស្រវឹងជ្រុលដូច្នោះទឹងណាស់និយាយថា បងខ្ញុំយល់ឃើញថា អ្នកជាមនុស្សល្អបានជាឲ្យមកធ្វើចៅហ្វាយស្រុក ហេតុម្ដេចអ្នកមកអង្គុយសំកុកផឹកតែស្រា លះបង់ការពជការមុខងាររបស់ខ្លួនសូន្យសោះ ។ ប៉ាំងថង់ឮដូច្នោះក៏អស់សំណើចហើយថា អ្នកមកនិយាយថា យើងលះបង់ការពជការមុខងារក្នុងខែត្រនោះ តើលះបង់ដូចម្ដេច? ។

ទៀតហ៊ុយថា អ្នកមករក្សាសេចក្ដីសុខទុក្ខរាស្ត្រក្នុងស្រុកនេះជាង ១០០ ថ្ងៃហើយ ចេះតែផឹកស្រាមិនបានកាត់សេចក្ដីតាមពាក្យបណ្ដឹងដែលរាស្ត្រប្ដឹង ទាល់តែប្រជារាស្ត្រចូលទៅសារទុក្ខ ។ ប៉ាំងថង់ថា ស្រុកនេះតូចណាស់ ក្រអ៊ីទឹងកាត់សេចក្ដីប៉ុណ្ណោះ អញ្ជើញអង្គុយចាំខ្ញុំមួយស្របក់ចុះ ខ្ញុំនឹងជំរះកាត់សេចក្ដីដែលរាស្ត្រប្ដឹងនោះឲ្យអ្នកស្ដាប់ ប៉ាំងថង់ក៏ឲ្យយកពាក្យបណ្ដឹងទាំងចោទទាំងចំលើយ ហើយឲ្យហៅគូក្ដីទាំងសងខាងមកអង្គុយរៀងគ្នាពេញទាំងសាលា ហើយឲ្យស្មៀនសូត្រសារពាក្យបណ្ដឹងដឹងចម្លើយទៅវិញទៅមកចប់ចុះ គ្រាចៀកប៉ាំងថង់នោះក៏ផ្ទៀងស្ដាប់ ដៃក៏

ចាប់ពិតសរសេរកត់ត្រា មាត់ពិភាក្សាកាត់សេចក្ដីវៃរហ័សទាំងដៃទាំងមាត់ស្ទាត់ទាំងស្ដាប់ចំណាប់ទាំងស្មារតីវៃទាំងប្រាជ្ញាព្រមគ្នា តែមួយស្របក់ក៏កាត់អស់សេចក្ដីទាំងប៉ុន្មានគ្មានទាស់អព្យាស្រ័យនៃគូក្ដីណាមួយ ត្រូវសេចក្ដីតាមច្បាប់គ្រប់មាត្រា សារក្រមដែលពិភាក្សាក៏សរសេររួចជាស្រេច ។ អស់អាណាប្រជានុរាស្ត្រទាំងឡាយ ក៏នាំគ្នាកោតសរសើរតម្រិះប្រាជ្ញាអឹងកង់ទូទៅ ។ ចាំងថងក៏និយាយនឹងទៀវហ៊ុយថា ខ្ញុំលះបង់មុខការនោះសោត តើមុខការអ្វី ? សូមជាមកទៀតចុះ ។ ទៀវហ៊ុយថា សេចក្ដីទាំងអម្បាលនេះក៏អស់រលីងទៅហើយ ។ ចាំងថងថា បើសេចក្ដីតែត្រឹមប៉ុណ្ណោះទេនឹងជាអ្វី ខ្ញុំនឹងនិយាយមិនបានឬ ? តែមិនសប្បាយចិត្តបានជាមិនរវល់នឹងជំរះកាត់សេចក្ដី ពោះបើរាជការខាងបូឆូនឹងស៊ុនគួនក្ដី ក៏មិនដូចជាខ្ញុំចាប់សរសេរអក្សរលើបាតដៃប៉ុណ្ណោះ បើលាដៃមើលកាលណាក៏នឹងឃើញច្បាស់កាលនោះទាំងអស់ ។ ទៀវហ៊ុយឮដូច្នោះ ក៏តក់ស្លុតក្នុងចិត្តនិយាយនឹងចាំងថងថា ឡៅពីនឹងខ្ញុំពុំបានដឹងសោះឡើយថា អ្នកមានតម្រិះប្រាជ្ញាដល់ប៉ុណ្ណោះ គិតថាអ្នកលះបង់ការរាជការសោះ បានជាប្រើខ្ញុំមកពិនិត្យមើល ដើម្បីនឹងបានជួយដាស់តឿនកុំឲ្យធ្វស់ធ្វោយ ឥឡូវខ្ញុំមកឃើញច្បាស់នឹងភ្នែកហើយ នឹងវិលទៅជំរាបឡៅពីឲ្យជ្រាបកិច្ចការវិញ ។ ចាំងថងក៏យកសំបុត្រឡោសុកឲ្យមកដល់ឡៅពីនោះឲ្យស៊ុនខៀនបើកមើលឲ្យទៀវហ៊ុយស្ដាប់ ។

ទៀតហើយពុះសេចក្តីសំបុត្រនោះសព្វគ្រប់ ក៏សួរប៉ាំងថងថា កាលដែលអ្នកមកជួបនឹងឡៅតីនោះ ហេតុអ្វីក៏មិនឲ្យសំបុត្រនេះទៅឡៅតីមើល ៗ ប៉ាំងថងថា កាលជួបគ្នាពីដំបូងនោះ ឡៅតីក៏មិនបានដឹងថាខ្លួនខ្ញុំដូចម្ដេចសោះ បើនឹងបង្ហាញសំបុត្រនោះឲ្យមើល ក៏ហាក់ដូចខ្ញុំកែងសុំសំបុត្រគេមកបង្អួតខ្លួនឯង ទុកឲ្យអ្នកដទៃសរសើរជំនួសវិញវិសេសជាង រួចសឹមបង្ហាញសំបុត្រនេះជាកស្តុតាង ៗ ទៀតហើយក៏និយាយនឹងស៊ិនខៀនថា បើកុំតែអ្នកឃាត់ឃាំងកំផកខ្ញុំពីដំបូងនឹងមិនជ្រួលខ្ជូចការទៅទេឬ ? ជាតែប៉ុណ្ណោះហើយ ទៀតហើយនឹងស៊ិនខៀន ក៏លាប៉ាំងថងទៅស្រុកកេងជីវិញ លុះទៅដល់ក៏ពណនាសេចក្តីឲ្យឡៅតីស្តាប់គ្រប់ប្រការ ហើយហុចសំបុត្រឲ្យឡៅតីមើលដែលមានសេចក្តីថា :

" ប៉ាំងថងនេះ បានរៀនសូត្រចេះដឹងវិជ្ជាសិល្បសាស្ត្រច្រើនណាស់ ជាមនុស្សមានតម្រេះប្រាជ្ញាគួរតាំងជាទីប្រឹក្សាលោកបាន បើនឹងក្រឡេកមើលខ្លួនប្រាណ ក៏ឃើញថា រូបកាយខាងក្រៅមិនសមជាអ្នកមានតម្រេះប្រាជ្ញាសោះ ខ្ញុំមានសេចក្តីស្តាយស្រណោះប៉ាំងថងណាស់ ខ្លាចក្រែងស្ទើងស្ទុះទៅនៅនឹងអ្នកដទៃទៀត ទើបខ្ញុំចំធៀតសរសេរសំបុត្រឲ្យប៉ាំងថងកាន់មកជួបនឹងលោកស៊ិន " ៗ

ឡៅតីបានឃើញសំបុត្រដូច្នោះ ក៏នៅគិតត្រិះរិះសន្ទិះសង្ស័យទទួល តាហានចូលទៅថ្លែងសេចក្តីថា ខុងបេងត្រឡប់មកវិញហើយ ៗ ឡៅតី

ក៏ចេញទៅទទួលចូលមក ហើយខុនបេនសួរថា ប៉ាំងចងបានមកនៅនឹងលោក តើគេបានសេចក្តីសុខសប្បាយទេឬ ? ។ ឡៅតៃកុងឆ្លើយថា ប៉ាំងចងបានមកជួបនឹងខ្ញុំ ។ ក៏តាំងឲ្យទៅធ្វើចៅហ្វាយស្រុកឡយអៀង ចេះតែលះបង់ការងារមិនបានត្រួតត្រានិយាយឲ្យរាស្ត្របានសេចក្តីសុខចិត្ត គិតតែផឹកស្រាព្រឹកល្ងាចជានិច្ច ហើយដេកធ្មេចមិនធ្វើការអ្វីសោះ ។ ខុនបេនឮដូច្នោះ ក៏អស់សំណើចហើយថា ប៉ាំងចងនេះជាមនុស្សបានរៀនវិជ្ជាចេះដឹងមានតម្រិះប្រាជ្ញាច្រើនណាស់ ចំពោះគេនឹងខ្ញុំពុំមែនដូចគ្នាទេ គេចេះជាងខ្ញុំ ១០ ភាគទៅទៀត ខ្ញុំបានសរសេរសំបុត្រផ្ញើទុកជូនលោកមួយច្បាប់ផង ប៉ាំងចងជូនមកលោកឃើញឬទេ ។ ឡៅតៃឆ្លើយថា ថ្ងៃនេះ បានឃើញតែសំបុត្រឡោសុកផ្ញើមក ឯសំបុត្ររបស់លោកមិនបានឃើញនៅឡើយ ។

ខុនបេនថា លោកតាំងប៉ាំងចងឲ្យធ្វើចៅហ្វាយស្រុកឡយអៀងដែលជាស្រុកតូចនោះ ប្រហែលជាពាស់ចិត្ត បានជាកុងលះបង់មុខការងាររាជការ ផឹកតែស្រាស៊ីដេកដូច្នេះ ។ ឡៅតៃថា បើទៀវហ៊ុយមិនមកប្រាប់ ក៏នឹងខូចអសារមនុស្សមានប្រាជ្ញាម្នាក់ទៅសោះ ហើយខុនបេនក៏ប្រើទៀវហ៊ុយឲ្យទៅអញ្ជើញប៉ាំងចងមក ។ ទៀវហ៊ុយក៏ទៅអញ្ជើញប៉ាំងឯស្រុកឡយអៀងមកដល់ស្រុកកេងជីវ ។ ឡៅតៃ ខុនបេន ក៏នាំគ្នាចេញទៅទទួលប៉ាំងចងដល់ក្រៅទ្វារស្រុកគំនាប់គ្នាតាមទំនៀម ហើយ

ឡៅពិកនិយាយនឹងប៉ាំងចង់ថា ខ្ញុំជាមនុស្សគិតស្រាលហើស ទើបមិនបានស្គាល់ច្បាស់ថា អ្នកមានគម្រេះប្រាជ្ញ តាត់ប្រើអ្នកឡូពៅធ្វើកដការស្រុកតូចនោះ ខ្ញុំសុំសាកោពទទួលខុស ឲ្យអ្នកអនុគ្រោះលើកទោសម្តងចុះ លុះនិយាយហើយក៏នាំគ្នាទៅអង្គុយលើគេហស្ថាន ។ ប៉ាំងថង់ក៏យកសំបុត្រខុងបេងបង្ហាញទៅឡៅពី ។ ទទួលយកមកមើលឃើញសេចក្តីថា៖

"ហង់ស៊ូដែលជាឈ្មោះប៉ាំងថង់នោះ បើបានមកដល់វេលាណា សូមឲ្យឡៅពីទទួលរក្សាទុកចុះ ព្រោះនឹងបានជួយធ្វើកដការ" ។

ឡៅពីឃើញសំបុត្រដូច្នោះ ក៏មានចិត្តសោមនស្សត្រេកអរណាស់ថាៈ "ខ្ញុំភ្លេចស្មូឡសោះ ទើបតែនឹងលើកនឹកឃើញពាក្យសុម៉ាតេកជោជាអាចារ្យបាននិយាយទុកនឹងខ្ញុំថា ហុកឡុងនោះគឺៈ ខុងបេង ហង់ស៊ូគឺប៉ាំងថង ទាំង ២ នាក់នេះ បើបានតែឈ្មោះណាមួយ ក៏នឹងជួយប្រាមប្រាថសត្រូវផែនដីបាន គ្រានេះ ក៏បានមកព្រមគ្នាទាំងពីរនាក់ហើយ គួរតែទំនុកបំរុងផែនដីព្រះចៅហៀនតេ ឲ្យបានរុងរឿងតទៅ ទើបតាំងប៉ាំង-ថងជាទីប្រឹក្សាជាមួយគ្នានឹងខុងបេង ឲ្យជួយទំប្រឹងបង្ហាត់សេនាទាហានឲ្យចំណានស្ទាត់ក្នុងក្បួនពិជ័យសង្គ្រាម ព្រមទាំងកិច្ចការរាជការគ្រប់ជំពូកក្នុងស្រុកទេស ក៏ជាសិទ្ធិដល់ខុងបេងនឹងប៉ាំងថងតាត់តែងត្រួតត្រាទាំងអស់ ។

ពួកអ្នកស៊ើបការ ក៏នាំយកពត៌មានទៅឲ្យដំណឹងចូឆូ ឯស្រុកហ៊ូគោ ថា ទៀវពីបានខុងបេងទឹងប៉ាំងថងមកជាទីប្រឹក្សា ប្រើប្រាជ្ញាបញ្ចុះបញ្ចូល សេនាពហានទឹងប្រមូលឲ្យបានស្បៀងអាហារ នូវគ្រឿងសាស្ត្រាវុធជាច្រើនណាស់ មុខជាទឹងរួមគំនិតគ្នាជាស្រឡះទៅខាងស៊ុនគួន ហើយលើកទ័ពមកដោយអាការគុំគួនទឹងធ្វើអន្តរាយលោកជាប្រាកដ ។ ចូឆូឮដូច្នោះ ក៏ឲ្យប្រមូលទីប្រឹក្សាទឹងសេនាពហានមកប្រជុំពិគ្រោះ ដើម្បីទឹងលើកទ័ពទៅខាងទិសទក្សិណ ។

ស៊ុនហ៊ុវក៏ជំរាបចូឆូថា ខ្ញុំបាទយល់ថា ជីវយីទើបនឹងស្លាប់ មិនទាន់មានមេកងទ័ពនឹងទីប្រឹក្សាទេ គួរនឹងលើកទ័ពទៅវាយយកស្រុកកាំងតាំង គង់នឹងបានដោយស្រួល រួចសឹមលើកទៅវាយយកស្រុកកេងជីវទៀត ។ ចូឆូថា យើងនឹងលើកទ័ពទៅ ផ្លូវក៏ឆ្ងាយខ្លាចក្រែងម៉ាថេងជីងនឹងលើកមកវាយយកស្រុកហ៊ូគោ កាលក្រោយដែលយើងលើកទ័ព ៨ សែន ៣ ម៉ឺន ទៅវាយយកស្រុកកាំងតាំង គ្រានោះ បានឮគេនិយាយថា ម៉ាថេងទៅ-ហ្វាយស្រុកសែលៀង ប្រុងនឹងលើកទ័ពមកវាយយកស្រុកហ៊ូគោ បើដូច្នោះវេលានេះ យើងត្រូវប្រុងប្រយ័ត្នចាត់ចែងឲ្យនៅរក្សាស្រុកជាមាំ-មួនទើបបាន ។

ស៊ុនហ៊ុវថា ខ្ញុំបាទយល់ឃើញថា បើបារម្ភខ្លាចដូច្នោះត្រូវតែបញ្ចោតឲ្យមានព្រះតម្រាស់ព្រះចៅហៀនតេទៅដល់ម៉ាថេង លោកជា

អ្នកទទួលព្រះតម្រាស់ តាំងម៉ាថេងឲ្យឡើងទីជានាយទាហានធំ នឹងឲ្យប្រាប់ប្រាមអាណាខែត្រខាងទិសទក្សិណ គឺច្បាំងយកស្រុកស៊ុនគួន តែត្រូវហៅយកខ្លួនមកគិតកងការសិន កាលណាម៉ាថេងមកដល់ហើយ យើងត្រូវចាប់សម្លាប់ចេញ រួចសឹមលើកទ័ពទៅវាយយកស្រុកកាំងតាំងជាខាងក្រោយ បើគិតដូច្នេះហើយ ទើបអស់កិច្ចការ ។ ចូឆូឮដូច្នោះក៏យល់ឃើញត្រូវ ទើបឲ្យសរសេរសំបុត្រព្រះតម្រាស់ព្រះចៅហៀនតេ ដូចពាក្យស៊ុនហ៊ុវថា ហើយប្រើព្រះកដប់រើកាន់ទៅឲ្យម៉ាថេង ។

ម៉ាថេងទទួលព្រះតម្រាស់ហើយ ក៏ឲ្យហៅម៉ាឈៀវ, ម៉ាហ៊ុវ ម៉ាធៀត ជាកូន នឹងម៉ាតាយជាក្មួយមកប្រឹក្សាថា ពីដើមតាំងស៊ុនទទួលព្រះតម្រាស់ព្រះចៅហៀនតេ ទៅរិះគិតគ្នានឹងឡេវពី ដើម្បីនឹងកំចាត់ចូឆូចេញ តាំងស៊ុនធ្វើការនោះមិនកំបាំង ចូឆូក៏ចាប់ខ្លួនតាំងស៊ុនសម្លាប់ចេញ យើងនឹងឡេវ-ពីក៏ដោះខ្លួនតែរួចទៅ យើងមកនៅស្រុកសៃលៀងនេះក៏ជាទីកំបាំង ហើយបានឮដំណឹងថា ឡេវពីទៅវាយយកស្រុកកេងជីវ យើងក៏គិតចង់ទៅរកដើម្បីនឹងជួយទំនុកបំរុងឡេវពី ឥឡូវចូឆូឲ្យមានសំបុត្រព្រះតម្រាស់ព្រះ-ចៅហៀនតេឲ្យមកហៅយើង ។ នឹងគិតប្រការម្ដេច ? ។

ម៉ាឈៀវឆ្លើយថា ចូឆូកាន់ព្រះតម្រាស់ព្រះចៅហៀនតេឲ្យហៅ ត្រូវតែទៅកុំខាន បើពុំបានចូលទៅដូចនឹងទទឹងគង់នឹងមានទោស តែបើទៅដល់ស្រុកក្រុងហើយ ត្រូវពិនិត្យមើលកលការឲ្យស្រួលសិន បើឃើញ

លុះមិនធ្វើការបាន ក៏ត្រូវធ្វើតាមព្រះតម្រាស់ព្រះចៅហៀនគេ ត្រាំដែលព្រះអង្គទ្រង់ព្រះអក្សរដោយលោហិតនោះ, ម៉ាតាយជាកូយធ្លើយថា ចូចជាមនុស្សបេះរ៉ះគិតល្អិតជ្រៅណាស់ ភ្ញាចក្រែងឲ្យហៅទៅដល់ហើយនឹងធ្វើអន្តរាយដល់យើងទេដឹង? ។ ម៉ាឈៀវថា ខ្ញុំសុំលើកទាហានទៅជាទ័ពមុខ នឹងលុកយកស្រុកហ៊្វូគោតែម្តង ដើម្បីនឹងជួយគ្រប់គ្រងផែនដីនៃព្រះចៅហៀនគេ ដូចគំនិតបិតាដែលគិតទុកនោះ ។

ម៉ាថេងថា ចៅកុំគាលគិតវីវរឡើយ យើងនឹងទុកចៅនូវហ័នស៊ុយជាសម្លាញ់យើង ឲ្យនៅរក្សាស្រុកសៃលៀងចុះ ខ្លួនយើងនឹងម៉ាហ៊ុវ ម៉ា-ធៀក ម៉ាតាយ នឹងលើកទាហានទៅស្រុកហ៊្វូគោ បើព្រះតម្រាស់ឲ្យហៅពិតក្តី មិនពិតក្តី រាំនឹងធ្វើអន្តរាយ យើងប្រការម្តេចក៏តាមការ តែយើងមានសេចក្តីបារម្ភក្រែងបាននៅរក្សាស្រុកឯកាយ ទើបម៉ាថេងបែងទាហានទាំងឡាយឲ្យទៅរក្សាស្រុកខ្លះ យកទាហាន ៥ ពាន់លើកចេញ-ទៅ ឲ្យម៉ាហ៊ុវ ម៉ាធៀកជានាយទ័ពមុខម៉ាតាយជានាយទ័ពក្រោយ លើកទៅដល់ជិតស្រុកហ៊្វូគោ ប្រហែល ២០០ ស៊ិន (៨ គ.ម.) ក៏បោះទ័ពឈប់នៅទីនោះ ។

លុះចូចូដឹងដំណឹង ក៏បង្គាប់អ៊ុយកុយឲ្យចេញទៅជួបនឹងម៉ាថេងព្រោះម៉ាថេងលើកទាហានមកច្រើន បើនឹងចូលទៅក៏ឲ្យចូលតែខ្លួន ម៉ាថេងនឹងទាហានមានទយសង ១ ដើម្បីនឹងចូលទៅក្រាបបង្គំគាល់ព្រះចៅ

ហៀនតេ ឯបណ្ដាកូនទាហានដែលបានមកពីរម្ញាយនឿយហត់ ហេតុ: ខាតដោយស្បៀងអាហារក៏ត្រូវឲ្យនាំគ្រឿងការខាងក្រៅចុះ លុះថ្ងៃស្អែក នឹងយកស្បៀងអាហារទៅឲ្យ អ៊ុយកុយទទួលពាក្យចូឆូហើយ ក៏ចេញទៅជួបនឹងម៉ាថេង គំនាប់គ្នាហើយ ក៏នាំគ្នាផឹកស្រានឹងបរិភោគអាហារ ឯអ៊ុយកុយ កាលផឹកស្រាស្រវឹងក៏និយាយថា បិតាខ្ញុំឈ្មោះអ៊ុយអ៊ួន ទទួលអនិច្ចកម្មកាលគ្រា លីឈុយ កុយគីលើកទ័ពមកធ្វើអន្តរាយដល់ទីព្រះរាជវាំងព្រះចៅហៀនតេ គ្រានេះចិត្តខ្ញុំក៏ពុំមាននឹងគុំគួរសោះ គ្រានេះ ក៏មកជួបប្រទះនឹងអាសត្រូវចំពោះរាជសម្បត្តិទៀត ។

ម៉ាថេងសួរថា នរណាជាសត្រូវចំពោះរាជសម្បត្តិនោះ ? ។ អ៊ុយកុយឆ្លើយថា គឺចូឆូនោះឯងជាសត្រូវចំពោះរាជសម្បត្តិ អ្នកមិនដឹងទេឬ? បានជាធ្វើមកសួរខ្ញុំ ។ ម៉ាថេងគិតមន្ទិលក្នុងចិត្តថា អ៊ុយកុយជាពួកចូឆូ ខ្លាចក្រែងប្រើមកបញ្ឆោតយកការ ក៏ធ្វើជាតក់ស្លុតរន្ធត់ញាប់ញ័រអស់ទាំងខ្លួន ហើយថាអ្នកកុំបរហាដូច្នេះ ចិត្តចូឆូនេះមិនមែនដូច្នោះទេ បើដឹងដល់ចូឆូហើយ យើងក៏ត្រូវនាំគ្នាស្លាប់អសារឥតការ ។ អ៊ុយកុយក៏ស្រែកគំហកឲ្យម៉ាថេងថា អ្នកភ្លេចហើយឬ ? កាលព្រះចៅហៀនតេទ្រង់ព្រះអក្សរចេញមកដោយព្រះលោហិត គ្រានោះ យើងជាខ្ញុំព្រះអង្គប្រាកដ មិនមែនជាខ្ញុំអាក្បត់ចូឆូនោះទេ អ្នកកុំមន្ទិលសង្ស័យអ្វីនឹងខ្ញុំឡើយ ការទាំងនេះហើយ ខ្ញុំក៏ត្រូវជួយគិតអ្នក ម៉ាថេងស្ដាប់មាត់អ៊ុយ

កុយចរចាំពោះនឹងមាត់ដូចគ្នា  ក៏យល់ថា  មិនមែនល្បិចបញ្ឆោត  ក៏ប្រាប់កិច្ចការអាថ៌កំបាំងតាំងពីដើមនោះឲ្យអ៊ុយកុយ ស្តាប់គ្រប់ប្រការ ។

អ៊ុយកុយឮដូច្នោះក៏ប្រាប់ថា  ឯចូវដែលឲ្យហៅអ្នកចូលទៅគាល់នោះមិនមែនពិតត្រង់ទេ បើអ្នកចូលទៅវេលាណា គេនឹងចាប់សម្លាប់វេលានោះ  ចូរអ្នករិះគិតប្រយ័ត្នខ្លួនឲ្យមាំមួន ។  មាំថេងថា  គំនិតចូវនោះគឺគិតដូចម្តេចខ្លះ អ្នកនៅក្នុងស្រុកនេះជាមួយ គង់នឹងដឹងមិនខាន សូមឲ្យអ្នកជួយគិតចុះខ្ញុំនឹងធ្វើតាម ។ អ៊ុយកុយថា ដែលចូវឲ្យហៅអ្នកចូលទៅគាល់ព្រះចៅហៀនគេនោះ អ្នកត្រូវឆ្លើយទៅវិញថា ទើបមកពីស្រុកឆ្ងាយកំពុងនឿយហត់ណាស់សូមឲ្យបង្អង់ឈប់សិន ព្រឹកនេះ ចូវនឹងឲ្យយកសៀងមកឲ្យទាហានអ្នក  មុខជាចូវនឹងចេញមកមើលកលការខ្លួនឯង  ចូវចេញមកហើយ  ឲ្យអ្នករិះគិតចាប់ខ្លួនវាសម្លាប់ឲ្យបាន ។

មាំថេងឮដូច្នោះ  ក៏ពេញចិត្តណាស់ថា  ការខាងក្នុងស្រុកឲ្យអ្នកជួយគិតកែខៃចុះ ឯការខាងក្រៅនោះខ្ញុំនឹងរិះគិតខ្លួនឯង និយាយគ្នាហើយអ៊ុយកុយក៏លាមាំថេងទៅប្រាប់ចូវថា  មាំថេង  ទើបនឹងមកពីស្រុកឆ្ងាយកំពុងនឿយហត់ណាស់  ដែលនឹងឲ្យចូលមកគាល់នោះសុំឲ្យលោកបង្អង់សិន  ប្រាប់ហើយអ៊ុយកុយក៏លាចូវទៅផ្ទះ  ខាងគ្រិះរិះដែលនឹងគិតធ្វើអន្តរាយចូវ  ក៏ខានមិនសម្រេចដូចប្រាថ្នា  តាំងតែគិតសោចុះសោឡើងយូរណាស់  ទុក្ខក៏ស្រុះនៅក្នុងដើមទ្រូង  ដូចអន្ទង់ស៊ីពងក្នុងទឹក ។

ឯកិរិយាធំឃើញអ៊ុយកុយសោប់សេល់មិនសប្បាយ ក៏ចូលទៅលួងលោមសួរដល់ ២.៣ ដង អ៊ុយកុយក៏មិនប្រាប់ថាប្រការម្តេច ៗ ឯនាងលីស៊ុនអៀង ជាកិរិយាបន្ទាប់ ដាប់មានប្រុសសហាយឈ្មោះបៀវតេកជាប្អូនប្រពន្ធធំ ៗ បៀវតេកនោះចង់បាននាងលីស៊ុនអៀងជាប្រពន្ធ ក៏ទំអត់ចន់ទីងរកកំហុសអ៊ុយកុយយូរណាស់មកហើយ មិនសមនឹងសេចក្តីប្រាថ្នា ៗ

កាលអ៊ុយកុយមិនសប្បាយចិត្តនោះ នាងលីស៊ុនអៀងក្រឡេកឃើញមុខប្តីដូចជាទោមនស្សខឹងក្តៅ ក៏នាំយកហេតុនោះទៅប្រាប់បៀវ-តេកជាសហាយថា អ៊ុយកុយប្តីខ្ញុំទៅធ្វើកដការទីងចូចត្រឡប់មកផ្ទះថ្ងៃនេះ ឃើញកិរិយាដូចជាខឹង ហើយចេះតែសោប់សេល់មិនសប្បាយ មិនដឹងជាហេតុដូចម្តេច ៗ បៀវតេកថា បងបានឮថា អ៊ុយកុយចេញទៅជួបទីងមាំថេង ហើយត្រឡប់មកវិញមិនសប្បាយតែម្តង មុខជាមានរឿងអ្វីប្លែកបានជាដូច្នេះ ប្អូនឯងចូលទៅល្បងលួងលោមសួរឲ្យដឹងការចុះ នោះនាងលីស៊ុនអៀងក៏ចូលទៅ ៗ

លុះដល់ពេលយប់ អ៊ុយកុយក៏ចូលទៅអាស្រ័យដំណេកជាមួយនាងលីស៊ុនអៀង ៗ ក៏ធ្វើប្រតិបត្តិតាមប្រក្រតី ហើយធ្វើ។ពាយនិយាយលួងលោមសួរអ៊ុយកុយថា ឡោកីជាគូជព្រះកដវង្សព្រះចៅហៀនគេ តាំងចិត្តធ្វើកដការទុំនុកបំរុងផែនដីដោយសុចរិត ខាងចូចជាមនុស្សទុច្ចរិត

អាក្រក់ នឹងធ្វើការអ្វីក៏គ្មានត្រង់នឹងផែនដីនោះ ឯខ្លួនលោកក៏ជាមនុស្ស មានគម្រោះប្រាជ្ញា ហេតុអ្វីក៏មកនៅជាមួយចូឆូដែលជាសត្រូវនឹងរាជសម្បត្តិនោះវិញ ។

អ៊ុយកុយផឹកស្រាស្រវឹងខ្លាំង មិនតាំងចិត្តនឹងពិគ្រោះឲ្យឃើញខុសត្រូវធ្ងន់ស្រាល បណ្ដាលឲ្យវង្វេងដោយមាតុគ្រាម លុះតាមកលមាយាស្រីក៏ស្រដីប្រាប់ថា ខ្លួនទៅជាស្រី ស្រាលសេចក្ដីណាស់ បងជាប្រុសទើបដឹងច្បាស់ថា ចូឆូជាសត្រូវរាជសម្បត្តិ បងក៏គិតនឹងធ្វើប្រទូសរ៉ាយចូឆូជាយូរមកហើយ តែខ្លាចមិនសម្រេចសេចក្ដីប្រាថ្នា នាងលីស៊ុនអៀងក៏ធ្វើជាអង្វរសួរថា គំនិតលោកនឹងគិតការនោះដូចម្ដេច ទើបអាចសម្លាប់ចូឆូបាន អាណិតប្រាប់ខ្ញុំឲ្យដឹងជានផងចុះ ខ្ញុំជាស្រីពោះម៉ែមិនស្គាល់ខុសត្រូវក៏គង់ជួយពន្យល់ប្រុសបានខ្លះទៅដែរ ។ អ៊ុយកុយឃើញថា នាងលីស៊ុនអៀងចេះតែសួរក៏ពន្យល់ថា ការណ៍នេះខ្លួនបងនឹងម៉ាថេង បានគិតគ្នាជាស្រេចហើយ ។ ក៏ពណ៌នារឿងរ៉ាវ ដែលគិតនឹងម៉ាថេងនោះ ឲ្យនាងលីស៊ុនអៀងនោះស្ដាប់គ្រប់ប្រការ, លុះអ៊ុយកុយងងុយដោយស្រវឹងស្រាដេកលក់ នាងលីស៊ុនអៀងក៏លបបើកទ្វារចេញទៅប្រាប់ចៀវគេក តាមរឿងដែលអ៊ុយកុយនិយាយនោះ ឲ្យចៀវគេកស្ដាប់ ។ ចៀវគេកក៏ប្រញាប់ទៅប្រាប់ឲ្យចូឆូដឹងទាំងពាក់កណ្ដាលអធ្រាត្រ ។ ចូឆូក៏ឲ្យឃុំខ្លួនចៀវគេកទុកក្នុងបន្ទប់មួយ ហើយឲ្យចំរើលើកគ្នាទៅចាប់ខ្លួនអ៊ុយកុយនឹង

ភរិយាបុត្រទៅដាក់គុកទាំងអស់ ។

គ្រានោះ ចូចូក៏ឲ្យហៅចូហាន ចៅជូ ស៊ីវម្បូន ហៃហ៊ូអៀនមកឲ្យប្រាប់ពតិមាន ដែលចៀវគេកប៉ុងឲ្យការណ៍ពីអ៊ុយកុយនោះឲ្យស្តាប់គ្រប់ប្រការ ហើយបង្គាប់ថា ព្រឹកនេះឲ្យអ្នកកល់គ្នាតែងខ្លួនឲ្យដូចយើង យកទង់ក្រហមរបស់យើងហែមុខទៅ ហើយឲ្យទៅជួជាបែកស្តាំ ឲ្យហៃហ៊ូអៀនជាបែកឆ្វេង ចូហានជាកងហ្លួង ស៊ីវឡុងជាកងជួន លើកចេញទៅតាំងផ្លូវស្ពានទ័ពក្រៅក្រុង ឲ្យធ្វើអាការដូចជានឹងលើកចេញទៅ ។ ម៉ាថេងមិនទាន់ដឹងខ្លួន ក៏សំគាល់ថា យើងលើកចេញទៅ ក៏នឹងលើកទ័ពចូលមកតាមសញ្ញាគានឹងអ៊ុយកុយ អ្នកត្រូវអុជផាវជាសញ្ញាឡើង ហើយឲ្យទាហានបាញ់ធ្នូចំម៉ាថេង ហើយចាប់ខ្លួនឲ្យបាន ។ ចូហាននឹងទាហានទាំងពួង ក៏លើកចេញទៅតាំងតាមបង្គាប់គ្រប់ទ័ពខ្លួន ។

ម៉ាថេង លុះព្រឹកឡើងក៏ចាត់ចែងទាហាន លើកចេញពីកបន្ទាយចូលទៅជិតស្រុកហ៊ូគោ ឃើញទាហានចេញមកមានទង់ក្រហមដោតត្រៀបត្រាក៏មានអំណរក្នុងចិត្តណាស់ សំគាល់ថា ច្បាស់ជាចូចូលើកទ័ពមកដូចពាក្យអ៊ុយកុយនិយាយ ម៉ាថេងក៏បរសេះលើកទាហានដម្រង់ចូលទៅ លុះទៅដល់ជិតក៏ឮសូរសំឡេងផាវ ហើយឃើញទាហានពួកទង់ក្រហមលើកធ្នូឡើងបាញ់ ព្រួញធ្នូក៏ធ្លាក់ចម្រុះមកត្រង់ ឃើញចូវហានបំផាយសេះ

ត្រង់ចូលមក ម៉ាថេងភ័យណាស់បរសេះត្រឡប់រត់ ទទួលទៅធូស៊ីឡុងហៃហ៊ួអៀនលើកទាហានចេញមកហោមរោមព័ទ្ធជុំវិញខ្លួន ម៉ាថេងនឹងម៉ាហ៊ីវ ម៉ាធៀតក៏ពារទំលាយចេញទៅបាន ទទួលព្រួញធ្នូបាញ់ទៅត្រូវទាំង ៣ នាយសេះ របេះធ្លាក់ពីលើសេះ ឯម៉ាធៀតនោះក៏អស់អាយុស្លាប់មួយរំពេច ទាហានក៏ស្ទុះស្រូចូលទៅហោមព័ទ្ធចាប់ខ្លួនម៉ាថេងនឹងម៉ាហ៊ីវចងបាន ហើយនាំខ្លួនចូលទៅជូនចូចូ ៗ ក៏ឲ្យយកខ្លួនអ៊ុយកុយចេញមកសួរពិចារណាឲ្យឆ្លើយតទល់សំដីគ្នានឹងម៉ាថេងនោះ អ៊ុយកុយក៏ឆ្លើយបដិសេធមិនទទួលហើយថា ខ្លួនខ្ញុំបាទនឹងបានគប់គិតគ្នានឹងម៉ាថេងប៉ងប្រាថ្នាប្រទូសរ៉ាយមហាឧបរាជក៏ទេ ហើយនិយាយតទៅនឹងម៉ាថេងថា អ្នកកុំភ័យបារម្ភអ្វីឡើយ ព្រោះខ្លួនយើងមិនមានសេចក្តីខុសពីអ្វីសោះ ខណៈនោះ ចូចូឲ្យនាំយកខ្លួនចៀវគេកចេញមកសួរពិចារណាចំពោះមុខអ៊ុយ-កុយ ចៀវគេកក៏និយាយនឹងពាក្យដដែល ៗ ចូចូក៏សួរអ៊ុយកុយនឹងម៉ា-ថេងតទៅ អ៊ុយកុយម៉ាថេងក៏តទល់សំដីនឹងចៀវគេកទាំងអស់ ៗ

( នៅមានត )

## រឿងព្រងចិង

លោក ក៉យ-ប៊ុតា ប្រែរៀបរៀង

(តមក)

នៅចំកណ្ដាលពួកទ័ពសេះនេះ មានរាជរថមួយទឹមដោយសេះបួន ប្រដាប់ដោយក្បាច់រចនាដ៏មានពណ៌ដូចមាសក្លីក្រហមច្រាលឆ្អៅ ហើយមានទ្វារទីងបង្អួចរចនាដោយកញ្ចក់ ។ ព្រះអង្គម្ចាស់ទ្រង់កៀសព្រះអង្គឲ្យ ដើម្បីឲ្យរាជរថនេះបរដោយសេរីតាមថ្នល់ធំនោះ ។ លុះរាជរថនោះមកដល់, ស្រាប់តែមានបុរសម្នាក់ចេញពីពួកដង្ហែ មកក្រាបបង្គំទូលសួរព្រះអង្គម្ចាស់ថា: “ តើអ្នកឯងលក់អ្វី? បុរសនេះមិនស្គាល់ថាព្រះអង្គជាព្រះរាជបុត្រព្រះមហាក្សត្រទេ ។

– ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបថា: ខ្ញុំគ្មានលក់អ្វីទេ ! ។

– បុរសក៏សួរតទៅទៀតថា: “ តើអ្វីនៅក្នុងកន្ត្រកនោះ? មិនគឺផ្លែប៉ែសឬផ្លែប៉ោមឬ ? ព្រះអង្គម្ចាស់យើងទ្រង់ធ្វើព្រះរាជដំណើរមកតាំងពីព្រឹកទល់ល្ងាច ទ្រង់មានបំណងចង់សោយដែរ ចូរលក់ផ្លែនោះមកឲ្យយើងខ្លះ ! ” ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបថា: “ផ្លែឈើនេះសម្រាប់តែយើងប៉ុណ្ណោះ, យើងមិនអាចលក់បានទេ ! ដូចអ្នកឯងជ្រាបស្រាប់

ហើយ នៅទីនេះគ្មានស្មៅមួយទងសោះ បើខ្ញុំឃ្លាន តើខ្ញុំមានអ្វីបំបាត់ការស្រេកឃ្លានបាន ! " ។

ចំណែកព្រះអង្គម្ចាស់ដែលគង់នៅលើកដរថ ក៏ឲ្យយកប្រាក់ ១ កហាបណៈទៅទិញផ្លែឈើនោះ ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលសួរបុរសថា :

" តើអ្នកឯងទៅណា ? "

បុរសក្រាបបង្គំទូលព្រះអង្គម្ចាស់ថា :

" ព្រះអង្គម្ចាស់យើងទ្រង់យាងទៅកាន់សំណាក់ព្រះអង្គម្ចាស់ក្សត្រដែលទ្រង់ត្រូវបញ្ជាប់ពាក្យ ។

ឯព្រះអង្គម្ចាស់មានព្រះបន្ទូលដូច្នោះ ក៏ទ្រង់បានយកផ្លែឈើប្រទានទៅបុរសនោះ ។

ព្រះអង្គម្ចាស់ដែលគង់លើកដរថ ទ្រង់សោយផ្លែពីរនឹងផ្លែបំបែសស្រស់នោះទៅ ។ ដោយកដរថនោះបេះតែបរ ១ ទៅ, ស្រាប់តែព្រះអង្គម្ចាស់បានបញ្ចេញព្រះសូរសៀងយ៉ាងខ្លាំង ដោយក៏យកក់ស្លុតឥតទបមាដោយទ្រង់ទតព្រះរូបព្រះអង្គទៅឃើញជារូបអមនុស្សមានព្រះភក្រ្ត មានពុកចង្កាហើយព្រះសិរមានស្នែងពីរដុះទំពីលើថែមទៀត ។ ព្រះកដបរិចារដែលដង្ហែព្រះអង្គម្ចាស់ ក៏ឈប់នៅកណ្តាលថ្នល់រង់ចាំអ្នកលក់ផ្លែឈើ ។ បន្តិចទៀតព្រះអង្គម្ចាស់ដែលលក់ផ្លែឈើ, ទ្រង់យាងមកដល់

ទីនេះ ។ ពួករដ្ឋមន្ត្រីក៏ឃាំងផ្លូវមិនឲ្យទ្រង់ស្ដេចយានបាន ។

ពួករដ្ឋមន្ត្រីក្រាបបង្គំសួរថា: “ តើផ្លែឈើដែលទ្រង់បានលក់ថ្វាយព្រះអង្គម្ចាស់យើង យកពីណាមក ” ។

ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូលតបទៅវិញថា: “ ផ្លែឈើនេះគឺ ខ្ញុំបេះពីដើមក់ពិត ។ ” ។

ពួករដ្ឋមន្ត្រីក៏ក្រាបបង្គំទូលថា: “ សូមទ្រង់ទត ! ក្រោយដែលព្រះអង្គម្ចាស់ទូលព្រះបង្គំសោយផ្លែឈើទ្រង់ ។ មេត្តាទតមើលចុះ ម្ដេចក៏លើព្រះភក្ត្រព្រះអង្គមានដុះរោមវែង ។ ហើយនៅលើព្រះសិរមានស្នែងដុះបេះ ! ” ។

ព្រះអង្គម្ចាស់លុះយានទៅកាន់កដរថហើយ ក៏ទ្រង់ទតទៅឃើញមនុស្សម្នាក់អង្គុយក្នុងកដរថមានសភាពប្លែកអស្ចារ្យ. ទ្រង់មានព្រះហឫទ័យសប្បាយឥតបមា ” ។

ព្រះអង្គម្ចាស់ទ្រង់មានបន្ទូលតបទៅវិញថា: “ ខ្ញុំបានសោយផ្លែឈើនោះដែរ, ម្ដេចក៏ខ្ញុំគ្មានរោម, គ្មានស្នែង ! ” ។

ពួករដ្ឋមន្ត្រី ក៏មិនអាចនឹងឆ្លើយតបតនឹងទ្រង់បានឡើយ ។

ក្រោយដែលព្រះអង្គម្ចាស់ទ្រង់ព្រះតម្រិះ ទ្រង់ក៏បានឈ្វេងយល់មួយរំពេចហើយទ្រង់មានបន្ទូលថា :

“ តើព្រះអង្គម្ចាស់អ្នកឯងសោយផ្លែឈើនោះហើយទ្រង់ផ្ទុះ? ” ។

ពួករដ្ឋមន្ត្រីក៏ក្រាបបង្គំទូលតបថា: " ទ្រង់ផ្ទំ " ។

ព្រះអង្គម្ចាស់ទ្រង់តបវិញថា: " ឥឡូវនេះខ្ញុំឥតមានសង្ស័យទេ ! អ្នកឯងជាជនបរទេស, អ្នកឯងមិនដឹងទំនៀមទម្លាប់ប្រទេសនេះ ដែលគេហាមមិនឲ្យដេក ក្រោយដែលបានបរិភោគម្ហូបអាហារហើយ ។ បើយើងដេកមុខជាមានរោមនិងស្នែងហើយ " ។

ពួករដ្ឋមន្ត្រីមើលមុខគ្នាទៅវិញមកហើយថា: " តើយើងធ្វើយ៉ាងណា ! ការណ៍នេះគឺមកពីការស្រេកឃ្លានហួសប្រមាណ នឹងការងងុយងោកងក់នៃព្រះអង្គម្ចាស់យើង តើព្រះអង្គម្ចាស់យើងទៅធ្វើព្រះរាជសមរសជាមួយព្រះអង្គម្ចាស់ក្សត្រីដូចម្ដេចកើត បើព្រះរូបព្រះអង្គអាក្រក់ដូច្នេះ ! ។

មានរដ្ឋមន្ត្រីម្នាក់ពោលថា: " បើយ៉ាងនេះត្រូវតែយើងវិលទៅកាន់ព្រះរាជធានីវិញ " ។

តែព្រះអង្គម្ចាស់ទ្រង់មិនយល់ព្រមតាម ហើយទ្រង់មានព្រះបន្ទូលថា: " យើងរង់ចាំព្រះអង្គម្ចាស់ក្សត្រីជាច្រើនឆ្នាំមកហើយ យើងមិនអាចនឹងដកឃ្លាថយ ខានធ្វើសមរសនឹងព្រះនាងនោះសោះឡើយ " ។

ដល់អវសាន មានរដ្ឋមន្ត្រីម្នាក់ទៀត ដែលស្និតនៅជិតព្រះអង្គបានស្នើសុំប្រើឧបាយកលមួយថា: " យើងត្រូវរកយុវបុរសម្នាក់ មានសភាពស្អាតស្អំប្រកបដោយសោភណភាព ដែលយើងទុកជាព្រះអង្គម្ចាស់យើង

សុទ្ធសាធ ហើយយើងនាំឲ្យចូលទៅក្នុងព្រះបរមរាជវាំងថ្វាយបង្គំព្រះបិតាក្មេក, គង់ជិតព្រះអង្គម្ចាស់ក្សត្រី ។ លុះដល់ព្រះនាងយាងទៅកាន់ព្រះនគរ ព្រះបិតាក្មេកវិញ ព្រះនាងនឹងត្រូវទទួលព្រះអង្គម្ចាស់ជាព្រះស្វាមីពុំខាន " ។

ឧបាយកលនេះបានទទួលយល់ព្រមពីពួករដ្ឋមន្ត្រីទាំងឡាយ ពួករដ្ឋមន្ត្រីទាំងឡាយ ក៏ខំព្យាយាមស្វែងរកយុវបុរសម្នាក់ មានរូបឆោមលោមពិណាស្រស់ប្រិមប្រិយ ។ ក្រោយដែលបានពិនិត្យបុរសកំឡោះដែលស្ថិតនៅទីនោះ រដ្ឋមន្ត្រីទាំងឡាយក៏យល់ថា : " អ្នកលក់ផ្លែឈើនេះជាយុវបុរសមានរូបកាយប្រកបដោយលំអគ្រប់យ៉ាង ក៏មូលមតិគ្នាឲ្យអ្នកលក់ផ្លែឈើនោះ ឡើងជិះលើរាជរថជំនួសព្រះអង្គម្ចាស់ខ្លួន ។ ប៉ុន្តែអ្នកលក់ផ្លែឈើធ្វើពុតពាដូចជាមិនព្រមធ្វើសហការជាមួយសោះ ក៏មានវាចាថា ខ្ញុំប្រញាប់ណាស់ ខ្ញុំមិនអាចបំពេញបេសកកម្មនោះបានឡើយ ។

ពួករដ្ឋមន្ត្រីក៏បានទទូចអង្វរករអ្នកលក់ផ្លែឈើ ឲ្យទទួលធ្វើមុខដំណែងនោះជួសព្រះអង្គម្ចាស់ ។ នឹងប្រទានប្រាក់ប្រាំកហាបណៈ ។

អ្នកលក់ផ្លែឈើតបថា : " ប្រាំកហាបណៈ ! មិនសមនឹងទៅកាន់មុខដំណែងនោះបានទេ " ។

ពួករដ្ឋមន្ត្រីក៏តបមកវិញថា សូមជូន ៧ កហាបណៈចុះ ។

អ្នកលក់ផ្លែឈើ(១) ក៏យល់ព្រមហើយឡើងទៅអង្គុយនៅលើរាជរថ។ ឯព្រះអង្គម្ចាស់ដែលមានពុកមាត់ពុកចង្កាខឹងស្នេង ក៏គង់លើពាជីមួយចូលទៅកាន់រាជធានីនោះដែរ ។ អ្នកលក់ផ្លែឈើគេតុបតែងឲ្យជូតក្បាលនិងកន្សែងធំមានស្បៃបិទមុខជិត ។ ពួករាជមន្ត្រីបានគិតគ្នាថា លុះទៅដល់ព្រះបរមរាជវាំងត្រូវឲ្យព្រះអង្គម្ចាស់យើង ស្ដេចលាក់ពួនខ្លួននៅបន្ទប់មួយ ហើយកុំឲ្យអ្នកណាឃើញសោះឡើយ ។ ការប្រយ័ត្ននេះរួចហើយ រាជរថក៏ធ្វើដំណើរតទៅទៀត ។

លុះបុរសលក់ផ្លែឈើមកដល់រាជធានី, ព្រះមហាក្សត្រនគរនោះ ទ្រង់បានយាងទៅទទួលនៅខាងទ្វារធំយ៉ាងឧឡារិក ។ ទ្រង់បានទតទៅឃើញព្រះសុទិសាមានរូបឆោមល្អស្រស់ជាអនេកកប្បការ ហើយមានព្រះជំនូនច្រើនផង, ទ្រង់មានព្រះរាជហឫទ័យខ្លាចក្រែងព្រះសុទិសាទ្រង់បានជ្រាបនូវព្រឹត្តិការណ៍នៃព្រះអង្គម្ចាស់ក្សត្រី, ទ្រង់ក៏ប្រញាប់ប្រញាល់ចាត់ឲ្យរៀបចំព្រះពិធីសមរសក្នុងវាំង ៤ ថ្ងៃ ៤ យប់យ៉ាងអធិកអធម ។

ពួកចាស់ទុំត្រូវជប់លៀងនៅខាងក្រៅព្រះបរមរាជវាំង ។ ពួកក្មេងអាចចូលមកជប់លៀងនៅក្នុងព្រះបរមរាជវាំង ដើម្បីនឹងកំដរព្រះអង្គម្ចាស់នឹងព្រះនាងបាន ។ ពិធីនឹងកិច្ចការកំសាន្តសប្បាយត្រូវដែលគេបំពេញដោយ

---

១– បុរសលក់ផ្លែឈើនេះជាព្រះអង្គម្ចាស់នេះ តែពួករាជមន្ត្រីទាំងឡាយមិនបានដឹងស្គាល់ទេ បានជាខ្ញុំសូមពណ៌នាជាពាក្យសាមញ្ញ មិនបានប្រើរាជស័ព្ទ ។

ស្ងប់ស្ងាត់ព្រមទាំងប្រយ័ត្នប្រយែងយ៉ាងខ្លាំង, ក្រែងដំណឹងអាក្រក់ពីព្រះនាងលេចឮខ្ចរខ្ចាយទៅបាន ។

ពិធីសមោសកន្លងមក ៣ ថ្ងៃ ព្រះនាងមិនដែលបានទតទៅកាន់ព្រះអង្គម្ចាស់ដល់មួងសោះឡើយ ។ ទ្រង់ព្រះកន្សែងសោយសោកនឹករលឹកដល់ព្រះអង្គម្ចាស់ ដែលទ្រង់ស្នេហាពេញព្រះហឫទ័យ លុះដល់ថ្ងៃទី ៤ ព្រះមហាក្សត្រទ្រង់ព្រួយព្រះរាជហឫទ័យជាខ្លាំង ក៏មានព្រះរាជបញ្ជាឲ្យយាយអករម្នាក់ជាទីទុកព្រះរាជហឫទ័យទៅដំរាបព្រះនាងថា: ព្រះអង្គម្ចាស់ទ្រង់មានព្រះហឫទ័យស្នេហាចំពោះព្រះនាងជាខ្លាំង ។

នៅពេលលៀងព្រះក្រយាស្ងោយមួយនៅសាយណ្ហសម័យ, ព្រះអង្គម្ចាស់ទ្រង់គង់នៅជិតព្រះអង្គម្ចាស់ក្សត្រី ទ្រង់ចៀតឱកាសក្នុងពេលដែលពួកសមន្តរាជទាំងឡាយមិនបានអើពើនឹងទ្រង់ ទ្រង់ខ្សឹបដាក់ព្រះកាណ៌ព្រះនាងថា: ទ្រង់បានវិលត្រឡប់មកវិញហើយ ព្រះនាងទ្រង់បានជ្រាបច្បាស់នូវព្រះសូរសៀងនៃព្រះអង្គម្ចាស់ហើយ, ទ្រង់បើកស្បៃបាំងព្រះភក្ត្រ ហើយទ្រង់បានក្រឡេកទៅឃើញច្បាស់ដូចជាទ្រង់សុបិននិមិត្តដូច្នោះ ។

ព្រះអង្គម្ចាស់ក្សត្រីទ្រង់ជូតព្រះភក្ត្រ ដែលជោរជន់ដោយទឹកព្រះនេត្រ ; ទ្រង់មានព្រះបន្ទូលឆ្លើយតបហើយទ្រង់ព្រះសំរួល ; ទ្រង់បានក៏ជាមួយព្រះអង្គម្ចាស់ជាច្រើនដង ។ ព្រះអង្គម្ចាស់ទ្រង់មានព្រះបន្ទូល

ចំពោះព្រះនាងថា: យើងនឹងគិតធ្វើដំណើរនៅពេលខាងស្អែក សូមព្រះនាងសុំសេះឈើពីព្រះវរបិតា ហើយបើព្រះវរបិតាពុំព្រមព្រះរាជទានទេ សូមព្រះនាងក្រាបបង្គំទូលថា ព្រះនាងមិនព្រមទៅជាមួយទូលបង្គំទេ បើទុកជាព្រះវរបិតាកំញើញគំរាមយ៉ាងណា កុំឲ្យព្រះនាងទ្រង់ភ័យតក់ស្លុតឲ្យសោះ ត្រូវទ្រង់ទទូចសុំព្រះវរបិតានូវសេះឈើនោះឲ្យទាល់តែបាន ។

ចំណែកខាងព្រះមហាក្សត្រវិញ ព្រះអង្គទ្រង់បានចាត់ឲ្យយាយអករ៍ម្នាក់ឃ្លាំមើលព្រះអង្គម្ចាស់ចាំងពីរព្រះអង្គ ។ យាយអករ៍ក៏វិលត្រឡប់ទៅវិញបានក្រាបបង្គំទូលមហារាជថា: "ព្រះអង្គម្ចាស់ទាំងពីរព្រមព្រៀងគ្នាដោយសុខចិត្ត ទ្រង់បានកំព្រៀងចាំងពីរព្រះអង្គយ៉ាងសប្បាយរីករាយ ។ ព្រះមហាក្សត្រទ្រង់មានព្រះរាជហឫទ័យសោមនស្សពន់ពេក ដោយទ្រង់បានដំណឹងល្អនេះ ។

ព្រឹកឡើងមានបុគ្គលជាគៀវកិត្តិយសបានមករង់ចាំ នៅមុខខ្លោងទ្វារព្រះបរមរាជវាំងដើម្បីនឹងក្រាបបង្គំព្រះអង្គម្ចាស់ក្សត្រី ។ ព្រះអង្គម្ចាស់និងព្រះបរិវារបានរង់ចាំព្រះអង្គម្ចាស់ក្សត្រីនៅទីនោះដែរ តែព្រះនាងមិនឃើញយាងទៅ ។ ព្រះនាងបានតាមទារសេះឈើ ពីព្រះវរបិតា; ទ្រង់បានយកព្រះហស្តចាំងពីរឱបព្រះបាទានៃព្រះវរបិតា តាមទារដោយសោកសង្រៀងជាខ្លាំង ។ ព្រះរាជាទ្រង់ព្រះពិរោធជាខ្លាំងទ្រង់ត្រាស់

បង្គាប់ឲ្យហៅនាយពេជ្ឈឃាដមក តែព្រះនាងទ្រង់ឥតមានតក់ស្លុតអ្វីសោះឡើយ ។

ព្រះនាងទ្រង់ក្រាបបង្គំទូលព្រះវរបិតាថា: " សូមបិតាសម្លាប់កូនចុះ, បើបិតាទ្រង់មិនព្រមឲ្យសេះឈើមកកូន " ។

ព្រះរាជាទ្រង់ព្រះពិរោធជាខ្លាំង តែបើទុកជាយ៉ាងណាក៏ដោយ ក៏ព្រះនាងទ្រង់គ្មានព្រឺព្រួចអ្វីសោះឡើយ ទ្រង់មិនលះបង់ព្រះបំណងគឺតាមតារយកសេះឈើនោះទេ ។

ពួកឥស្សរជន ដែលរង់ចាំព្រះនាងនៅខាងទ្វារព្រះបរមរាជវាំង ក៏នឹកឆ្ងល់ថាហេតុដូចម្ដេចក៏បាត់ព្រះនាង មិនឃើញយាងមក ! ។ ពួកនេះក៏ចូលទៅក្នុងព្រះបរមរាជវាំង ដើម្បីនឹងសួរហេតុនោះឲ្យច្បាស់លាស់ ។

ព្រះមហាក្សត្រទ្រង់មានព្រះរាជបន្ទូលថា: " កូនខ្ញុំចង់យកសេះឈើទៅជាមួយនឹងវា ! " ។

ពួកឥស្សរជនក៏ក្រាបបង្គំទូលតបថា :

" សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់ព្រះរាជានុញ្ញាតឲ្យព្រះនាងយកសេះឈើជាល្បែងក្មេងទៅជាមួយព្រះនាងផងចុះ ។

លុះទ្រង់ព្រះសណ្ដាប់ដូច្នោះ ព្រះមហាក្សត្រក៏ប្រគល់សេះឈើឲ្យព្រះនាងភ្លាមមួយរំពេច ។

ព្រះអង្គម្ចាស់ នឹង ព្រះនាងក៏ទ្រង់គង់លើរាជរថផ្ញើព្រះដំណើរចេញ

ទៅដោយមានព្រះបរិពារជាច្រើនពាន់នាក់ហែហមទៅជាមួយផង ។

ព្រះដំណើរនោះមានសភាពឆ្ងាយដាច់ស្រយាល ។ ព្រះអង្គម្ចាស់នឹងព្រះនាងមានមនុស្សថែរក្សាអមព្រះអង្គជានិច្ច បានជាគ្មានឱកាសនឹងគេចព្រះអង្គចេញពីទីនោះសោះ ។ ព្រះអង្គទាំងពីរស្តេចយាងដិតទៅដល់ប្រទេសព្រះមហាក្សត្រនៃព្រះអង្គម្ចាស់ដែលមានស្នេហ៍ ទ្រង់មានព្រះហឫទ័យព្រួយបារម្ភជាខ្លាំង ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះនាងថា: "បើយើងទាំងពីរនាក់ទៅដល់មុខព្រះបរមរាជវាំងនៃព្រះរាជាប្រទេសនោះ សូមព្រះនាងក្រាបបង្គំទូលព្រះមហាក្សត្រថា សូមទ្រង់យកថាសប្រាំពីរសុទ្ធតែពេញទៅដោយមាស ។ មាសនោះ, ព្រះនាងនឹងបាចទៅលើមហាជន ។ បើព្រះមហាក្សត្រទ្រង់មិនព្រមត្រាស់បង្គាប់ឲ្យយកថាសទាំងប្រាំពីរនោះទេ ព្រះនាងមិនត្រូវចុះពីរាជរថឡើយ ។

លុះព្រះអង្គម្ចាស់ទាំងពីរយាងទៅដល់មុខព្រះបរមរាជវាំង ព្រះនាងទ្រង់នឹកឃើញបណ្តាំព្រះស្វាមី ទ្រង់ធ្វើតាមបណ្តាំនោះយ៉ាងម៉ឺងម៉ាត់ ។ មហាជនទាំងប្រុសស្រី ក្មេង ចាស់រត់ទៅដណ្តើមមាស ដែលព្រះនាងទ្រង់បាចលើផែនប្រថពី ។ ក្នុងពេលនោះ ព្រះអង្គម្ចាស់ទ្រង់ទាញព្រះហស្តព្រះនាងហើយទ្រង់គង់លើសេះឈើ ទ្រង់មួលក្ងួរសោ សេះឈើនោះហោះទៅលើអាកាស ។ ព្រះដំណើរនៃព្រះអង្គម្ចាស់ទាំងពីរព្រះអង្គក៏បានទៅដល់រាជធានីដោយសុវត្ថិភាព ។

តាំងពីព្រះអង្គម្ចាស់ស្តេចយាងចុតភិពជលាទី ព្រះវរបិតាព្រះអង្គទ្រង់ព្រួយបារម្ភពន់ពេកដុំពុំបានសោះ មានព្រះរាជឱង្ការថា « ការបាត់ព្រះឱរសនេះ ចុះហេតុមកពីជាងឈើនោះឯង ព្រោះហេតុដូច្នេះ ត្រូវជាងឈើនេះទទួលទណ្ឌកម្មប្រហារជីវិតចង់ » ក៏ត្រាស់បង្គាប់ឲ្យយកជាងឈើ ទៅបោះដែកគោលភ្ជាប់ត្រង់កន្ទុនដែលចូលទៅកាន់ស្ពានអស់រយៈវេលា ៣ ថ្ងៃ ៣ យប់ហើយ ។ ប៉ុន្តែក្នុងពេលនោះ ទទួលព្រះអង្គម្ចាស់ស្តេចនិវត្តមកកាន់រាជធានីវិញ លុះយាងមកដល់ទ្រង់ទតដល់ជាងឈើក្លាម ទ្រង់មានព្រះបន្ទូលទៅកាន់ព្រះវរបិតា: " បិតា, សេះឈើនេះមានប្រយោជន៍សំខាន់ណាស់! បើគ្មានសេះឈើនេះទេ កូនមិនអាចធ្វើដំណើរដោយស្រួលបាន កូនមិនអាចទិញបានព្រះនាងធ្វើជាមហេសីព្រមទាំងមិនអាចវិលត្រឡប់មកកាន់ព្រះរាជនិវេសន៍បានឡើយ» បិតា! សូមព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យហៅជាងឈើ ដែលធ្វើសេះឈើនោះមក សូមឲ្យបិតា ព្រះរាជទានទូវរង្វាន់ដ៏ប្រសើរ ។

លុះទ្រង់ព្រះសណ្តាប់ដូច្នេះហើយ ព្រះមហាក្សត្រទ្រង់ខ្មាស់អៀនពន់ពេក ក៏ប្រាប់ព្រះឱរសថា ព្រះអង្គបានយកជាងនោះទៅបោះដែកគោលចំពីមុខស្ពានហើយ ។ តមកបានត្រាស់បង្គាប់អាមាត្យឲ្យទៅមើលជាងឈើនោះ ។ ឯជាងឈើនៅរស់ពុំទាន់អស់ជីវិតនៅឡើយ ។ គេបាន

នាំជាន់ឈើនោះយកមកថ្វាយព្រះអង្គម្ចាស់ ៗ ក៏បានចាត់គ្រូពេទ្យយ៉ាងជំ-នាញមកព្យាបាលរបួសនោះឲ្យជាសះស្បើយ ៗ ព្រះមហាក្សត្រទ្រង់បានធ្វើព្រះរាជអំណោយនូវថង់មួយពេញទៅដោយមាស ដើម្បីទិញឲ្យជាន់ឈើនេះព្យាយាមធ្វើសេះឈើនេះឲ្យវិសេសវិសាលឡើងតទៅអនាគត ៗ

បន្ទាប់មក មានការជប់លៀង ហើយប្រគំតូរ្យតន្ត្រីគគ្រឹកគគ្រេងជាឧឡារិក ដើម្បីជាព្រះកិត្តិយសចំពោះព្រះរាជសមរស រវាងព្រះអង្គម្ចាស់និងព្រះនាង ៗ

ថ្ងៃក្រោយមក ព្រះអង្គម្ចាស់តាំងពីរព្រះអង្គ ក៏បានឡើងគ្រងរាជ-សម្បត្តិជាជំណាតពីព្រះវរបិតារហូតមក ៗ

ចប់រឿងសេះឈើ

(នៅមានត)

# រឿងព្រេងទាក់ទងដោយភូមិសាស្ត្រខ្មែរ
## ផ្សាយៈចេញពីក្រុមជំនុំទំនៀមទម្លាប់

> ទំនៀមទម្លាប់ នៃខេមរជាតិ
> ខ្មែរគួរខ្មីឃ្មាត សិក្សាពេញទី ។
> ព្រោះខេមរជាតិ ជាជាតិសោភី
> ក្នុងទ្វីបអាស៊ី តាំងពីព្រេងនាយ ។
>
> ប.ព

## រឿងភ្នំសុពណ៌កាលី
### នៅខេត្តក្រចេះ

បើយើងធ្វើដំណើរចេញពីក្រុងភ្នំពេញទៅ តាមផ្លូវទន្លេធំ ដោយទូកប៉ុកប៉ាល ដល់ទៅភ្នំដីប្រាល ហើយបត់ទៅចូលផែផ្សារក្រូចឆ្មារ ស្រុកក្រូចឆ្មារ ជាទីរួមខេត្តកំពង់ចាម ក្រឡេកមើលភ្នែកទៅទិសឦសាន កងទីរួមខេត្តក្រចេះ ស្រុកឆ្លូង ត្រើយខាងជើង ត្រង់ឃុំចម្បក់ យើងនឹងឃើញភ្នំមួយខ្ពស់ខ្ពុង នៅក្បែរឆ្នេរទន្លេនោះ ឈ្មោះ "ភ្នំសុពណ៌កាលី" ជាភ្នំសក្ដិសិទ្ធិ ៗ ប្រវត្តិនៃភ្នំនោះ មានរឿងដំណាលដូចតទៅនេះ ៖

កាលពីព្រេងនាយ មានក្រពើ ១ ឈ្មោះ "សុពណ៌កាលី" ខ្លួនធំមហិមា មានឫទ្ធានុភាពពូកែណាស់ ឥតក្រពើណា

ប្រឡងប្ញទ្ធិផងបាន អាស្រ័យនៅអន្លង់មួយឈ្មោះអន្លង់សាលី ដែលសព្វថ្ងៃហៅកូម៉ិអន្លង់សាលី នៅក្នុងស្រុកស្ទឹងត្រង់ ខែត្រកំពង់ចាម ខាងក្រោមក្នុងសុពណ៌កាលីចម្ងាយប្រហែល ៤០ គីឡូម៉ែត្រ ។

ក្នុងសម័យជាមួយគ្នានោះ នៅឃុំមហាលាភ ស្រុកកោះសូទិន ក្នុងខែត្រកំពង់ចាម មានក្រពើ ១ ឈ្មោះ "នាន់ទៅ" នៅអាស្រ័យក្នុងទឹកទន្លេ ត្រង់ទីកំពង់វត្តមហាលាភ ជាក្រពើរបស់លោកសង្ឃចិញ្ចឹម បើលោកនិមន្តទៅបិណ្ឌបាត ក្រពើនោះតែងបញ្ជូនលោកទៅ ដល់លោកនិមន្តត្រឡប់មកវិញ ក្រពើនោះក៏បានចម្លងមកតាមដំណើរនោះ ។

ក្រពើនោះ មានខ្លួនធំណាស់ ក្បាលប្រវែង ៧ ហត្ថ ចេះតំណែងខ្លួនជាមនុស្សបាន ។ កាលដែលតំណែងខ្លួនជាមនុស្ស បានឮពាក្យមនុស្សនិយាយគ្នាថា "ក្រពើឈ្មោះនាន់ទៅនេះ ធំអ្វីប៉ុណ្ណឹងក្រពើឈ្មោះសុពណ៌កាលី នៅអន្លង់សាលីធំជាងនេះទៅទៀត" ។

នាន់ទៅបានឮពាក្យមនុស្សដូច្នោះ ក៏និម្មិតខ្លួនជាក្រពើដូចដែល ហែលទឹកសំដៅទៅរកក្រពើសុពណ៌កាលី ដោយប្រាថ្នានឹងប្រឡងប្ញទ្ធិគ្នា ទៅតាមផ្លូវមានចម្ងាយច្រើនរយគីឡូម៉ែត្រ, លុះចេញទៅដល់មាត់ពាមផ្កាយម្រេច ប្រទះនឹងយាយចាស់តាចាស់កំពុងដែរទូកក្នុងទន្លេ នាន់ទៅក៏គិតថា "បើខ្លួននៅជាក្រពើនឹងសួរផ្លូវយាយតាយាយនេះពុំបានទេ ព្រោះគាត់ខ្លាច, បើដូច្នេះ គួរតែនិម្មិតខ្លួនជាលោកនេន

ទើបសុំដោយសារខឹងតាត់ភ្នន" គិតដូច្នោះហើយ ក៏ខំម៉ិតខ្ទះធ្វើជាលោកទេន សុំដោយសារជាមួយតាខឹងយាយបានដូចបំណង ។ នាងនុរ៉ៃលោកទេន មិនបានឲ្យតាចៃកៃឡទូកទេ នាងបង្គាប់ថា "សូមតាទៅអង្គុយកាន់ដើងចែវខាងក្បាលទូកចប់ខ្ទួនឲ្យនឹងចុះ" ថាដូច្នោះហើយ នាងនុរ៉ៃលោកទេន ក៏ចំចែវទូកលឿនបន្តិចម្តង ៗ យូរទៅរតតែលឿនឡើង ៗ ដោយអំណាចនាងនុរ៉ៃទិមិតយកកន្ទុយជួយកាយទឹកផងផង, ចំនួន ៤ ម៉ោងទើបដល់កន្លែងក្រពើសុពណ៌កាលីនោះ, នាងនុរ៉ៃលោកទេន បានសួរទៅតាយាយថា "ឡើងត្រើយខាងណាតា!?" ។ តាយាយប្រាប់ទៅវិញថា "ឡើងត្រើយខាងស្តាំនេះបានហើយ" ។ លុះចូលទូកទៅដល់កំពង់ នាងនុរ៉ៃលោកទេន ជួយអូសទូកតាយាយឲ្យផុតពីទឹក ។ តាថា "ដាក់ទូកត្រឹមហ្នឹងបានហើយ" ។ នាងនុរ៉ៃលោកទេនថា "ពុំបានទេតា!", ថាហើយក៏អូសទូកនោះទៅដាក់ដល់ចំពោះមាត់ជ្រាំង ចងក្រៀកដោយប្រាក់ក្ជាប់នឹងបង្គោល ព្រោះនាងនុរ៉ៃគិតថា "នៅពេលប្រឡងប្ញទ្ធិគ្នានោះ រលកទឹកខ្លាំងណាស់ ពោរដល់ចំពោះជ្រាំង បើប្រហែសមិនចងទូកឲ្យជាប់មុខជានឹងអណ្តែតទូកនោះបាត់", រួចហើយក៏ប្រែខ្លួនជាក្រពើ លោតចុះទៅក្នុងទឹក ហែលសំដៅទៅរកក្រពើសុពណ៌កាលី បានជួបគ្នាហើយក៏ប្រខាំគ្នាដោយប្ញទ្ធិយ៉ាងអស្ចារ្យ បញ្ច្រាំខ្លួនផុតពីទឹក ផ្អើលអស់មនុស្សមកមើលត្រៀបត្រា រលកទឹកបោកហួសចំពោះជ្រាំង ។ លុះប្រខាំគ្នាយូរទៅ ក្រពើនាងនុរ៉ៃ

មានបុទ្ធិជាង ទាំងត្រីពោះក្រពើសុពណ៌កាលី ។ ក៏ធ្លាយពោះស្លាប់មួយរំពេច ក្លាយកើតជាកំមួយហៅថា "កំសុពណ៌កាលី" តាមនាមក្រពើនោះ ដកបមកដល់សព្វថ្ងៃនេះ ។

(ភ្នំនេះ ពូកែសក្តិសិទ្ធិណាស់ បើអ្នកណាទៅរៀនមន្តវិជ្ជានៅទីភ្នំនោះ កំពុងអង្គុយស្វាធ្យាយ មានពួកភូតបិសាច មកលួងធ្វើជាជុំមាសប៉ុនផ្លែងទុំ ឬស្រីក្រមុំមកពិតតែបស្អាតាំងសងខាង, បើអ្នករៀនវិជ្ជានោះភ្ញាក់ចំណាប់ ចង់បានរបស់អស់នោះ មុខជាពួកនោះវាយបំបាក់កស្លាប់ពុំខាន) ។

កាលមានជ័យជំនះហើយ ក្រពើនាងខ្មៅនោះ ក៏ត្រឡប់ទៅទីលំនៅវិញ ។ លុះនៅយូរបន្តិចទៅ ក្រពើនោះកំពុងតែបញ្ចេះលោកខេនធ្ងន់ទឹក ស្រាប់តែប្រទះនឹងក្រពើជាបច្ចាមិត្រដដែលទៀតមកបៀតបៀន, នាងខ្មៅក៏គិតថា "ឥឡូវនេះ នឹងទុកលោកខេននៅកន្លែងណា?" ។ រកកន្លែងនឹងទុកគ្មាន នាងខ្មៅក៏លេបលោកខេនចូលទៅក្នុងពោះខ្លួន ហើយក៏ប្រយុទ្ធនឹងក្រពើជាបច្ចាមិត្រ ។ ក្រពើបច្ចាមិត្រចាញ់ក្រពើនាងខ្មៅគេចខ្លួនរត់បាត់ទៅ ។

លុះរួចកិច្ចប្រយុទ្ធនេះហើយ នាងខ្មៅក៏ខ្ជាក់លោកខេនចេញពីពោះតាមមាត់ខ្លួនមកវិញ ឃើញលោកខេននោះសុគត នាងខ្មៅក៏កើតសេចក្តីសោកស្តាយក្រៃពេក ។

នៅខណៈដែលពួកមហាជន កំពុងធ្វើបុណ្យឈាបនកិច្ចរំលាយសព្វលោកខេននោះ, ក្រពើនាងខ្មៅក៏ក៏វាទៀងទៅដេកលើគំនរភ្លើងដែលកំពុងឆេះពេញអំណាច ។ គេជាជាតុកំឆេះក្រពើនាងខ្មៅបង់ជីវិតទៅ ។

ផ្នែកកំណត់ដំណឹងប្រវត្តិការណ៍

ពត៌មានផ្សេងៗរបស់ក្រសួងធម្មការ

# ការតាំងមន្ត្រីសង្ឃ

តាមព្រះរាជក្រឹត្យលេខ ១៤ ន.រ. ចុះថ្ងៃ ២៥ មីនា ១៩៦១ សម្តេចព្រះនរោត្តម-សីហនុ ឧបយុវរាជ ព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យតាំងព្រះគ្រូវរបញ្ញាមុនី ងួយ-យ៉ិន ជន្មាយុ ៤៣ ឆ្នាំ, វស្សា ២០ ជាឋានានុក្រម នៅវត្តបទុមវតី ក្រុងភ្នំពេញ ជារាជាគណៈសម្រាប់ចត្តា មានគោរម្យងារជា « ព្រះធេតមោលី » ជាជំនួសព្រះទេពមោលី ធួត-ម៉ាង់ ដែលទទួលអនិច្ចធម្ម ។

បានតាំងលោកគ្រូ ញ៉ៀប-ឡៅ ជន្មាយុ ៥១ ឆ្នាំ, វស្សា ៣១ នៅវត្តឥន្ទវង្ស ឃុំមៀន ជាព្រះគ្រូវជីរវិទូ អនុគណស្រុកព្រៃឈរ ខេត្តកំពង់ចាម ។

បានតាំងលោកគ្រូ ច្រាក់-ជន ជន្មាយុ ៥០ ឆ្នាំ, វស្សា ២៨ នៅវត្តជោតនារាម ជាព្រះគ្រូសំវរមុនី អនុគណស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

បានតាំងលោកគ្រូ ឡា-ឈាង ជន្មាយុ ៦៣ ឆ្នាំ, វស្សា ៤៣ នៅវត្តគិរីទក្ខិណារាម ឃុំតាំងយ៉ាប ជាព្រះគ្រូមង្គលទេព្វលោករង្ស មេគណខេត្តតាកែវ ។

បានតាំងលោកគ្រូ សិង្ហញាន-សួង ជន្មាយុ ៤៩ ឆ្នាំ, វស្សា ២៨ ជាព្រះគ្រូវិសុទ្ធសីលធម្ម មេគណខេត្តកោះកុង ។

បានតាំងលោកគ្រូ ភិរ-ង៉ៅ ជន្មាយុ ៤៣ ឆ្នាំ, វស្សា ៣២ ជាព្រះ-គ្រូទីបរក្ខសត្តា អនុគណស្រុកកោះកុង ។

បានតាំងលោកគ្រូ សាំង ហួយ ជន្មាយុ ៤៤ ឆ្នាំ, វស្សា ២២ នៅវត្តអរញ្ញារាម លំផាត់ ជាព្រះគ្រូធម្មញ្ញាណចារី មេគណខេត្តរតនគិរី ។

បានតាំងលោកគ្រូ យេង-សេង ជន្មាយុ ២៥ ឆ្នាំ, វស្សា ៥ នៅវត្តអរញ្ញារាម លំផាត់ ជាព្រះបាឡាត់ព្រហ្មវិទូមេធ សម្រាប់មេគណខេត្តរតនគិរី ។

បានតាំងលោកគ្រូ ចាំច៉ា-ច៉ោត ជន្មាយុ ២៦ ឆ្នាំ, វស្សា ៦ នៅវត្តរតនរង្សី បកែវ ជាព្រះវិន័យធរ សម្រាប់មេគណខេត្តរតនគិរី ។

បានតាំងលោកគ្រូ ក្មេង-ខាំង ជន្មាយុ ២៣ ឆ្នាំ, វស្សា ២ នៅវត្តអរញ្ញារាម លំផាត់ ជាព្រះសមុហ៍ សម្រាប់មេគណខេត្តរតនគិរី ។

បានតាំងលោកគ្រូ ងី-ស៊ី ជន្មាយុ ២២ ឆ្នាំ, វស្សា ២ នៅវត្តអរញ្ញា-រាម លំផាត់ ជាលេខាធិការ សម្រាប់មេគណខេត្តរតនគិរី ។

---